


**គណៈកម្មការគ្រប់គ្រងកម្មវិធី**

## គណៈកម្មការគ្រប់គ្រងកម្មវិធី

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

លោកជំទាវបណ្ឌិត **ស៊ើ សុជាតា**

ឯកឧត្តម **ពុត សាមិត្ត**

លោកជំទាវ **គឹម សេដ្ឋានី**

លោកជំទាវ **ទន់ សាអ៊ឹម**

លោកជំទាវវេជ្ជបណ្ឌិត **ឆាយគឹម សុទ្ធាវី**

## គណៈកម្មការនិពន្ធ

លោកស្រី **ធឹម លន់**

លោកស្រី **ហ៊ុន ហ្សីឌីឡា**

លោកស្រី **ពេជ សុគន្ធា**

លោក **ឡឹង ឧុទ្ធី**

## គណៈកម្មការរៀបរៀងនិងពិនិត្យ

លោកជំទាវវេជ្ជបណ្ឌិត **ឆាយគឹម សុទ្ធាវី**

ឯកឧត្តមវេជ្ជបណ្ឌិត **យង់ គន្ធារិទ្ធ**

លោកជំទាវវេជ្ជបណ្ឌិត **ស្វ ឆវីរត្ន**

## ជំនួយការបច្ចេកទេស

លោក **គួ ប៊ុនឃាង**

## វិចិត្រករ

លោក **ឡុង សុវណ្ណា**

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ .................. អយក.ប្រក. ចុះថ្ងៃទី.....ខែ........ឆ្នាំ២០២២ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

**ហាមថតចម្លង**

រក្សាសិទ្ធិ ©

**នាយកដ្ឋានសុខភាពសិក្សា**

បោះពុម្ពផ្សាយ ឆ្នាំ២០២២

ចំនួន ........................ច្បាប់

# អ្នកពិគ្រោះយោបល់បច្ចេកទេស

- លោកទន្តបណ្ឌិត **ហាក់ ស៊ីថន** ក្រសួងសុខាភិបាល
- លោកស្រីទន្តបណ្ឌិត **ឆៃ ទេព្វិរូ** ក្រសួងសុខាភិបាល
- លោកស្រីវេជ្ជបណ្ឌិត **ហុក ស៊ីវ៉ាន្នី** ក្រសួងសុខាភិបាល
- លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ដោរ សីហា** ក្រសួងសុខាភិបាល
- លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ម៉ារ អមរិន្ទ** ក្រសួងសុខាភិបាល
- លោកស្រីវេជ្ជបណ្ឌិត **អ៊ុក សុគន្ធ** ក្រសួងសុខាភិបាល
- លោក **មឿង សុភេន** ក្រសួងបរិស្ថាន
- លោកសាស្ត្រាចារ្យ **កៅ សុវណ្ណតារា** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- លោកវេជ្ជបណ្ឌិត **ឃឹម សំអាត** អង្គការ WHO
- លោកវេជ្ជបណ្ឌិត **ឃិល ដារ៉ាចុង** អង្គការ WHO
- លោក **ជុំ ចាន់រ៉ា** អង្គការ UNICEF
- លោកស្រីវេជ្ជបណ្ឌិត **ចុង វណ្ណដារ៉ា** អង្គការ **UNFPA**
- លោកស្រី **សេក ស៊ីសុខុម** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា **RHAC**
- លោកស្រីបណ្ឌិត **សាផន សុមោលីរស្មី** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា **RHAC**
- លោកស្រី **ឱម យុទ្ធារី** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា **RHAC**
- លោក **តាន់ តិរៈ** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា **RHAC**
- លោក **គង់ សារ៉ែម** អង្គការ SAVE THE CHILDREN
- កញ្ញា Eri Kai អង្គការ FIDR
- លោកស្រី **គីម ចាន់រ៉ាច័យ** អង្គការ FIDR
- លោកស្រី **ហុង គីមឡុង** អង្គការ FIDR
- លោក **រី ម៉ូរ៉ា** អង្គការ FIDR
- លោកបណ្ឌិត **ភឿន ប៊ុណ្ណា** សមាគម EMDR
- កញ្ញា **ហុង ណៃស៊ីម** សមាគម EMDR
- លោក **ភុល សុភារិទ្ធ** សមាគម EMDR
- លោក **ហែម គា** អង្គការ HAGAR Cambodia

# អារម្ភកថា

សៀវភៅ "អប់រំសុខភាព" សម្រាប់គ្រូថ្នាក់ទី៥ នេះ ត្រូវបានរៀបចំឡើងតម្រូវទៅតាមមេរៀនដែលមាននៅក្នុងសៀវភៅអប់រំសុខភាពសម្រាប់សិស្ស ដោយបានកំណត់ច្បាស់លាស់នូវចំនួនម៉ោងនៃការបង្រៀនមេរៀននីមួយៗ ដែលបានកំណត់នៅក្នុងកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំសុខភាព។ សៀវភៅនេះមានបង្ហាញពីវិធីសាស្ត្របង្រៀន តាមបែបសិស្សមជ្ឈមណ្ឌល ដើម្បីជាជំនួយដល់គ្រូបង្រៀនក្នុងការរិះរកគំនិតច្នៃប្រឌិត បង្កើតសកម្មភាពបង្រៀន ធ្វើឱ្យមានការចូលរួមពីសិស្ស សំដៅឱ្យសិស្សចងចាំបានល្អ។

ការបង្រៀននិងរៀនមុខវិជ្ជាអប់រំសុខភាព មានគោលដៅឱ្យអ្នកសិក្សា មានចំណេះដឹងសុខភាពស្របតាមការលូតលាស់រាងកាយនិងស្មារតីប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ បំណិនសម្រាប់បង្ការជំងឺឆ្លង ជំងឺមិនឆ្លង គ្រោះថ្នាក់ផ្សេងៗ និងវិធីជួយសង្គ្រោះបឋម គុណតម្លៃនិងឥរិយាបថដែលនាំឱ្យពួកគេអភិវឌ្ឍខ្លួនប្រកបដោយភាពពេញលេញទាំងកាយ ប្រាជ្ញាស្មារតីនិងចេះទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន។ គោលដៅនៃមេរៀននីមួយៗ បានកំណត់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា សម្រាប់លោកគ្រូអ្នកគ្រូរៀបចំសកម្មភាពបង្រៀនតាមវិធីសាស្ត្រចូលរួមទាំងការសិក្សាបែបបញ្ញត្តិ បែបរិះរក និងបែបប្រធានបទ។ លោកគ្រូ អ្នកគ្រូអាចប្រើប្រាស់វិធីសាស្ត្រលាយច្របាច់បញ្ចូលគ្នា ដោយមានភាពទន់ភ្លន់ បត់បែនតាមខ្លឹមសារនៃមេរៀន ធ្វើយ៉ាងណាបង្កើនពុទ្ធិដល់សិស្សក្នុងការប្រកាន់យកនិងអនុវត្តប្រចាំថ្ងៃរបស់ពួកគេ ដើម្បីបង្ការជំងឺឆ្លង ជំងឺមិនឆ្លង និងគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងបំណិនថែទាំសុខភាពជាប់ជាប្រចាំទាំងពេលបច្ចុប្បន្ននិងទៅអនាគត សំដៅធ្វើឱ្យខ្លួនឯងនិងអ្នកនៅជុំវិញខ្លួនមានសុខភាពល្អ កម្លាំងមាំមួន និងមានសុវត្ថិភាពគ្រប់កាលៈទេសៈក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

យើងខ្ញុំជាគណៈកម្មការនិពន្ធ សង្ឃឹមថា សៀវភៅនេះ នឹងក្លាយជាឯកសារគោលដ៏សំខាន់សម្រាប់ការបង្រៀនមុខវិជ្ជាអប់រំសុខភាព។ ព្រមជាមួយគ្នានេះ យើងខ្ញុំរង់ចាំទទួលយកនូវរាល់សំណូមពរនិងមតិចូលរួមផ្សេងៗ អំពីសំណាក់លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាពីគ្រប់មជ្ឈដ្ឋាន ដើម្បីជួយលើកស្ទួយមុខវិជ្ជាអប់រំសុខភាពកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

**គណៈកម្មការនិពន្ធ**

# បញ្ជីអត្ថបទ


សមាសភាគទី១ : សុខភាពបឋម

ជំពូកទី១ : អាហាររូបត្ថម្ភ និងអនាម័យ ..... 1

**មេរៀនទី ១ : អាហារូបត្ថម្ភពេលពេញវ័យ** ..... 1

**មេរៀនទី ២ : អនាម័យពេលពេញវ័យ** ..... 6

ជំពូកទី២ : ការថែទាំភ្នែកនិងមាត់ធ្មេញ ..... 10

**មេរៀនទី ១ : អនាម័យមាត់ធ្មេញ** ..... 10

**មេរៀនទី ២ : ការវាស់គំហើញ** ..... 14

**មេរៀនទី ២ : ការវាស់គំហើញ (ត)** ..... 17

**មេរៀនទី ២ : ការវាស់គំហើញ (តចប់)** ..... 23

ជំពូកទី៣ : ការបង្ការជំងឺឆ្លង ..... 27

**មេរៀនទី ១ : ការពុលអាហារ** ..... 27

**មេរៀនទី ១ : ការពុលអាហារ (តចប់)** ..... 31

**មេរៀនទី ២ : ជំងឺរាក** ..... 35

**មេរៀនទី ២ : ជំងឺរាក (តចប់)** ..... 38

**មេរៀនទី ៣ : ថ្នាំបង្ការ** ..... 42

**មេរៀនទី ៣ : ថ្នាំបង្ការ (តចប់)** ..... 46

សមាសភាគទី២ : សុខភាពផ្លូវចិត្ត ..... 50

**មេរៀនទី ១ : ទំនុកចិត្តនិងការទាក់ទងជាមួយមិត្តភក្តិ** ..... 50

**មេរៀនទី ២ : ការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ** ..... 54

**មេរៀនទី២ : ការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ (តចប់)** ..... 58

សមាសភាគទី៣ : សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ..... 61

ជំពូកទី១ : សីលធម៌ក្នុងជីវិតផ្លូវភេទ ..... 61

**មេរៀនទី ១ : ទំនាក់ទំនង** ..... 61

មេរៀនទី ២ : ទំនាក់ទំនង (តចប់) ..... 65

**មេរៀនទី ២ : ការបង្កើតមិត្តល្អ** ..... 68

**មេរៀនទី ៣ : ការស្វែងយល់ពីយេនឌ័រ** ..... 71

**មេរៀនទី ៤ : ការគោរពគ្នាទៅវិញទៅមក** ..... 75

**មេរៀនទី ៥ : ការប៉ះពាល់ដោយសុជីវធម៌ និងខ្វះសុជីវធម៌** ..... 79

**មេរៀនទី ៦ : ការសម្រេចចិត្ត ជំនាញចរចា និងបដិសេធ** ..... 85

**មេរៀនទី ៦ : ការសម្រេចចិត្ត ជំនាញចរចា និងបដិសេធ (តចប់)** ..... 89

ជំពូកទី២ : ការលូតលាស់រាងកាយនៅពេលពេញវ័យ ..... 92

មេរៀនទី ១ : ការប្រែប្រួលនៅពេលពេញវ័យ ..................................................... 92
មេរៀនទី ១ : ការប្រែប្រួលនៅពេលពេញវ័យ (តចប់) ....................................... 96
មេរៀនទី ២ : សរីរាង្គភេទ ......................................................................... 99
មេរៀនទី ២ : សរីរាង្គភេទ (តចប់) .............................................................. 103
មេរៀនទី ៣ : ការមករដូវ ......................................................................... 107
សមាសភាគទី៤ : សុខភាពនិងបរិស្ថាន .......................................................... 112
មេរៀនទី ១ : កាកសំណល់និងផលប៉ះពាល់សុខភាព.............................................. 112
មេរៀនទី ១ : កាកសំណល់និងផលប៉ះពាល់សុខភាព (តចប់) ................................ 115
មេរៀនទី ២ : ការបំពុលទឹកនិងផលប៉ះពាល់សុខភាព ........................................ 119
មេរៀនទី ២ : ការបំពុលទឹកនិងផលប៉ះពាល់សុខភាព (តចប់) ........................... 122
មេរៀនទី ៣ : គ្រោះថ្នាក់នៃសារធាតុញៀន..................................................... 125
មេរៀនទី ៣ : គ្រោះថ្នាក់នៃសារធាតុញៀន (តចប់) ........................................ 129

# មេរៀនទី ១ : អាហារូបត្ថម្ភពេលពេញវ័យ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីសារជាតិចិញ្ចឹមសំខាន់ៗដែលត្រូវការពេលពេញវ័យ<br>• រៀបរាប់ពីសារៈសំខាន់នៃការបរិភោគអាហារអំឡុងពេលពេញវ័យ។ | • បង្ហាញពីសារជាតិសំខាន់ៗដែលត្រូវបរិភោគនៅពេលពេញវ័យ<br>• កត់ត្រាពីប្រភេទអាហារដែលត្រូវបរិភោគប្រចាំថ្ងៃនៅពេលពេញវ័យ។ | • បណ្ដុះទម្លាប់បរិភោគអាហារឱ្យបានច្រើនក្រុមដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់។ |

**៣- សម្ភារៈ**

សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារ និងគំនិតសំខាន់ៗ**

- សារជាតិចិញ្ចឹមសំខាន់ៗអំឡុងពេលពេញវ័យមានដូចជា ជាតិដែក កាល់ស្យូម និងប្រូតេអ៊ីន។
- សារៈសំខាន់នៃការបរិភោគអាហារដែលមានសារជាតិចិញ្ចឹមសំខាន់ៗអំឡុងពេលពេញវ័យ រួមមានអាហារដែលសម្បូរជាតិកាល់ស្យូមជួយឱ្យឆ្អឹងរឹងមាំ លូតកម្ពស់ និងមានសុខភាពល្អ។ ជាតិដែកជួយបង្កើតគ្រាប់ឈាមក្រហម ជាពិសេសកុមារីដែលបានបាត់បង់ឈាមនៅពេលមករដូវ។ ប្រូតេអ៊ីនជួយដល់ការលូតលាស់ និងជួយទ្រទ្រង់រាងកាយទប់ទល់ប្រឆាំងនឹងជំងឺផ្សេងៗ។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សា ការងារជាដៃគូ ឬក្រុម ពន្យល់ សំយោគ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំឭកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
    - តើអ្នកត្រូវជ្រើសរើស និងហូបអាហារប្រភេទណាខ្លះ ដើម្បីមានសុខភាពល្អ?
    - តើអ្វីទៅជាសារជាតិចិញ្ចឹមដែលអ្នកបានរៀនកន្លងមក? គ្រូទុកពេល ៣ នាទី ឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ចម្លើយ**

- សារជាតិចិញ្ចឹមមានផ្ទុកនៅក្នុងអាហារ ហើយពេលដែលយើងបរិភោគចូលទៅក្នុងខ្លួន វាធ្វើឱ្យយើងមានសុខភាពល្អ។ សារជាតិចិញ្ចឹមត្រូវបានគេចែកចេញជា ២ ក្រុម គឺ ម៉ាក្រូសារជាតិ និង មីក្រូសារជាតិ។ **ម៉ាក្រូ**មានន័យថាធំ ដូច្នេះតម្រូវការពីសារជាតិចិញ្ចឹមប្រភេទនេះក្នុងបរិមាណច្រើន។ សារជាតិចញ្ចឹមក្នុងម៉ាក្រូសារជាតិមានបីៈ កាបូអ៊ីដ្រាត ប្រូតេអ៊ីន និងលីពីត។ **មីក្រូ**មានន័យថាតូច ដូច្នេះយើងត្រូវការសារជាតិទាំងនេះក្នុងបរិមាណតិចតួច ប៉ុន្តែសារជាតិទាំងនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់រាងកាយរបស់យើង។ មីក្រូសារជាតិមានពីរប្រភេទគឺ វីតាមីន និង សារជាតិរ៉ែ( ជាតិដែក កាល់ស្យូម ប៉ូតាស្យូម... )។



តើខ្ញុំត្រូវជ្រើសរើសនិងហូបអាហារប្រភេទណាខ្លះ ដើម្បីមានសុខភាពល្អ?

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : សារជាតិចិញ្ចឹមសំខាន់ៗអំឡុងពេលពេញវ័យ**

- គ្រូឱ្យសិស្សមើលសៀវភៅសិស្សរួចពន្យល់។ តើអ្វីទៅជាភាពពេញវ័យ ? គ្រូហៅសិស្ស ៣-៤ នាក់ ឱ្យឆ្លើយ។
- សម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវ។

**ចម្លើយ**

- ក្មេងប្រុស ឬក្មេងស្រី ដែលមានអាយុចន្លោះពី ១០ ទៅ ១៤ឆ្នាំ ចាប់ផ្តើមកត់សម្គាល់ឃើញថារាងកាយរបស់ពួកគេមានការប្រែប្រួល ហើយវិវត្តន៍ទៅរកភាពពេញវ័យ ក្នុងពេលដ៏សំខាន់នេះ រាងកាយមានការលូតលាស់លឿន ពិសេសកម្ពស់ និងទម្ងន់ ដែលចាំបាច់ត្រូវការអាហារបត្ថម្ភទាំង ម៉ាក្រូ និងមីក្រូសារជាតិ។

• គ្រូសួរ : តើសារជាតិសំខាន់ៗដែលត្រូវការអំឡុងពេលពេញវ័យមានអ្វីខ្លះ ? វាមានមុខងារដូចម្តេចខ្លះ ? គ្រូទុកពេល ៣នាទី ឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវ។

| សារជាតិចិញ្ចឹម | មុខងារ | ប្រសិនបើអ្នកមិនបានបរិភោគគ្រប់គ្រាន់(កង្វះ) នឹងធ្វើឱ្យ |
|---|---|---|
| ជាតិដែក | - ជួយបង្កើតគ្រាប់ឈាមក្រហម  - ជួយបញ្ជូនអុកស៊ីសែនទៅកោសិកានៃរាងកាយ  | ស្លេកស្លាំង ឈឺក្បាលដោយសារខ្វះជាតិដែក  |

| សារជាតិចិញ្ចឹម | មុខងារ | ប្រសិនបើអ្នកមិនបានបរិភោគគ្រប់គ្រាន់(កង្វះ) នឹងធ្វើឱ្យ |
|---|---|---|
| ជាតិកាល់ស្យូម | ជួយឱ្យធ្មេញនិងឆ្អឹងរឹងមាំមានសុខភាពល្អ   | ឆ្អឹងចុះខ្សោយមិនអាចលូតលាស់ល្អទេ បើមិនបរិភោគជាតិកាល់ស្យូមបានគ្រប់គ្រាន់។ ឆ្អឹងពុកនៅពេលអាយុកាន់តែច្រើន។  |

| សារជាតិចិញ្ចឹម | មុខងារ | ប្រសិនបើអ្នកមិនបានបរិភោគគ្រប់គ្រាន់(កង្វះ) នឹងធ្វើឱ្យ |
|---|---|---|
| ប្រូតេអ៊ីន | ជួយបង្កើតកោសិកា និងជាលិកាក្នុងរាងកាយ ដូចជាសាច់ដុំ ស្បែក សក់ ក្រចក និងទឹករងៃ។   | កម្ពស់និងទម្ងន់លូតលាស់យឺត។ |

**ខ្លឹមសារ : សារៈសំខាន់នៃការបរិភោគអាហារដែលមានសារជាតិចិញ្ចឹមសំខាន់ៗអំឡុងពេលពេញវ័យ**

- សកម្មភាព : គ្រូបែងចែកសិស្សជាក្រុមពិភាក្សាពីប្រភពអាហារ និងសារៈសំខាន់នៃការបរិភោគអាហារដែលមានសារជាតិចិញ្ចឹមសំខាន់ៗអំឡុងពេលពេញវ័យក្នុងតារាងខាងក្រោម៖

| សារជាតិចិញ្ចឹម | ប្រភពអាហារ | សារៈសំខាន់ |
|---|---|---|
| ជាតិដែក | | |
| កាល់ស្យូម | | |
| ប្រូតេអ៊ីន | | |

- តំណាងក្រុមឡើងរាយការណ៍និងបកស្រាយ
- គ្រូសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

| សារជាតិចិញ្ចឹម | ប្រភពអាហារ | សារៈសំខាន់ |
|---|---|---|
| ជាតិដែក | **ប្រភពពីសត្វ:** ថ្លើមសត្វ ឬសាច់ក្រហម  **ប្រភពពីរុក្ខជាតិ:** បន្លែពណ៌បៃតងចាស់ ផ្លែឈើក្រៀម និងគ្រាប់ធញ្ញជាតិមានជាតិប្រេង  | ពេលពេញវ័យ គឺជាពេលវេលានៃការលូតលាស់យ៉ាងឆាប់រហ័ស ជាពិសេសក្មេងស្រីនៅអាយុចន្លោះនេះត្រូវការជាតិដែកបន្ថែម ដើម្បីបង្កើតគ្រាប់ឈាមក្រហម ដែលបានបាត់បង់ប្រចាំខែនៅពេលពួកគេមានរដូវ។ |
| កាល់ស្យូម | **កាល់ស្យូម** ច្រើនតែមាននៅក្នុងទឹកដោះគោនិងផលិតផលទឹកដោះគោ ដូចជា : យ៉ាអ៊ួ ឬឈីស។ ប៉ុន្តែវាក៏អាចត្រូវបានគេរកឃើញនៅក្នុងត្រីតូចៗ ផ្កាខាត់ណាបៃតង និងសារ៉ាយសមុទ្រផងដែរ។  | អំឡុងពេញវ័យ រាងកាយយើងអាចស្រូបយក និងរក្សាទុកជាតិកាល់ស្យូមឱ្យបានច្រើន គ្រប់គ្រាន់ដើម្បីធ្វើឱ្យ ឆ្អឹងរឹងមាំ លូតកម្ពស់ និងមានសុខភាពល្អ។ |
| ប្រូតេអ៊ីន | **ប្រភពពីសត្វ:** ជាទូទៅប្រូតេអ៊ីនច្រើនមាននៅក្នុងសាច់ ត្រី និងស៊ុត ។ល។  | ហេតុអ្វីបានជាប្រូតេអ៊ីនមានសារៈសំខាន់អំឡុងពេលពេញវ័យ? អំឡុងពេលពេញវ័យគឺមានការលូតលាស់យ៉ាងឆាប់រហ័ស ដូច្នេះ យើងត្រូវការចាំបាច់បរិភោគអាហារ |

| | | |
|---|---|---|
| | **ប្រភពពីរុក្ខជាតិៈ** ជាការល្អដែលអាចបរិភោគជាតិប្រូតេអ៊ីនពីសណ្តែក ផលិតផលធ្វើពីសណ្តែកនិងពីប្រភពផ្សេងទៀត។  | ដែលសម្បូរប្រូតេអ៊ីន ដើម្បីការលូតលាស់និងជួយទ្រទ្រង់រាងកាយ ទប់ទល់ប្រឆាំងនឹងជំងឺផ្សេងៗ។ |

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។

❖ **មេរៀនសង្ខេប**



អំឡុងពេលពេញវ័យ រាងកាយរបស់យើងត្រូវការចាំបាច់នូវសារជាតិចិញ្ចឹម សំខាន់ៗដូចជា កាល់ស្យូម ជាតិដែក និងប្រូតេអ៊ីន សម្រាប់ការលូតលាស់រាងកាយ និងមានសុខភាពល្អ។ ការបរិភោគអាហារដែលមានសារជាតិចិញ្ចឹមសំខាន់ៗ ដូចជា ជាតិដែក ជួយបង្កើតគ្រាប់ឈាមក្រហម និងជួយបញ្ជូនអុកស៊ីសែនទៅរាងកាយ។ កាល់ស្យូម ជួយធ្វើឱ្យឆ្អឹងរឹងមាំបាន រយៈពេលយូរ និងប្រូតេអ៊ីន ត្រូវការចាំបាច់សម្រាប់ការលូតលាស់រាងកាយ៕

## ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើសារជាតិចិញ្ចឹមសំខាន់ៗដែលត្រូវការពេលពេញវ័យមានអ្វីខ្លះ? មានមុខងារអ្វីខ្លះ?

២- តើសារជាតិដែក កាល់ស្យូម និងប្រូតេអ៊ីន មានសារៈសំខាន់ដូចម្តេចខ្លះ អំឡុងពេលពេញវ័យ?

## ៨- **លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរអ្នកបរិភោគអាហារដែលសម្បូរជាតិកាល់ស្យូម ជាតិដែក និងប្រូតេអ៊ីន សម្រាប់ការលូតលាស់ និងមានសុខភាពល្អ។

**កិច្ចការផ្ទះ**

១- ចូរអ្នកកត់ត្រាពីប្រភេទអាហារដែលត្រូវបរិភោគប្រចាំថ្ងៃនៅអំឡុងពេលពេញវ័យ។

២- ចូរមើលមេរៀនអនាម័យពេលពេញវ័យ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

**ឯកសារយោង**


1. https://www.sahealth.sa.gov.au/wps/wcm/connect/86349d0041d42230a601f7fc48414beb/Iron+and+Iron+Deficiency_Khmer
2. https://www.health.com.kh/archives/81289

# មេរៀនទី ២ : អនាម័យពេលពេញវ័យ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ពណ៌នាពីការធ្វើអនាម័យសម្រាប់មនុស្សស្រី និងប្រុស។ | • បង្ហាញពីការអនុវត្តអនាម័យនៅពេលពេញវ័យ សម្រាប់មនុស្សស្រី និងប្រុស។ | • យកចិត្តទុកដាក់អនុវត្តអនាម័យឱ្យបានជាប្រចាំ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- អនាម័យសម្រាប់មនុស្សស្រី : ការថែរក្សាអនាម័យជារឿងសំខាន់សម្រាប់ស្ត្រីគ្រប់រូបអំឡុងពេលមក រដូវ។ អំឡុងពេលមករដូវអ្នកមិនត្រូវប្រើប្រាស់សំឡីតែមួយក្នុងរយៈពេលយូរនោះទេនិងប្រើប្រាស់ទឹកស្អាតសម្រាប់លាងសម្អាតទ្វាមាសឱ្យស្អាតជានិច្ច...។
- អនាម័យសម្រាប់មនុស្សប្រុស : បុរសត្រូវការពិនិត្យសុខភាពទៀងទាត់ប្រចាំឆ្នាំ ដូចជាស្ត្រីដែរ ដើម្បីបង្ការទប់ស្កាត់ជាមុន និងព្យាបាលទាន់ពេលវេលានូវប្រភេទជំងឺផ្សេងៗ។

**៥- វិធីសាស្ត្រ**

ការសួរសំណួរ និងចម្លើយ ការធ្វើបទបង្ហាញរបស់សិស្ស ការងារជាដៃគូ ឬក្រុម។

**៦- សកម្មភាពបង្រៀន និងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការផ្ទះ។

  ២- តើនៅលើកមុនអ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស : ...

  ៣- តើអ្នកត្រូវការសារជាតិសំខាន់ៗមានអ្វីខ្លះ ក្នុងអំឡុងពេលពេញវ័យ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ចម្លើយ**

អំឡុងពេលពេញវ័យ រាងកាយរបស់យើងត្រូវការចាំបាច់នូវរបបអាហារ គ្រប់គ្រាន់ពិសេសអាហារដែលសម្បូរជាតិកាល់ស្យូម ជាតិដែក និងប្រូតេអ៊ីន សម្រាប់ការលូតលាស់និងមានសុខភាពល្អ។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : អនាម័យសម្រាប់មនុស្សស្រី**

- គ្រូពន្យល់សិស្ស៖ តើការមករដូវគឺជាអ្វី?

**ចម្លើយ**

ការមករដូវមានន័យថា រាងកាយរបស់ក្មេងស្រីកំពុងធ្វើការលូតលាស់ និងកំពុងត្រៀមខ្លួនសម្រាប់អនាគតរបស់នាង ពីព្រោះវាគឺជាពេលវេលាដែលនាងអាចពពោះ និងមានកូនបាន។ ក្នុងអំឡុងពេលមានរដូវ ស្រទាប់ភ្នាសសើមស្បូនត្រូវបានដាច់ចេញលាយឡំជាមួយនឹងឈាមដែលហូរចេញមកក្រៅខ្លួនតាមប្រដាប់ភេទរបស់ក្មេងស្រី។

- គ្រូបែងចែកសិស្សជាក្រុមពិភាក្សា សំណួរ: តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីថែរក្សាអនាម័យក្នុងអំឡុងពេលមករដូវ? គ្រូទុកពេល ៥ ទៅ១០នាទីឱ្យសិស្សពិភាក្សា។
  - តំណាងក្រុមឡើងរាយការណ៍និងបកស្រាយ
  - គ្រូសំយោគចម្លើយតាមខ្លឹមសារមេរៀន

**ចម្លើយ**

ការថែរក្សាអនាម័យជារឿងសំខាន់សម្រាប់មនុស្សស្រីគ្រប់រូបអំឡុងពេលមករដូវ។ ខាងក្រោមជាគន្លឹះមួយចំនួនដែលត្រូវអនុវត្ត៖

- ជ្រើសរើសសំឡីអនាម័យប្រភេទណាមួយតាមចំណូលចិត្ត តែអ្វីដែលសំខាន់អ្នកមិនគួរដូរប្រភេទសំឡីអនាម័យញឹកញាប់ពេក និងមិនហួសកាលបរិច្ឆេទប្រើប្រាស់
- មិនត្រូវប្រើប្រាស់សំឡីតែមួយក្នុងរយៈពេលយូរនោះទេ ព្រោះវាអាចបង្កបញ្ហា និងងាយឆ្លងរោគផ្សេងៗ គួរផ្លាស់ប្តូរសំឡីឱ្យបានញឹកញាប់ (២ ទៅ ៣ ម៉ោងម្តង)។
- សម្អាតទ្វារមាសឱ្យបានត្រឹមត្រូវ ឈាមរដូវអាចហូរទៅកន្លែងផ្សេងៗ ដែលចាំបាច់ត្រូវតែសម្អាតឱ្យបានស្អាតដោយប្រុងប្រយ័ត្ន និងទៀងទាត់នៅពេលអ្នកដូរសំឡីអនាម័យញឹកញាប់ វាក៏ជួយមិនឱ្យមានក្លិនផងដែរ។
- ប្រើប្រាស់ទឹកស្អាតសម្រាប់លាងសម្អាតទ្វារមាសពីមុខទៅក្រោយជានិច្ច ជាជម្រើសដ៏ល្អគួរប្រើទឹកក្តៅឧណ្ហៗដើម្បីសម្អាត។ ទោះយ៉ាងណាសាប៊ូអាចប្រើលាងសម្អាតផ្នែកខាងក្រៅបានដែរ។



ងូតទឹកសម្អាតរាងកាយ

- ត្រូវខ្ចប់សំឡីអនាម័យដែលប្រើរួចឱ្យបានត្រឹមត្រូវ ហើយដាក់ក្នុងធុងសំរាម បន្ទាប់មកត្រូវលាងដៃនឹងសាប៊ូឱ្យបានស្អាត។
- មិនត្រូវងូត ឬលេងទឹក ត្រពាំង ស្ទឹង ទន្លេ អូរ សមុទ្រ ។ល។

- គ្រូសួរ : តើការថែរក្សាអនាម័យក្នុងអំឡុងពេលមករដូវមានសារៈសំខាន់ដូចម្ដេចខ្លះ ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ចម្លើយ**

សារៈសំខាន់នៃការថែរក្សាអនាម័យពេលមករដូវមានដូចជា៖

- បង្ការការចម្លងរោគតាមប្រដាប់បន្តពូជ និងឆ្លងមេរោគតាមបង្ហូរនោម
- ការអនុវត្តវិធានការអនាម័យបានល្អ ធ្វើឱ្យមនុស្សស្រីមិនងាយរងគ្រោះនឹងភាពគ្មានកូនផងដែរ
- ធ្វើឱ្យមានទំនុកចិត្ត អារម្មណ៍ស្រស់ស្រាយ មិនមានការបារម្ភពីក្លិនមិនល្អ
- មិនអវត្តមាននៅសាលារៀន។



ការមករដូវនិងអនាម័យពេលមករដូវ

- គ្រូសួរ : តើការថែរក្សាអនាម័យសម្រាប់មនុស្សប្រុសមានសារៈសំខាន់ដូចម្ដេចខ្លះ ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ចម្លើយ**

ការធ្វើអនាម័យរបស់មនុស្សប្រុសអំឡុងពេលពេញវ័យមានសារៈសំខាន់ណាស់ ជាពិសេសបង្ការការឆ្លងរោគតាមប្រដាប់បន្តពូជ។យើងត្រូវអនុវត្តតាមវិធានការដូចខាងក្រោម៖

- ត្រូវងូតទឹកសម្អាតរាងកាយ និងសរីរាង្គបន្តពូជឱ្យបានស្អាត ដើម្បីការពារការឆ្លងមេរោគតាមប្រដាប់បន្តពូជ

- ត្រូវដុសលាងប្រដាប់បន្តពូជឱ្យបានស្អាតជានិច្ច ជាពិសេសត្រូវពន្លាត់ស្បែកគ្របក្បាលលិង្គ រួចដុសឱ្យបានស្អាត
- ត្រូវស្លៀកខោក្នុងដែលមិនរឹបខ្លាំងពេកទេ ជាពិសេសពេលគេង
- មានទំនុកចិត្ត អារម្មណ៍ស្រស់ស្រាយ មិនមានការបារម្ភពីក្លិនខ្លួនមិនល្អ។



ងូតទឹកសម្អាតរាងកាយ

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

អនាម័យមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងសុខភាពទូទៅរបស់មនុស្សគ្រប់រូប មិនថាស្រីឬប្រុសនោះទេ។ ការថែរក្សាអនាម័យជារឿងសំខាន់សម្រាប់មនុស្សគ្រប់រូបអំឡុងពេលមករដូវក្នុងការបង្ការនូវការចម្លងរោគតាមប្រដាប់បន្តពូជ។

ការធ្វើអនាម័យរបស់មនុស្សប្រុសអំឡុងពេលពេញវ័យមានសារៈសំខាន់ណាស់ ជាពិសេស បង្ការការឆ្លងរោគតាមប្រដាប់បន្តពូជ និងបំបាត់ក្លិនខ្លួនមិនល្អ។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើការអនុវត្តអនាម័យនៅពេលមករដូវមានសារៈសំខាន់អ្វីខ្លះ?

២- តើការអនុវត្តអនាម័យរបស់បុរសមានសារៈសំខាន់អ្វីខ្លះ?

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរអ្នកធ្វើអនាម័យខ្លួនប្រាណជាប្រចាំ ដើម្បីបង្ការការឆ្លងរោគតាមប្រដាប់បន្តពូជ និងបំបាត់ក្លិនខ្លួនមិនល្អ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនអនាម័យមាត់ធ្មេញ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : អនាម័យមាត់ធ្មេញ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីផលវិបាកនៃការកង្វះអនាម័យមាត់ធ្មេញ<br>• រៀបរាប់ពីការធ្វើអនាម័យមាត់ធ្មេញ។ | • បង្ហាញពីផលវិបាកនៃការកង្វះអនាម័យមាត់ធ្មេញ<br>• បង្ហាញពីរបៀបដុសសម្អាតធ្មេញបានត្រឹមត្រូវ។ | • បណ្តុះទម្លាប់អនុវត្តអនាម័យនិងដុសសម្អាតមាត់ធ្មេញឱ្យបានជាប្រចាំពិសេសមុនចូលដេក។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- សារៈប្រយោជន៍នៃការដុសសម្អាតមាត់ធ្មេញ មានដូចជា ការពារជំងឺពុកធ្មេញ និងពុំមានក្លិនមាត់ កាត់បន្ថយការឆ្លងជំងឺតាមមាត់ សោភ័ណភាពស្រស់ស្អាត ទំពារ អាហារបានម៉ដ្ឋល្អ និងបរិភោគអាហារមានរសជាតិឆ្ងាញ់។
- ផលវិបាកនៃកង្វះអនាម័យមាត់ធ្មេញ មានដូចជា អញ្ចាញធ្មេញមានជំងឺ និងមានក្លិនមាត់មិនល្អ ឆ្លងជំងឺផ្សេងៗតាមមាត់ បាត់បង់សោភ័ណភាព ការបញ្ចេញសំឡេងមិនបានត្រឹមត្រូវ ទំពារ អាហារមិនបានម៉ដ្ឋល្អ ចំណាយថវិកាច្រើនក្នុងការព្យាបាលធ្មេញ មិនបានទៅរៀនដោយសារឈឺធ្មេញ។
- អនាម័យមាត់ធ្មេញ យើងត្រូវដុសសម្អាតធ្មេញ ជាមួយថ្នាំដុសធ្មេញដែលមានកម្រិតជាតិភ្លុយអ៊រ៉ាយ ហើយដុសថ្នមៗស្រាលៗ និងអនុវត្តឱ្យបានយ៉ាងតិច ពីរដងក្នុងមួយថ្ងៃ និងអនុវត្តការដុសធ្មេញឱ្យបានត្រឹមត្រូវនិងជាប្រចាំ។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យនៅលើកមុន ? គ្រូប្រមូលកិច្ចការផ្ទះ។

២- តើនៅលើកមុន អ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។

ចម្លើយសិស្ស : ...

៣- តើប្អូនដុសសម្អាតធ្មេញប៉ុន្មានដងក្នុងមួយថ្ងៃ? គ្រូហៅសិស្ស២ឬ៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្ស...

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : សារៈប្រយោជន៍នៃការដុសសម្អាតមាត់ធ្មេញ**

- គ្រូសួរ: តើការដុសសម្អាតមាត់ធ្មេញមានសារៈប្រយោជន៍ដូចម្តេចខ្លះ? គ្រូទុកពេល ៣ នាទី ឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

ចម្លើយ: ការដុសសម្អាតធ្មេញឱ្យបានត្រឹមត្រូវ និងជាប្រចាំ គឺជាចំណែកមួយនៃការធ្វើអនាម័យខ្លួនប្រាណ។ ការដុសសម្អាតធ្មេញមានសារៈប្រយោជន៍៖

  - ការពារជំងឺពុកធ្មេញ និងកាត់បន្ថយការឆ្លងជំងឺតាមមាត់
  - បំបាត់ក្លិនមាត់ ធ្វើឱ្យយើងមានទំនុកចិត្តក្នុងការប្រាស្រ័យទាក់ទងគ្នា
  - បង្កើនសោភ័ណភាពស្រស់ស្អាត
  - ទំពាអាហារបានម៉ដ្ឋល្អ និងការបរិភោគអាហារមានរសជាតិឆ្ងាញ់
  - មិនចំណាយថវិកាទៅលើការព្យាបាលធ្មេញ និងទៅរៀនបានទៀងទាត់។


ទំពាអាហារបានម៉ដ្ឋល្អធ្មេញ


មានក្លិនមាត់ល្អ


បានទៅរៀនទៀងទាត់


ធ្មេញស្អាត

**ខ្លឹមសារ : ផលវិបាកនៃកង្វះអនាម័យមាត់ធ្មេញ**

គ្រូសួរសំណួរ៖

- តើអ្នកធ្លាប់ឈឺធ្មេញដែរឬទេ? ហេតុអ្វីបានជាធ្មេញអ្នកឈឺ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។
- គ្រូបែងចែកសិស្សជាក្រុមពិភាក្សារយៈពេល ៥ទៅ១០នាទី លើសំណួរ តើមានផលវិបាកអ្វីខ្លះប្រសិនបើមិនបានដុសសម្អាតធ្មេញ?
  - តំណាងក្រុមបង្ហាញលទ្ធផល
  - គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេបតាមខ្លឹមសារនៃមេរៀន។

**ចម្លើយ** : ផលវិបាកនៃការមិនដុសសម្អាតធ្មេញមានដូចជា៖

  - អញ្ចាញធ្មេញមានជំងឺ និងមានក្លិនមាត់មិនល្អ

- ឆ្លងជំងឺផ្សេងៗតាមមាត់ (អញ្ចាញធ្មេញ រលាកបំពង់ក រលាកផ្លូវដង្ហើម និងជំងឺដទៃផ្សេងទៀត)
- បាត់បង់សោភ័ណភាព និងការបញ្ចេញសំឡេងមិនបានត្រឹមត្រូវ
- ទំពារអាហារមិនបានម៉ដ្ឋល្អ និងបរិភោគអាហារមិនមានរសជាតិឆ្ងាញ់
- ចំណាយថវិកាច្រើនក្នុងការព្យាបាលធ្មេញ
- មិនបានទៅរៀន ដោយសារឈឺធ្មេញ។



ផលវិបាកនៃកង្វះអនាម័យមាត់ធ្មេញ

**ខ្លឹមសារ : អនាម័យមាត់ធ្មេញ**

- គ្រូសួរសំណួរបំផុស៖
  ១- តើអ្នកចង់បានធ្មេញស្អាតដែរឬទេ ?
  ២- តើអ្នកធ្វើដូចម្ដេចខ្លះ ដើម្បីឱ្យធ្មេញស្អាតល្អ ? គ្រូហៅសិស្ស២ ឬ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស
- គ្រូសំយោគ និងសម្របសម្រួលចម្លើយសិស្ស
- គ្រូបង្ហាញពីរូបផ្គុំនៃក្រាសធ្មេញ និងរបៀបដុសសម្អាតធ្មេញ



① ដាក់ច្រាសបញ្ឆិត ៤៥អង្សា ដុសពីលើចុះក្រោម (ធ្មេញលើ) ដុសពីក្រោមឡើង



② ដាក់ច្រាសនៅផ្នែកខាងក្នុងនៃធ្មេញ (ដោយប្រើបច្ចេកទេសដូចដំណាក់កាល



③ ដុសផ្ទៃទំពាខាងក្រោយមុខ



④ ប្រើចុងច្រាសដុសផ្ទៃទំពាខាងមុខ (ធ្មេញទាំងលើទាំងក្រោម)



⑤ កុំភ្លេចដុសអណ្ដាតរបស់អ្នកផង

- គ្រូឱ្យសិស្ស៣ ទៅ៥នាក់ឡើងមកអនុវត្ត
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេប តាមខ្លឹមសារនៃមេរៀនរួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅកិច្ចការ។



**មេរៀនសង្ខេប**

អនាម័យមាត់ធ្មេញ ក៏ជាកត្តាសំខាន់មួយ ដែលធ្វើអោយសម្រស់កាន់តែមានភាពស្រស់ស្អាតថែមមួយកម្រិតទៀតផងដែរ។ ការដុសសម្អាតធ្មេញមានសារៈប្រយោជន៍ដូចជា ការពារជំងឺពុកធ្មេញ និងពុំមានក្លិនមាត់ កាត់បន្ថយការឆ្លងជំងឺតាមមាត់ សោភ័ណភាពស្រស់ស្អាត ទំពារអាហារបានម៉ដ្ឋល្អ និងបរិភោគអាហារមានរសជាតិឆ្ងាញ់ និងមានសុខភាពទូទៅល្អប្រសើរ៕

### ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើការធ្វើអនាម័យមាត់ធ្មេញមានសារៈសំខាន់ដូចម្តេចខ្លះ?

២- តើផលវិបាកនៃកង្វះអនាម័យមាត់ធ្មេញមានអ្វីខ្លះ?

៣- ចូរប្អូនរៀបរាប់ពីរបៀបដុសសម្អាតធ្មេញឱ្យបានត្រឹមត្រូវ។

### ៨- លំហាត់ (ជំហានទី៥)

**បណ្តាំផ្ញើ**: ចូរប្អូនថែរក្សាធ្មេញរបស់ប្អូនឱ្យមានសុខភាពល្អ ដោយដុសសម្អាតធ្មេញយ៉ាងតិច ២ ដងក្នុងមួយថ្ងៃ ពិសេសពេលចូលគេង។

**កិច្ចការផ្ទះ** : ចូរប្អូនមើលមេរៀនការវាស់គំហើញសម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការវាស់គំហើញ

## ខ្លឹមសារម៉ោងទី១ : ស្ថានភាពនៃបញ្ហាភ្នែក និងសារៈសំខាន់នៃការវាស់គំហើញ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីស្ថានភាពបញ្ហាភ្នែក<br>• រៀបរាប់ពីសារៈសំខាន់នៃការវាស់គំហើញ។ | • បង្ហាញពីវិធីសាស្ត្រ និងសារៈសំខាន់នៃការវាស់គំហើញ។ | • ចូលរួមអនុវត្តការវាស់គំហើញ និងស្វែងរកសេវាពិនិត្យ និងព្យាបាលភ្នែកត្រឹមត្រូវ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- ***ស្ថានភាពនៃបញ្ហាភ្នែក*** : នៅលើពិភពលោក អ្នកឯកទេសបានរកឃើញថា បញ្ហាកំហុសកំណុំរូបភាព ជាមូលហេតុចម្បងដែលបណ្ដាលឱ្យគំហើញចុះខ្សោយ ចំពោះកុមារដែលមានអាយុចាប់ពី ៥ ដល់ ១៥ឆ្នាំ។ យោងតាមការសិក្សាជាច្រើន កុមារនៅតាមសាលារៀន ដែលមានបញ្ហាកំហុសកំណុំ រូបភាពបណ្ដាលឱ្យភ្នែកមីញ៉ូបជាមូលហេតុចម្បង នាំឱ្យមានបញ្ហាគំហើញចុះខ្សោយ។
- ***សារៈសំខាន់នៃការវាស់គំហើញ*** ដើម្បីកំណត់បាននូវគំហើញធម្មតា ឬខ្សោយ ទទួលបាននូវការព្យាបាលបានទាន់ពេលវេលា ទទួលបាននូវគំហើញធម្មតាវិញដោយការប្រើវ៉ែនតា និងមិនធ្វើឱ្យភ្នែកកាន់តែមានបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការផ្ទះ។

២- តើនៅសប្ដាហ៍មុនអ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ហៅសិស្ស ២-៣នាក់ឱ្យឆ្លើយ ។ ចម្លើយសិស្ស : ...។

៣- តើអ្នកអាចមើលឃើញដោយសារអ្វី? តើភ្នែកអាចមើលឃើញអ្វីខ្លះ? គ្រូទុកពេល ២នាទីឱ្យសិស្ស

គិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : *ស្ថានភាពទូទៅនៃបញ្ហាភ្នែក***

- គ្រូពន្យល់ពីស្ថានភាពទូទៅនៃភ្នែក : នៅលើពិភពលោក អ្នកឯកទេសបានរកឃើញថា បញ្ហាកំហុសកំណុំរូបភាព ជាមូលហេតុចម្បងដែលបណ្តាលឱ្យគំហើញចុះខ្សោយ ចំពោះកុមារដែលមានអាយុចាប់ពី៥ដល់១៥ឆ្នាំ។ យោងតាមការសិក្សាជាច្រើន កុមារនៅតាមសាលារៀន ដែលមានបញ្ហាកំហុសកំណុំរូបភាពបណ្តាលឱ្យភ្នែកមីញ៉ូបជាមូលហេតុចម្បង នាំឱ្យមានបញ្ហាគំហើញចុះខ្សោយ។
- គ្រូសួរ៖
  - តើអ្នកធ្លាប់មើលអក្សរមិនច្បាស់ ឬពិបាកមើលដែរឬទេ? ហេតុអ្វី?
  - តើការវាស់គំហើញមានន័យដូចម្តេច? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ចម្លើយ**

គំហើញ គឺជាសមត្ថភាពនៃភ្នែកដែលអាចមើលឃើញ និងអាចកំណត់ចំណុចមួយស្ថិតក្នុងចម្ងាយមួយដែលបានកំណត់ជាក់លាក់។

**ខ្លឹមសារ : *សារៈសំខាន់នៃការវាស់គំហើញ***

- គ្រូសួរសំណួរ : តើការវាស់គំហើញមានសារៈសំខាន់ដូចម្តេចខ្លះ?
- គ្រូចែកក្រដាសតូចម្នាក់១សន្លឹកឱ្យទៅសិស្ស រួចទុកពេល៣ ទៅ៥នាទី ឱ្យសរសេរចម្លើយម្នាក់១ដាក់លើក្រដាស។ បន្ទាប់មកឱ្យសិស្សយកចម្លើយបិទលើក្តារខៀន។
  - គ្រូសម្របសម្រួល និងសំយោគចម្លើយសិស្ស។

**ចម្លើយ**

ការវាស់គំហើញមានសារៈសំខាន់មានដូចជា កំណត់បាននូវគំហើញធម្មតា ឬខ្សោយ ទទួលបាននូវការព្យាបាលបានទាន់ពេលវេលា ទទួលបាននូវគំហើញធម្មតាវិញដោយការប្រើវ៉ែនតា និងមិនធ្វើឱ្យភ្នែកកាន់តែមានបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។

**មេរៀនសង្ខេប**



បញ្ហាកំហុសកំណុំរូបភាព ជាមូលហេតុចម្បងដែលបណ្តាលឱ្យគំហើញចុះខ្សោយ ចំពោះកុមារដែលមានអាយុចាប់ពី ៥ ដល់ ១៥ឆ្នាំ។ ការវាស់គំហើញមានសារៈសំខាន់ដូចជា កំណត់បាននូវគំហើញធម្មតា ឬខ្សោយ ទទួលបាននូវការព្យាបាលបានទាន់ពេលវេលា ទទួលបាននូវគំហើញធម្មតាវិញដោយការប្រើវ៉ែនតា និងមិនធ្វើឱ្យភ្នែកកាន់តែមានបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើការវាស់គំហើញមានន័យដូចម្ដេច?

២- តើការវាស់គំហើញមានសារៈសំខាន់អ្វីខ្លះ?

**៨- លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកថែរក្សាភ្នែកឱ្យបានល្អ និងប្រាប់ទៅក្រុមគ្រួសារពីសារៈសំខាន់នៃការថែរក្សាភ្នែក។

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវពីវិធីសាស្ត្រនៃការវាស់គំហើញ តាមរយៈការមើលមេរៀនបន្ទាប់ និងសាកសួរពីក្រុមគ្រួសារ ឬអ្នកដឹងពីការវាស់គំហើញ គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការវាស់គំហើញ (ត)

## ខ្លឹមសារម៉ោងទី២ : ការវាស់គំហើញ (វិធីសាស្ត្រនៃការវាស់គំហើញ)

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីការវាស់គំហើញ។ | • បង្ហាញពីវិធីសាស្ត្រនៃការវាស់គំហើញ។ | • ចូលរួមអនុវត្តការវាស់គំហើញ និងស្វែងរកសេវាពិនិត្យ និងព្យាបាលភ្នែកត្រឹមត្រូវ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**ការវាស់គំហើញ (វិធីសាស្ត្រនៃការវាស់គំហើញ)** : យើងប្រើប័ណ្ណវាស់គំហើញសម្រាប់ជាខ្នាតវាស់សមត្ថភាពមើលឃើញរបស់ភ្នែក ដែលប័ណ្ណនោះមានជាលេខ អក្សរ ឬសញ្ញាដែលមានទំហំ និងចម្ងាយកំណត់ជាក់លាក់។

**វិធីសាស្ត្រនៃការវាស់គំហើញមានដូចតទៅ៖**

- រកទីតាំងដាក់ផ្ទាំងវាស់គំហើញនៅទីតាំងដែលមានពន្លឺច្បាស់ល្អ ( មិនមានចំណាំងផ្លាត ពន្លឺ )
- ធ្វើការកំណត់ចម្ងាយ ៣ម៉ែត្រពីទីតាំង ដែលយើងឈរ ឬអង្គុយអានប័ណ្ណអក្សរ អ៊ី (E) ។ របៀបឆ្លើយតបនៅពេលប្រើប្រាស់ផ្ទាំងអក្សរ អ៊ី ដោយយកអ៊ីទោលមកបង្ហាញជាឧទាហរណ៍ តើអក្សរ អ៊ី (E) បែរទៅទិសខាងណា ? ( លើ ក្រោម ឆ្វេង ស្តាំ )
- របៀបគ្របភ្នែក ត្រូវយករបាំងភ្នែកគ្របភ្នែកខាងឆ្វេងជាមុនឱ្យជិត តែមិនត្រូវសង្កត់លើគ្រាប់ភ្នែកទេ ហើយត្រូវវាស់ភ្នែកខាងស្តាំមុន រួចទើបវាស់ភ្នែកខាងឆ្វេងវិញ ដោយយករបាំងភ្នែកគ្របភ្នែកខាងស្តាំវិញម្តង។
- ឱ្យកុមារឆ្លើយទិសជើងអក្សរ អ៊ី ម្តងមួយទិស ឱ្យបានទាំងបួនទិសហើយកត់ត្រា
- ករណីកុមារមានពាក់វ៉ែនតា ត្រូវវាស់ដោយពាក់វ៉ែនតា។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលអ្នកគ្រូ/លោកគ្រូបានដាក់ឱ្យនៅសប្តាហ៍មុន ? គ្រូប្រមូលកិច្ចការផ្ទះ។

២- តើនៅសប្តាហ៍មុន អ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស : ...

៣- តើការវាស់គំហើញមានន័យដូចម្តេច ?

ចម្លើយៈ ការវាស់គំហើញ គឺជាសមត្ថភាពនៃភ្នែកដែលអាចមើលឃើញ និងអាចកំណត់ចំណុចមួយស្ថិតក្នុងចម្ងាយមួយដែលបានកំណត់ជាក់លាក់។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ការវាស់គំហើញ**

គ្រូសួរសំណួរ៖

- តើអ្នកណាខ្លះមើលអក្សរពុំសូវឃើញ ? ( សូមលើកដៃ )
- តើអ្នកចង់វាស់គំហើញដែរឬទេ ? ចម្លើយសិស្ស......
- គ្រូបង្ហាញពីសម្ភារៈសម្រាប់វាស់គំហើញ





- គ្រូពន្យល់ពីរបៀបឆ្លើយទិសដៅជើងអក្សរ អ៊ី ( លើ ក្រោម ឆ្វេង ស្តាំ ) ម្តងមួយទិសឱ្យបានទាំងបួនទិស។

គ្រូអនុវត្តការវាស់គំហើញសិស្សទាំងអស់ ដោយត្រូវរៀបចំសម្ភារៈសម្រាប់ពិនិត្យការវាស់គំហើញសិស្សទាំងអស់ដូចក្នុងតារាងខាងក្រោម៖

| | |
|---|---|
| ១. | គ្រូហៅឈ្មោះសិស្សម្តងម្នាក់ៗតាមបញ្ជីឈ្មោះសិស្ស មកធ្វើការវាស់ភ្នែក រីឯសិស្សដទៃរក្សាភាពស្ងៀមស្ងាត់។ |
| ២. | ត្រូវវាស់ភ្នែកស្តាំមុន ត្រូវឱ្យសិស្សគ្របភ្នែកខាងឆ្វេងដោយប្រើបាំងភ្នែក ពេលរួចហើយវាស់ភ្នែកឆ្វេងវិញម្តងដោយឱ្យសិស្សគ្របភ្នែកខាងស្តាំវិញ |

| | |
|---|---|
| ៣. | ដើម្បីធានាចម្ងាយឱ្យមានសុក្រឹតភាពបណ្ណអក្សរអ៊ី (E) ត្រូវដាក់បង្ហាញជាប់ក្ដារខៀន ឬជញ្ជាំងដែលមានចម្ងាយ ៣ម៉ែត្រ ពីទីតាំងដែលសិស្សឈរ ឬអង្គុយ |
| ៤. | • ឱ្យសិស្សឆ្លើយទិសដៅជើងអក្សរអ៊ី ទំហំ ៦/៦០ ម្ដងមួយទិសៗឱ្យបានទាំងបួនទិស ហើយកត់ត្រា។ បន្ទាប់មកឱ្យសិស្សឆ្លើយទិសដៅនៃជើងអក្សរ៦/១២ ដែលមាន ៥អក្សរ ( ទាំង៥អក្សរ )មួយម្ដងៗ ហើយកត់ត្រាឱ្យបានជាក់លាក់។<br>• ករណីសិស្សមានពាក់វ៉ែនតាត្រូវវាស់ដោយពាក់វ៉ែនតា។ |













ប្រភេទបណ្ណវាស់គំហើញផ្សេងទៀត និងវិធីវាស់គំហើញ

**ចំណាំ៖**

**គំហើញធម្មតា៖**

- សិស្សអាចមើលឃើញអក្សរ អ៊ី (E) តូច ( ទំហំ ៦/១២ ដែលមាន ៥អក្សរ ) បានចាប់ពីបួន អក្សរឡើងដោយភ្នែកម្ខាង។
- សិស្សអាចមើលឃើញអក្សរ អ៊ី (E) ធំ ( ទំហំ ៦/៦០) បានទាំងបួនជ្រុង (ទិស) អក្សរដោយភ្នែកម្ខាង។

**ខ្សោយគំហើញ៖**

- សិស្សមិនអាចមើលឃើញអក្សរ អ៊ី (**E**) តូច ( ទំហំ ៦/១២ ដែលមាន ៥អក្សរ ) ច្រើនជាងបី អក្សរដោយភ្នែកម្ខាងបាន មានន័យថា សិស្សមានបញ្ហាខ្សោយគំហើញ កម្រិតទាបទៅមធ្យម ត្រូវជូនដំណឹងទៅឪពុក ម្តាយ ឬអ្នកអាណាព្យាបាលពួកគេ ដើម្បីបញ្ជូនទៅជួបអ្នកឯកទេសខាងភ្នែកធ្វើការពិនិត្យបន្ត។
- សិស្សមិនអាចមើលឃើញអក្សរ អ៊ី (**E**) ធំ ( ទំហំ ៦/៦០ ) បានទាំងបួនជ្រុង ( ទិស ) អក្សរដោយភ្នែកម្ខាង មានន័យថា សិស្សមានបញ្ហាខ្សោយគំហើញ កម្រិតធ្ងន់ធ្ងរ។ ត្រូវជូនដំណឹង ទៅឪពុក ម្តាយ ឬអ្នកអាណាព្យាបាលពួកគេ ដើម្បីប្រញាប់បញ្ជូនទៅជួបអ្នកឯកទេសខាងភ្នែកជាបន្ទាន់។
- សរសេរខ្នាតនៃតារាងអក្សរ **E**

- គ្រូឱ្យសិស្សសង្កេតមើលសកម្មភាពក្នុងការអនុវត្តការវាស់គំហើញសិស្ស
- ឱ្យសិស្សដែលបានវាស់ភ្នែករួចជួយអនុវត្តបន្ត (ម្នាក់ហៅឈ្មោះតាមបញ្ជីឈ្មោះម្នាក់កត់ត្រាលទ្ធផល ម្នាក់ជាអ្នកចង្អុលអក្សរ **E** )



៦/៦០



៦/១២




**ឧបសម្ព័ន្ធ៖**

- បញ្ជីរាយនាមឈ្មោះសិស្ស (គ្រូមានស្រាប់)
- កំណត់ត្រាលទ្ធផលការវាស់គំហើញសិស្សម្នាក់ៗ (ជាគំរូលើក្រដាសផ្ទាំងធំ)

## កំណត់ត្រាលទ្ធផលការវាស់គំហើញសិស្ស

ឈ្មោះសិស្ស.......................អាយុ.................ភេទ..................................................

| ភ្នែកស្តាំ | | ភ្នែកឆ្វេង | | បញ្ជូន | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| ៦/៦០ | ៦/១២ | ៦/៦០ | ៦/១២ | | |
| □ធម្មតា<br>□ខ្សោយគំហើញ | □ធម្មតា<br>□ខ្សោយគំហើញ | □ធម្មតា<br>□ខ្សោយគំហើញ | □ធម្មតា<br>□ខ្សោយគំហើញ | | |

## របាយការណ៍នៃការវាស់គំហើញសិស្ស

សិស្សថ្នាក់ទីចំនួន ..........ខេត្ត.............ស្រុក...........ឃុំ.............ភូមិ....................សាលា..................
........ស្រី .......................នាក់ ចំនួនសិស្សបានវាស់គំហើញសរុប.............នាក់ ស្រី...........សិស្ស
ថ្ងៃ.............ឆ្នាំ.......................ខែ..........................
ឈ្មោះគ្រូប្រចាំថ្នាក់....................................លេខទូរស័ព្ទ................................

| លរ | ឈ្មោះសិស្ស | ភេទ | អាយុ | ភ្នែកស្តាំ | | ភ្នែកឆ្វេង | | បញ្ជូន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|---|---|
| | | | | ៦/៦០ | ៦/១២ | ៦/៦០ | ៦/១២ | | |
| ១ | | | | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយ □ គំហើញ | | |
| ២ | | | | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយ □ គំហើញ | | |
| ៣ | | | | □ធម្មតា<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយគំហើញ □ | ធម្មតា □<br>ខ្សោយ □ គំហើញ | | |

## លិខិតជូនដំណឹង

នាងខ្ញុំស្ថិតនៅក្នុងភូមិ....................នៃសាលា......................ជាគ្រូថ្នាក់ទី.................................ខ្ញុំបាទឈ្មោះ/ ។...........................................................ខេត្ត.............ស្រុក...........ឃុំ.............

## សូមជម្រាបជូន

លោកនៃសាលា............រៀននៅថ្នាក់ទី..........................លោកដែលជាអាណាព្យាបាលសិស្សឈ្មោះ
ឱ្យបានជ្រាបថា ........................ខេត្ត.............ស្រុក...........ឃុំ.............ស្ថិតនៅក្នុងភូមិ....................

បន្ទាប់ពីបានធ្វើការវាស់គំហើញ បានរកឃើញថាកុមារដែលមានឈ្មោះខាងលើ មានបញ្ហាខ្សោយគំហើញដែលតម្រូវឱ្យមានការត្រួតពិនិត្យពីគ្រូពេទ្យជំនាញខាងភ្នែកនៅមន្ទីរពេទ្យ .........
។.................................................................

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកស្រី/ លោក ដែលជាអ្នកអាណាព្យាបាល មេត្តាជូន កុមារទៅជួបគ្រូពេទ្យភ្នែកកុំបីខាន។............................................................

ថ្ងៃ.........ឆ្នាំ................ខែ...................

ហត្ថលេខានាយកសាលា　　　　　　ហត្ថលេខាគ្រូប្រចាំថ្នាក់



**មេរៀនសង្ខេប**

វិធីសាស្ត្រនៃការវាស់គំហើញមានដូចជា រកទីតាំងដាក់ផ្ទាំងវាស់គំហើញដោយកំណត់ចម្ងាយ ៣ម៉ែត្រពីទីតាំង ដែលយើងឈរ ការគ្របភ្នែកត្រូវយករបាំងភ្នែកគ្របភ្នែកខាងឆ្វេងជាមុនឱ្យជិត ត្រូវវាស់ភ្នែកខាងស្តាំមុន រួចទើបវាស់ភ្នែកខាងឆ្វេង ករណីកុមារមានពាក់វ៉ែនតា ត្រូវវាស់ដោយពាក់វ៉ែនតា។

### ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីវិធីសាស្ត្រនៃការវាស់គំហើញ។

### ៨- **លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ**: ចូរថែរក្សាភ្នែករបស់ប្អូនឱ្យបានល្អ កុំមើលសៀវភៅជិតពេក មើលទូរស័ព្ទយូរពេក...។

**កិច្ចការផ្ទះ** :

១- ចូរអ្នករៀបរាប់ពីទំហំលេខប៉ុន្មាន ដែលខ្សោយគំហើញធ្ងន់ធ្ងរ ខ្សោយគំហើញមធ្យម និងភ្នែកធម្មតា។

២- ចូរអ្នកមើលខ្លឹមសារមេរៀនត្រង់ចំណងជើង ការស្វែងរកសេវាពិនិត្យ និងព្យាបាលភ្នែកសម្រាប់រៀននៅម៉ោងអប់រំសុខភាពសប្តាហ៍ក្រោយ។

# មេរៀនទី ២ : ការវាស់គំហើញ ( តចប់ )

## ខ្លឹមសារម៉ោងទី៣ : ការស្វែងរកសេវាពិនិត្យ និងព្យាបាលភ្នែក

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងអាចមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីទីកន្លែងផ្តល់សេវាពិនិត្យ និងព្យាបាលភ្នែក។ | • បង្ហាញពីទីកន្លែងផ្តល់សេវាពិនិត្យ និងព្យាបាលភ្នែក។ | • ចូលរួមអនុវត្តការវាស់គំហើញ និងស្វែងរកសេវាពិនិត្យនិងព្យាបាលភ្នែកត្រឹមត្រូវ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**ការស្វែងរកសេវាពិនិត្យ និងព្យាបាលភ្នែក** : បន្ទាប់ពីវាស់គំហើញរួចហើយ ក្នុងករណីមើលអក្សរអឺ ធំ ( ទំហំ៦/៦០ ) ឬអក្សរអឺ តូច ( ទំហំ៦/១២ ) មិនឃើញអក្សរអឺនៅជួរទី២ ត្រូវប្រញាប់ទៅរកអ្នកឯកទេសខាងភ្នែកជាបន្ទាន់។ ករណីចាំបាច់ដូចជា របួសភ្នែក មានវត្ថុចូលភ្នែក ភ្នែកក្រហម ត្រូវប្រញាប់ទៅរកអ្នកឯកទេសខាងភ្នែកជាបន្ទាន់មិនចាំបាច់វាស់ភ្នែកឡើយ។

**៥- វិធីសាស្រ្ត**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យ? ចម្លើយសិស្ស : ......
  - ៣- ថ្ងៃនេះយើងនឹងអនុវត្តការវាស់គំហើញអ្នកដែលមិនទាន់បានវាស់បន្តទៀត។ តើប្អូនចាំបានទេថាមានសម្ភារៈអ្វីខ្លះសម្រាប់វាស់គំហើញ? យើងវាស់គំហើញដូចម្តេច?
  - ៤- នៅពេលដែលប្អូនខ្សោយគំហើញ តើប្អូនត្រូវធ្វើដូចម្តេច? ចម្លើយសិស្ស : ......

- គ្រូសំយោគចម្លើយ
- គ្រូឱ្យសិស្សដែលបានវាស់ភ្នែករួចជួយអនុវត្តបន្ត (ម្នាក់ហៅឈ្មោះតាមបញ្ជីឈ្មោះ ម្នាក់កត់ត្រាលទ្ធផល ម្នាក់ជាអ្នកចង្អុលអក្សរ E ) គ្រូរៀបចំរបាយការណ៍ លិខិតជូនដំណឹង និងលិខិតបញ្ជូនដែលបានត្រៀមរួច។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ការស្វែងរកសេវាពិនិត្យ និងព្យាបាលភ្នែក**

**សំណួរពិភាក្សា:**

- គ្រូបែងចែកសិស្សជាក្រុមពិភាក្សារយៈពេល ៥ ទៅ៧នាទី លើសំណួរ តើអ្នកស្គាល់កន្លែងផ្តល់សេវាពិនិត្យ និងព្យាបាលភ្នែកនៅទីណាខ្លះ ?
- តំណាងក្រុមបង្ហាញលទ្ធផល
- គ្រូសម្រេបសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ**

ការស្វែងរកសេវាពិនិត្យ និងព្យាបាលភ្នែកអាចរកបានតាមទីតាំងខាងក្រោម៖

| លរ | ឈ្មោះខេត្ត | ឈ្មោះ និងទីតាំងសំខាន់ៗនៃសេវាព្យាបាលភ្នែក |
|---|---|---|
| ១ | សៀមរាប | មន្ទីរពេទ្យបង្អែកខេត្តសៀមរាប ក្រុងសៀមរាប |
| ២ | កំពង់ធំ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ ក្រុងស្ទឹងសែន |
| ៣ | កំពង់ឆ្នាំង | មន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង |
| ៤ | កំពង់ស្ពឺ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ ក្រុងច្បារមន |
| ៥ | ឧត្តរមានជ័យ | មន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ ក្រុងសំរោង |
| ៦ | ព្រះវិហារ | មន្ទីរពេទ្យបង្អែក១៦ មករា ក្រុងព្រះវិហារ |
| ៧ | ប៉ៃលិន | មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន ក្រុងប៉ៃលិន |
| ៨ | ព្រៃវែង | មន្ទីរពេទ្យបង្អែកអ្នកលឿង |
| ៩ | កណ្តាល | មន្ទីរពេទ្យបង្អែកជ័យជំនះ ក្រុងតាខ្មៅ |
| ១០ | កំពត | មន្ទីរពេទ្យបង្អែកខេត្តកំពត ក្រុងកំពត |
| ១១ | បាត់ដំបង | មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ក្រុងបាត់ដំបង |
| ១២ | ពោធិ៍សាត់ | មន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់ ក្រុងពោធិ៍សាត់ |
| ១៣ | បន្ទាយមានជ័យ | មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា ជប៉ុនមង្គលបុរី ក្រុងមង្គលបុរី |
| ១៤ | កំពង់ចាម | មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម ក្រុងកំពង់ចាម |
| ១៥ | ត្បូងឃ្មុំ | មន្ទីរពេទ្យបង្អែកខេត្តត្បូងឃ្មុំ ក្រុងសួង |
| ១៦ | ស្វាយរៀង | មន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង ក្រុងស្វាយរៀង |
| ១៧ | ក្រចេះ | មន្ទីរពេទ្យបង្អែកខេត្តក្រចេះ ក្រុងក្រចេះ |
| ១៨ | ស្ទឹងត្រែង | មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង ក្រុងស្ទឹងត្រែង |
| ១៩ | ព្រះសីហនុ | មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ ក្រុងព្រះសីហនុ |

| | | |
|---|---|---|
| ២០ | មណ្ឌលគីរី | មន្ទីរពេទ្យបង្អែកសែនមនោរម្យ ក្រុងសែនមនោរម្យ |
| ២១ | រតនៈគីរី | មន្ទីរពេទ្យបង្អែកខេត្តរតនៈគីរី ក្រុងបានលុង |
| ២២ | តាកែវ | មន្ទីរពេទ្យភ្នែកតាកែវ ក្រុងដូនកែវ |
| ២៣ | រាជធានីភ្នំពេញ | ១. មន្ទីរពេទ្យព្រះអង្គឌួង ២. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត<br>៣. មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ ៤. មន្ទីរពេទ្យព្រះកេតុមាលា<br>៥. មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មជនពិការកៀនឃ្លាំង និង<br>៦. មន្ទីរពេទ្យកាល់ម៉ែត |




ពេទ្យភ្នែកនៅរាជធានីភ្នំពេញនិងតាមបណ្តាខេត្ត

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ប្រសិនបើអ្នកមានបញ្ហាភ្នែក សូមប្រញាប់រួសរាន់ទៅពិនិត្យភ្នែក នៅមន្ទីរពេទ្យភ្នែកដែលមានទីតាំងជិតកន្លែងរស់នៅ។ សូមកុំទិញថ្នាំប្រើប្រាស់មុនពេលពិនិត្យភ្នែក និងការគោរពតាមវេជ្ជបញ្ជារបស់គ្រូពេទ្យគឺជាការយកចិត្តទុកដាក់ថែរក្សាភ្នែករបស់អ្នក។

## ៧- **វាយតម្លៃ** (ជំហានទី៤)

១- គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីទីតាំងនៃសេវាពិនិត្យ និងព្យាបាលភ្នែកដែលមាននៅក្នុងប្រទេសកម្ពុជា

២- គ្រូដឹកនាំសិស្សច្រៀង **ការថែទាំភ្នែក** (លំនាំបទឱផ្កាយលើមេឃ)

I. មួយ ពីរ បី បួន ប្រាំគឺជាក្បួនការពារនេត្រា
មួយត្រូវតែញាំប្រចាំជាតិអា ពីរត្រូវរក្សានូវអនាម័យ
ពីរត្រូវរក្សានូវអនាម័យ។

II. បីកុំទស្សនា ឬអានអក្សរជិតឆ្ងាយពេកថ្លៃ
រកពន្លឺគ្រប់ទោះយប់ឬថ្ងៃ ត្រូវចេះកែខៃឱ្យល្មមកុំហួស
ត្រូវចេះកែខៃឱ្យល្មមកុំហួស។

III. ទី៤នោះថា ត្រូវតែបង្ការកុំឱ្យរបួស
មកលើគ្រាប់ភ្នែកវាអាចជ្រុលហួស ប្រុងប្រយ័ត្នខ្ពស់ផុតគ្រោះបន្ទាន់
ប្រុងប្រយ័ត្នខ្ពស់ផុតគ្រោះបន្ទាន់។

IV. រីប្រាំសោតណា បើមានបញ្ហាប្រញាប់រួសរាន់
ឱ្យពេទ្យពិនិត្យឆាប់ពិតជាទាន់ ចាំកុំបីភាន់មានប្រាំប្រការ
ចាំកុំបីភាន់មានប្រាំប្រការ។

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរអ្នកថែទាំភ្នែកឱ្យបានល្អ ហើយប្រសិនបើមានបញ្ហាភ្នែកត្រូវប្រាប់ឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ដើម្បីឱ្យគាត់ជូនទៅរកសេវាពិនិត្យ និងព្យាបាលភ្នែក។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការពុលអាហារ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ការពុលអាហារ

## ខ្លឹមសារម៉ោងទី១ : និយមន័យ និងមូលហេតុនៃការពុលអាហារ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ ការពុលអាហារ<br>• ពណ៌នាពីមូលហេតុនៃការពុលអាហារ។ | • បង្ហាញពីមូលហេតុនៃការពុលអាហារ<br>• កត់សម្គាល់ចំណីអាហារដែលងាយបង្កការពុលអាហារ។ | • បណ្តុះទម្លាប់បរិភោគមានអនាម័យ បង្ការការពុលអាហារ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- និយមន័យៈ ការពុលចំណីអាហារ គឺបណ្តាលមកពីអាហារនិងទឹកដែលមានមេរោគដោយសារបាក់តេរី វីរុស និងសាធាតុពុលដទៃទៀត ហើយតាមរយៈការបរិភោគអាហារ និងផឹកទឹកដែលមានមេរោគទាំងនេះ មនុស្សនឹងអាចឈឺ ឬស្លាប់បានក្នុងករណីពុលអាហារធ្ងន់ធ្ងរ។
- មូលហេតុៈ ការពុលចំណីអាហារ បង្កឡើងដោយអាហារនិងទឹកដែលមានមេរោគ។ កត្តាធំៗបួនដែលធ្វើឱ្យមានការពុលអាហារមានដូចជា អតិសុខុមប្រាណ (វីរុស និងបាក់តេរី) សារធាតុគីមី ជាតិពុលពីធម្មជាតិ (ពីរុក្ខជាតិ និងសត្វ) និងប៉ារ៉ាស៊ីត។ ខាងក្រោមនេះ គឺជារបៀបនៃការចម្លងមេរោគពីអាហារ និងទឹក៖

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យ? ចម្លើយសិស្ស : ......

៣- តើអ្នក ឬគ្រួសារអ្នកធ្លាប់ពុលអាហារដែរឬទេ ?

៤- តើការពុលអាហារមានអាការៈដូចម្ដេចខ្លះ ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : និយមន័យនៃការពុលអាហារ**

- គ្រូសួរៈ តើការពុលចំណីអាហារមានន័យដូចម្ដេច ? គ្រូឱ្យសិស្ស២ ឬ៣ នាក់ឆ្លើយ
- គ្រូសម្រេបសម្រួល និងសំយោគចម្លើយ។

**ចម្លើយ**

ការពុលចំណីអាហារ គឺបណ្ដាលមកពីអាហារ និងទឹកដែលមានមេរោគដោយសារ បាក់តេរី វីរុស និង សាធាតុពុលដទៃទៀត ហើយតាមរយៈការបរិភោគអាហារ និងផឹកទឹកដែលមានមេរោគទាំងនេះ មនុស្សនឹងអាចឈឺ ឬស្លាប់បានក្នុងករណីពុលអាហារធ្ងន់ធ្ងរ។

**ខ្លឹមសារ : មូលហេតុនៃការពុលអាហារ**

- គ្រូសួរ : តើអ្វីខ្លះដែលធ្វើឱ្យយើងពុលអាហារ ?  តើការពុលអាហារមានរោគសញ្ញាដូចម្ដេចខ្លះ ?
- គ្រូឱ្យសិស្សសរសេរចម្លើយដាក់លើក្រដាសតូចដែលបានចែករួចមកបិទលើក្ដារខៀន
- ឱ្យសិស្សសង្កេតមើលចម្លើយបើដូចគ្នាដកចេញរក្សាទុកតែ១
- គ្រូប្រមូលផ្ដុំចម្លើយតាមប្រភេទ (បន្លែ ផ្លែឈើ អាហារ ភេសជ្ជៈ ថ្នាំសម្លាប់សត្វល្អិត ឱសថផ្សេងៗ)
- គ្រូបែកចែកសិស្សជាក្រុមពិភាក្សារយៈពេល៥ ទៅ១០នាទី លើសំណួរៈ
  - តើមូលហេតុអ្វីខ្លះ ដែលនាំឱ្យពុលអាហារ ?
  - តើរោគសញ្ញាដែលបណ្ដាលមកពីការពុលអាហារមានដូចម្ដេចខ្លះ ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្រេបសម្រួល សំយោគចម្លើយ ដោយលើកយករូបភាព" របៀបនៃការចម្លងមេរោគពីអាហារ និងទឹក" មកបង្ហាញ។

**ចម្លើយ**

ការពុលចំណីអាហារ បង្កឡើងដោយអាហារ និងទឹកដែលមានមេរោគ។ កត្តាធំៗបួនដែលធ្វើឱ្យមានការពុលអាហារ មានដូចជាអតិសុខុមប្រាណ (វីរុសនិងបាក់តេរី) សារធាតុគីមី ជាតិពុលពីធម្មជាតិ ( ពីរុក្ខជាតិនិងសត្វ)  និងប៉ារ៉ាស៊ីត។ ខាងក្រោមនេះជារបៀបនៃការចម្លងមេរោគពីអាហារ និងទឹកៈ




របៀបនៃការពុលអាហារអាចមានលក្ខណៈដូចខាងក្រោម៖



អាហារនិងទឹករបស់អ្នកមិនមានសុវត្ថិភាពនិងដៃរបស់អ្នកមិនស្អាត

អាហារនិងទឹកមានមេរោគ

អ្នកអាចឈឺបន្ទាប់ពីបរិភោគអាហារ (ការពុលអាហារ)

រោគសញ្ញាមួយចំនួនដែលបណ្តាលមកពីការពុលអាហារ រួមមាន៖




❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការពុលចំណីអាហារ គឺបណ្តាលមកពីអាហារនិងទឹកដែលមានមេរោគដោយសារ បាក់តេរី វីរុស និងសាធាតុពុលដទៃទៀត ហើយតាមរយៈការបរិភោគអាហារនិងផឹកទឹកដែលមានមេរោគទាំងនេះ មនុស្សនឹងអាចពុល ឈឺ ឬស្លាប់បាន។ កត្តាធំៗបួនដែលធ្វើឱ្យមានការពុលអាហារ មានដូចជាអតិសុខុមប្រាណ (វីរុសនិងបាក់តេរី) សារធាតុគីមី ជាតិពុលពីធម្មជាតិ (ពីរុក្ខជាតិនិងសត្វ) និងប៉ារ៉ាស៊ីត។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើការពុលអាហារមានន័យដូចម្តេច?

២- តើមូលហេតុអ្វីខ្លះ ដែលនាំឱ្យពុលអាហារ?

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ៖**

១- ចូរអ្នកសាកសួរក្រុមគ្រួសាររបស់អ្នក ពីវិធីកាត់បន្ថយ ឬព្យាបាលការពុលអាហារ និងកត់ត្រា?

២- ចូរអ្នកមើលមេរៀនពីវិធីបង្ការការពុលអាហារ សម្រាប់រៀននៅម៉ោងអប់រំសុខភាពសប្តាហ៍ក្រោយ។

# មេរៀនទី ១ : ការពុលអាហារ ( តចប់ )

## ខ្លឹមសារម៉ោងទី ២ : វិធីបង្ការការពុលអាហារ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ពណ៌នាពីវិធីបង្ការការពុលអាហារ។ | • បង្ហាញពីវិធីបង្ការការពុលអាហារ។ | • បណ្ដុះទម្លាប់បរិភោគមានអនាម័យដើម្បីបង្ការការពុលអាហារ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

វិធីបង្ការការពុលអាហារៈ ដើម្បីបង្ការ និងការពារពីការពុលចំណីអាហារ យើងត្រូវអនុវត្តវិធានការសុវត្ថិភាព អនាម័យដូចជា ត្រូវលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាតឱ្យបានស្អាតល្អ សម្អាតសម្ភារៈផ្ទះបាយ ត្រូវចម្អិនម្ហូបអាហារឱ្យបានឆ្អិនល្អ ហាត់ប្រាណឱ្យបានទៀងទាត់ ដើម្បីឱ្យរាងកាយមានសុខភាពល្អ។

**៥- វិធីសាស្រ្ត**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅសប្ដាហ៍មុនអ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះគ្រូដាក់ឱ្យ? ចម្លើយសិស្ស : ......
  - ៣- តើវិធីព្យាបាលការពុលអាហារត្រូវធ្វើដូចម្ដេចខ្លះ? គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

ប្រសិនអ្នកមានអាការៈដូចដែលបានរៀបរាប់ខាងលើ ចូរអ្នកអនុវត្តតាមវិធានខាងក្រោម៖



ញ៉ាំទឹកឱ្យបានច្រើន
បង្ការការខ្សោះជាតិទឹក



ពិគ្រោះជាមួយគ្រូពេទ្យ
និងលេបថ្នាំ



សម្រាកនៅមន្ទីរពេទ្យ

## ខ្លឹមសារ : វិធីបង្ការការពុលអាហារ

- គ្រូបែងចែកសិស្សជា៤ក្រុម ពិភាក្សាសំណួរខាងក្រោម រយៈពេល ៥ ទៅ ១០នាទី៖
  - ក. តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីរក្សាភាពស្អាត?
  - ខ. តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីទុកដាក់អាហារដាច់ដោយឡែកពីគ្នា?
  - គ. តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីចម្អិនអាហារឱ្យបានឆ្អិនល្អ?
  - ឃ. តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីទុកដាក់អាហារក្នុងសីតុណ្ហភាពត្រឹមត្រូវ?
- គ្រូឱ្យតំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសំយោគលទ្ធផលតាមខ្លឹមសារមេរៀន
- គ្រូឱ្យសិស្សធ្វើតារាងអាហារដែលបានបរិភោគនៅថ្ងៃម្សិលមិញម្នាក់១សន្លឹក ( រយៈពេល៥នាទី )

| អាហារពេលព្រឹក | អាហារពេលថ្ងៃត្រង់ | អាហារពេលល្ងាច |
|---|---|---|
| អាហារ............................. | ............................. | .............................. |
| សម្ល............................. | ............................ | .................................. |
| សាច់ ស៊ុត....................... | ................................ | .................................. |
| បន្លែ........................... | ............................ | ............................ |
| ភេសជ្ជៈ......................... | ............................ | ............................ |
| ផ្លែឈើ.......................... | ............................ | ............................... |
| បង្អែម នំ ......................... | ............................ | ............................ |

- ឱ្យសិស្សចាប់ដៃគូពីរនាក់ និងប្តូរតារាងអាហារគ្នា
- ឱ្យសិស្សអានតារាងអាហាររបស់ដៃគូរបស់ខ្លួនឱ្យសិស្សដទៃទៀតស្តាប់ (៣ ទៅ ៤គូ)
- គ្រូឱ្យសិស្សសង្កេត និងគូសពីក្រោមអាហារដែលប្រឈមនឹងការពុលដែលមិត្តអ្នកបានបរិភោគ
- គ្រូសំយោគចម្លើយសិស្ស ដោយលើករូបភាពមកបង្ហាញ (គ្រូបកស្រាយពីអាហារដែលប្រឈម)

**ចម្លើយ**

ដើម្បីបង្ការនិងការពារពីការពុលចំណីអាហារយើងត្រូវអនុវត្តវិធានការសុវត្ថិភាពដូចខាងក្រោម៖

លាងសម្អាតដៃឱ្យបានញឹកញាប់



សម្អាតសម្ភារៈផ្ទះបាយនិងកន្លែងជូតដៃ



ចម្អិនឱ្យបានឆ្អិនល្អ ហើយបរិភោគឱ្យអស់ (កុំទុកបរិភោគពេលក្រោយ)



ធ្វើឱ្យរាងកាយរឹងមាំមានសុខភាពល្អ



❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ដើម្បីបង្ការ និងការពារពីការពុលចំណីអាហារ យើងត្រូវ អនុវត្តវិធានការសុវត្ថិភាព អនាម័យ ដូចជា ត្រូវលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាតឱ្យបានស្អាតល្អ សម្អាតសម្ភារៈផ្ទះបាយ ត្រូវចម្អិនម្ហូបអាហារឱ្យបានឆ្អិនល្អ ហាត់ប្រាណឱ្យបានទៀងទាត់ ដើម្បីឱ្យរាងកាយមានសុខភាពល្អ។

## ៧- វាយតម្លៃ (ជំហានទី៤)

១- គ្រូសួរសិស្សឱ្យសិស្សរៀបរាប់ឡើងវិញពីវិធានការបង្ការការពុលអាហារ

២- តើសកម្មភាពណាខ្លះដែលបង្ការការពុលអាហារ? ចូរគូស √ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ៖

√



លាងដៃជាមួយសាប៊ូ



ឆាប់ចូលគេង



ញ៉ាំអាហារឆៅ



ចោលសម្រាមមិនត្រឹមត្រូវ



សម្អាតសម្ភារៈផ្ទះបាយ



ងូតទឹកមុនទៅសាលា



ដុសធ្មេញឱ្យបានត្រឹមត្រូវ



ចម្អិនឱ្យបានឆ្អិនល្អ



ពាក់ម៉ាស់គ្រប់ពេល

## ៨- លំហាត់ (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកប្រាប់ក្រុមគ្រួសារពីវិធីបង្ការការពុលអាហារ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនជំងឺរាក សម្រាប់រៀននៅម៉ោងអប់រំសុខភាពសប្ដាហ៍ក្រោយ។

# មេរៀនទី ២ : ជំងឺរាក

## ខ្លឹមសារម៉ោងទី១ : ស្ថានភាព និងផលប៉ះពាល់នៃជំងឺរាក និងមូលហេតុបង្កជំងឺរាក

**១- រយៈពេល** : ម៉ោងទី១

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងអាចមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់ពីនិយមន័យ ជំងឺរាក<br>• រៀបរាប់ពីស្ថានភាព និងមូលហេតុនៃជំងឺរាក។ | • បង្ហាញពីមូលហេតុ នៃជំងឺរាក។ | • បណ្តុះទម្លាប់អនុវត្តអនាម័យក្នុងការបរិភោគអាហារនិងការរស់នៅដើម្បីបង្ការជំងឺរាក។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- ស្ថានភាពនិងផលប៉ះពាល់នៃជំងឺរាក : បើយោងតាមទិន្នន័យរបស់អង្គការប្រជាសាស្ត្រ និងសុខភាពនៅប្រទេសកម្ពុជាឆ្នាំ២០០៥ បានបង្ហាញឱ្យឃើញថា ក្នុងអំឡុងពេល២សប្តាហ៍ នៃការអង្កេតកុមារ២០ភាគរយមានជំងឺរាក។
- មូលហេតុបង្កជំងឺរាក: ជំងឺនេះបណ្តាលមកពីមូលហេតុជាច្រើនផ្សេងៗគ្នា អាចបណ្តាលមកពីបាក់ តេរី វីរុស ឬប៉ារ៉ាស៊ីត ដែលចម្លងចូលក្នុងរាងកាយរបស់យើងតាមរយៈការបរិភោគចំណីអាហារខ្វះអនាម័យ ទឹកមិនស្អាត ដៃមិនស្អាត សត្វរុយ និងការបត់ជើងពាសវាលពាសកាល។

**៥- វិធីសាស្ត្រ**

ការសួរសំណួរ និងចម្លើយ កាពិភាក្សា បកស្រាយ ការងារជាដៃគូ ឬក្រុម។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
    - ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : .............
    - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យ ? ចម្លើយសិស្ស : ......
    - ៣- តើអ្នកធ្លាប់រាកដែរឬទេ ? បើធ្លាប់មូលហេតុអ្វី ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ។

- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ស្ថានភាពនិងផលប៉ះពាល់នៃជំងឺរាក**

- គ្រូឱ្យសិស្សមើលសៀវភៅសិស្សរួចពន្យល់អំពីស្ថានភាពនៃជំងឺរាក : នៅប្រទេសកម្ពុជាឆ្នាំ២០០៥ បានបង្ហាញឱ្យឃើញថា ក្នុងអំឡុងពេល ២សប្ដាហ៍ នៃការអង្កេត កុមារ ២០ ភាគរយមានជំងឺរាក។ ១៩ ភាគរយនៃគ្រួសារដែលមានកុមារមានជំងឺរាក បានប្រើប្រាស់ប្រភពទឹកមិនស្អាត ហើយ ២១ ភាគរយបានប្រើប្រាស់បង្គន់ដែលគ្មានអនាម័យ។
- គ្រូសួរ: តើជំងឺរាកមានផលប៉ះពាល់អ្វីខ្លះដល់កុមារ ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

ចម្លើយ

ជំងឺរាកមានផលប៉ះពាល់ធ្ងន់ធ្ងរដល់កុមារ ដែលភាគច្រើនគឺបណ្ដាលមកពីបាត់បង់ជាតិទឹក និងជាតិអំបិលជាច្រើន។ ការបាត់បង់នេះហៅថាខ្សោះជាតិទឹក និងមូលហេតុសំខាន់មួយទៀតគឺរាកមូល។

**ខ្លឹមសារ : មូលហេតុបង្កជំងឺរាក**

- គ្រូបែងចែកសិស្សជាក្រុម ពិភាក្សាពីមូលហេតុដែលនាំឱ្យកើតជំងឺរាក
- តំណាងក្រុមឡើងរាយការណ៍និងបកស្រាយ
- គ្រូសម្របសម្រួលនិងសំយោគចម្លើយតាមខ្លឹមសារមេរៀន ដោយលើកយករូបភាពវដ្ដនៃការចម្លងជំងឺរាកមកបញ្ជាក់ផង។

ចម្លើយ

ជំងឺនេះបណ្ដាលមកពីមូលហេតុជាច្រើនផ្សេងៗគ្នា អាចបណ្ដាលមកពីបាក់តេរី វីរុស ឬប៉ារ៉ាស៊ីត ដែលចម្លងចូលក្នុងរាងកាយរបស់យើងតាមរយៈការបរិភោគចំណីអាហារខ្វះអនាម័យ ទឹកមិនស្អាត ដៃមិនស្អាត សត្វរុយ និងការបត់ជើងពាសវាលពាសកាល។




វដ្ដនៃការចម្លងជំងឺរាក



**មេរៀនសង្ខេប**

ជំងឺរាកច្រើនកើតមានចំពោះកុមារដែលរស់នៅជាមួយគ្រួសារ ឬក្នុងសហគមន៍ ដែលប្រើប្រាស់ប្រភពទឹកមិនស្អាត ខ្វះអនាម័យ គ្មានបង្គន់ប្រើប្រាស់ ។ល។ ជំងឺរាកមានផលប៉ះពាល់ធ្ងន់ធ្ងរដល់កុមារ ដូចជា កុមារមិនបានរៀនសូត្រ ការលូតលាស់រាងកាយនិងបញ្ញា និងបណ្តាលឱ្យកើតជំងឺផ្សេងទៀត។ ជំងឺរាកបណ្តាលមកពីបាក់តេរី វីរុស ឬប៉ារ៉ាស៊ីត ដែលចម្លងចូលក្នុងរាងកាយរបស់យើង។

**៧- វាយតម្លៃ** ( ជំហានទី៤ )

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើជំងឺរាកផ្តល់ផលវិបាកអ្វីខ្លះ ?

២- តើមូលហេតុអ្វីខ្លះដែលនាំឱ្យកើតជំងឺរាក ?

**៨- លំហាត់** ( ជំហានទី៥ )

**ការងារស្រាវជ្រាវ** : ចូរអ្នកស្រាវជ្រាវ តើរោគសញ្ញាជំងឺរាកមានអ្វីខ្លះ ? គ្រូនឹងប្រមូលចម្លើយនៅម៉ោងសិក្សាអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ជំងឺរាក (តចប់)

## ខ្លឹមសារម៉ោងទី ២ : រោគសញ្ញាជំងឺរាក និងការបង្ការជំងឺរាក

**១- រយៈពេល** : ១ ម៉ោង

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងអាចមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
| --- | --- | --- |
| • រៀបរាប់ពីរោគសញ្ញា និងវិធីបង្កានៃជំងឺរាក។ | • បង្ហាញពីរោគសញ្ញា និងវិធីបង្ការជំងឺរាក។ | • បណ្តុះទម្លាប់អនុវត្តអនាម័យក្នុងការបរិភោគអាហារ និងការរស់នៅដើម្បីបង្ការជំងឺរាក។ |

**៣- សម្ភារ:**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- រោគសញ្ញាជំងឺរាក: ករណីភាគច្រើន រោគសញ្ញានៃការរាកច្រើនតែបាត់ទៅវិញក្នុងរយៈពេលពីរថ្ងៃ។ ប៉ុន្តែមានពេលខ្លះ វាក៏អាចយូរដល់ច្រើនសប្តាហ៍ដែរ ហើយបើស្ថិតក្នុងស្ថានភាពបែបនេះ ជំងឺរាកអាចជាសញ្ញានៃជំងឺរលាកពោះវៀន។
- ការបង្ការជំងឺរាក: ដើម្បីបង្ការជំងឺរាកយើងត្រូវអនុវត្តវិធានដូចជាផឹកទឹកដាំពុះ ឬធុងចម្រោះ លាងដៃឱ្យបានស្អាតត្រឹមត្រូវជាមួយនឹងសាប៊ូ និងទឹកស្អាតជានិច្ច មុននឹងបរិភោគចំណីអាហារ និងក្រោយពេលចេញពីបង្គន់ ពិសេសពេលបន្ទោបង់រួចៗលៗ។

**៥- វិធីសាស្ត្រ**

ការសួរសំណួរ និងចម្លើយ ការពិភាក្សា បកស្រាយ ការងារជាដៃគូ ឬក្រុម។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន  អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យលើកមុន? ចម្លើយសិស្ស : ......
  - ៣- តើមូលហេតុអ្វីខ្លះដែលនាំឱ្យកើតជំងឺរាក? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ ទៅ៣នាក់ឱ្យឆ្លើយ។ សិស្សឆ្លើយ : ......................

ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)

## ខ្លឹមសារ : រោគសញ្ញាជំងឺរាក

- គ្រូឱ្យសិស្សមើលសៀវភៅសិស្សរួចពន្យល់ : ករណីភាគច្រើន រោគសញ្ញានៃការរាគច្រើនតែបាត់ទៅវិញក្នុងរយៈពេលពីរថ្ងៃ។ ប៉ុន្តែមានពេលខ្លះ វាក៏អាចយូរដល់ច្រើនសប្តាហ៍ដែរ ហើយបើស្ថិតក្នុងស្ថានភាពបែបនេះ ជំងឺរាកអាចជាសញ្ញានៃជំងឺរលាកពោះវៀន។
- គ្រូសួរ ៖ តើជំងឺរាកមានរោគសញ្ញាដូចម្តេច? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

  ចម្លើយ: រោគសញ្ញានៃជំងឺរាកមានដូចជា៖

  - ឧស្សាហ៍ជុះ លាមកទន់និងសុទ្ធតែទឹក
  - ឈឺពោះបែបរមួល ហើមពោះ ក្តៅខ្លួន
  - មានឈាមតាមលាមក
  - ខ្សោះជាតិទឹក ស្រេកទឹក
  - បត់ជើងតូច (នោម) តិច
  - សាច់ដុំខ្សោយ ភ្នែករូង។ ប្រសិនបើអ្នកជំងឺក្អួតទៀតនោះបង្ហាញថា អ្នកជំងឺមានសភាពកាន់តែធ្ងន់ធ្ងរត្រូវបញ្ជូនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យជាបន្ទាន់។



រោគសញ្ញានៃជំងឺរាក

## ខ្លឹមសារ : វិធីបង្ការជំងឺរាក

សកម្មភាព : គ្រូបែងចែកសិស្សជាក្រុមពិភាក្សាពីមូលហេតុ រោគសញ្ញា និងវិធីបង្ការនៃជំងឺរាកក្នុងតារាងខាងក្រោម៖

| មូលហេតុ | រោគសញ្ញា | វិធីបង្ការ |
|---|---|---|
| | | |
| | | |

- តំណាងក្រុមឡើងរាយការណ៍និងបកស្រាយ
- គ្រូសំយោគចម្លើយតាមខ្លឹមសារមេរៀន

| មូលហេតុ | រោគសញ្ញា | វិធីបង្ការ |
| --- | --- | --- |
| បណ្ដាលមកពីបាក់តេរី វីរុស ឬប៉ារ៉ាស៊ីត ដែលចម្លងចូលក្នុងរាងកាយរបស់យើងតាមការបរិភោគចំណីអាហារ និងទឹកកខ្វក់។ មេរោគចូលទៅក្នុងមាត់តាមរយៈការបរិភោគគ្មានអនាម័យ ទឹកកខ្វក់ ដៃមិនស្អាត សត្វរុយ និងការបត់ជើងពាសវាលពាសកាល។ | - ឧស្សាហ៍ជុះ លាមកទន់និងសុទ្ធតែទឹក<br>- ឈឺពោះបែបរមួល ហើមពោះក្ដៅខ្លួន<br>- មានឈាមតាមលាមក<br>- ខ្សោះជាតិទឹក ស្រេកទឹក<br>- បត់ជើងតូច(នោមតិច) សាច់ដុំខ្សោយ ភ្នែករូង។ | ផឹកទឹកដាំពុះ - ឬធុងចម្រោះ<br>- លាងដៃឱ្យបានស្អាតត្រឹមត្រូវជាមួយនឹងសាប៊ូ និងទឹកស្អាតជានិច្ច មុននឹងបរិភោគចំណីអាហារ និងក្រោយពេលចេញពីបង្គន់ ពិសេសពេលបន្ទោបង់រួច<br>-អនាម័យចំណីអាហារដោយទុកដាក់អាហារនៅកន្លែងស្អាត ដើម្បីចៀសវាងមានការចម្លងមេរោគតាមរយៈសត្វរុយ ឬធូលីផ្សេងជាដើម លាងបន្លែ ផ្លែឈើឱ្យបានស្អាត ជាពិសេសប្រសិនបើត្រូវរៀបចំទទួលទានឆៅ។<br>-បន្ទោបង់ក្នុងបង្គន់អនាម័យជានិច្ច។ |



❖ គ្រូសំយោគចម្លើយ និងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

រោគសញ្ញានៃជំងឺរាកមានដូចជា ឧស្សាហ៍ជុះ លាមកសុទ្ធតែទឹក បង្ហើយផតចូល ចំពោះកុមារតូចៗ បបូរមាត់ស្ងួត ភ្នែកខូង ឈឺពោះបែបរមួល ហើមពោះ ក្ដៅខ្លួន មានឈាមតាមលាមក ស្រេកទឹក បត់ជើងតូច (នោមតិច) សាច់ដុំខ្សោយ។ ដើម្បីបង្ការជំងឺរាកយើងត្រូវផឹកទឹកដាំពុះ ឬទឹកចម្រោះ លាងដៃឱ្យបានស្អាតត្រឹមត្រូវជាមួយនឹងសាប៊ូ មុននឹងបរិភោគចំណីអាហារ និងក្រោយពេលចេញពីបង្គន់ លាងបន្លែ ផ្លែឈើឱ្យបានស្អាត និងជៀសវាងការបន្ទោបង់ពាសវាលពាសកាល ពិសេសនៅជិតប្រភពទឹក៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើរោគសញ្ញាជំងឺរាកមានអ្វីខ្លះ?

២- តើវិធីបង្ការជំងឺរាកមានអ្វីខ្លះ?

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ**

១- ចូរអ្នករៀបរាប់ពីវិធីបង្ការជំងឺរាក និងប្រមូលចម្លើយនៅម៉ោងសិក្សាលើកក្រោយ។

២- ចូរអ្នកមើលមេរៀនថ្នាំបង្ការ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : ថ្នាំបង្ការ

## ខ្លឹមសារម៉ោងទី ១ : និយមន័យថ្នាំបង្ការ និងសារៈសំខាន់

**១- រយៈពេល** : ១ ម៉ោង

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងអាចមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់ពីនិយមន័យ និងសារៈសំខាន់នៃថ្នាំបង្ការ។ | • បកស្រាយពីប្រភេទ និងសារៈសំខាន់នៃថ្នាំបង្ការ។ | • ចូលរួមផ្សព្វផ្សាយនិងលើកទឹកចិត្តឪពុកម្តាយយកកូនទៅទទួលថ្នាំបង្ការ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ (ប័ណ្ណរូបភាពប្រតិទិន ប័ណ្ណសុខភាពកុមារ)

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

និយមន័យ: ថ្នាំបង្ការ គឺជាថ្នាំសម្រាប់ការពារប្រឆាំងនឹងមេរោគឆ្លងផ្សេងៗ។

ថ្នាំបង្ការ និងសារៈសំខាន់: ការផ្តល់ថ្នាំបង្ការពិតជាមានសារៈសំខាន់ណាស់ ពីព្រោះអាចការពារពីជំងឺនានា ពិសេសកុមារ។ បច្ចុប្បន្ននេះការផ្តល់ថ្នាំបង្ការគឺជាវិធីល្អបំផុតដែលឪពុកម្តាយអាចការពារកូនពីជំងឺកុមារធ្ងន់ធ្ងរ ១១ មុខ មុនកុមារមានអាយុ ២ ឆ្នាំ។ ថ្នាំបង្ការមានសម្រាប់កុមារនិងមនុស្សពេញវ័យ ៖

ក- ថ្នាំបង្ការ១១មុខ ដែលត្រូវតែចាក់ឱ្យទារកទើបនឹងកើតរហូតដល់អាយុ ១៨ ខែ

ខ- ថ្នាំបង្ការផ្សេងៗទៀតដែលយើងគួរចាក់ ឬផ្តល់

**៥- វិធីសាស្ត្រ**

ការសួរសំណួរ និងចម្លើយ ការធ្វើបទបង្ហាញរបស់សិស្ស ការងារជាដៃគូ ឬក្រុម។

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

ទំនាក់ទំនងមេរៀន (ជំហានទី២)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......

៣- តើអ្នកធ្លាប់ចាក់ថ្នាំដែរឬទេ? បើធ្លាប់តើចាក់ថ្នាំអ្វីខ្លះ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្ស:...

- គ្រូសំយោគ និងសម្របសម្រួលចម្លើយសិស្ស។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យថ្នាំបង្ការ**

- គ្រូឱ្យសិស្សមើលសៀវភៅសិស្សរួចពន្យល់ ៖ ថ្នាំបង្ការបានជួយស្រោចស្រង់ជីវិតមនុស្សបានជាច្រើនលាននាក់ណាស់ នៅលើពិភពលោក។ ការយកកុមារទៅចាក់ថ្នាំបង្ការ គឺដូចជាបានការពារកុមារពីជំងឺឆ្លងមួយចំនួនផង និងបានការពារកុំឱ្យជំងឺនោះធ្វើការរាតត្បាតផង។
- គ្រូសួរៈ តើអ្វីទៅជាថ្នាំបង្ការ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ
- គ្រូសម្របសម្រួលនិងសំយោគចម្លើយ

**ចម្លើយ**

ថ្នាំបង្ការ គឺជាថ្នាំសម្រាប់ការពារប្រឆាំងនឹងមេរោគឆ្លងផ្សេងៗ។

- គ្រូសួរ : តើការចាក់ថ្នាំបង្ការមានសារៈសំខាន់អ្វីខ្លះ? គ្រូទុកពេល ៣នាទីឱ្យសិស្សគិត រួចគ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ។
- គ្រូសម្របសម្រួល និងសំយោគចម្លើយ។

**ចម្លើយ**

- ការចាក់ថ្នាំបង្ការ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះអាចការពារយើងពីជំងឺនានាពិសេសគឺកុមារ។ ការយកកុមារទៅចាក់ថ្នាំបង្ការ គឺដូចជាបានការពារកុមារពីជំងឺឆ្លងកាចៗមួយចំនួនផង និងបានការពារកុំឱ្យជំងឺនោះធ្វើការរាតត្បាតផង។ បច្ចុប្បន្ននេះការផ្ដល់ថ្នាំបង្ការគឺជាវិធីល្អបំផុតដែលឪពុកម្ដាយអាចការពារកូនពីជំងឺកុមារធ្ងន់ធ្ងរ ១១ មុខ មុនកុមារមានអាយុ ២ ឆ្នាំ។
- សកម្មភាព : គ្រូបែងចែកសិស្សជាក្រុមពិភាក្សាសំណួរៈ ចូរអ្នករៀបរាប់ពីឈ្មោះថ្នាំបង្ការ ។
- តំណាងក្រុមឡើងរាយការណ៍និងបកស្រាយ
- គ្រូសំយោគចម្លើយតាមខ្លឹមសារមេរៀន

**ចម្លើយ**

ការផ្ដល់ថ្នាំបង្ការគឺជាវិធីល្អបំផុតដែលឪពុកម្ដាយអាចការពារកូនពីជំងឺកុមារធ្ងន់ធ្ងរ១១មុខ មុនកុមារមានអាយុ ២ ឆ្នាំ។

ក- ថ្នាំបង្ការ ១១ មុខ ដែលត្រូវតែចាក់ ឬបន្តក់ឱ្យទារកទើបនឹងកើតរហូតដល់អាយុ១៨ ខែ៖

- ការពារជំងឺរបេង
- ការពារជំងឺរលាកថ្លើមប្រភេទបេ
- ការពារជំងឺគ្រុនស្វិតដៃជើង
- ជំងឺតេតាណូស



- ការពារជំងឺក្អកមាន់
- ការពារជំងឺខាន់ស្លាក់
- ការពាររលាកស្អូត-រលាកស្រោមខួរក្បាលដោយហ៊ីប(**HIB**)
- ការពាររលាកស្អូត-រលាកស្រោមខួរក្បាលដោយភ្នើម៉ូកូក
- ការពារជំងឺកញ្រ្ជិល
- ការពារជំងឺស្អូច
- ការពារជំងឺរលាកខួរក្បាលជេអ៊ី

ខ- ថ្នាំបង្ការផ្សេងៗទៀតដែលយើងគួរចាក់មានៈ

- ការពារជំងឺអុតស្វាយ
- ផ្តាសាយធំ
- មហារីកមាត់ស្បូន
- ជំងឺរលាកថ្លើមប្រភេទបេ








❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ថ្នាំបង្ការបានជួយស្រោចស្រង់ជីវិតមនុស្សបានជាច្រើនលាននាក់ណាស់នៅលើពិភពលោក។ ការយកកុមារទៅទទួលថ្នាំបង្ការ គឺដូចជាបានការពារកុមារពីជំងឺឆ្លង កាចៗមួយចំនួនផង និងបានការពារកុំឱ្យជំងឺនោះធ្វើការរាតត្បាតផង។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ចូរឱ្យនិយមន័យថ្នាំបង្ការ?

២- តើថ្នាំបង្ការមានសារៈសំខាន់ដូចម្តេចខ្លះ?

**៨- លំហាត់** (ជំហានទី៥)

**ការងារស្រាវជ្រាវ** : ចូរអ្នកសួរឪពុក ឬម្តាយរបស់អ្នកថា តើអ្នកធ្លាប់បានចាក់ថ្នាំបង្ការអ្វីខ្លះ? កត់ត្រាពីឈ្មោះថ្នាំបង្ការទាំងនោះ។ គ្រូនឹងប្រមូលចម្លើយនៅម៉ោងសិក្សាលើកក្រោយ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនថ្នាំបង្ការ ត្រង់ចំណុចប្រតិទិននិងសេវាផ្តល់ថ្នាំបង្ការ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : ថ្នាំបង្ការ (តចប់)

## ខ្លឹមសារម៉ោងទី ២ : ប្រតិទិន និងសេវាផ្ដល់ថ្នាំបង្ការ

**១- រយៈពេល** : ១ ម៉ោង

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងអាចមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីប្រតិទិន និងសេវាផ្ដល់ថ្នាំបង្ការ | • បង្ហាញពីសេវាផ្ដល់នៃថ្នាំបង្ការ<br>• ធ្វើតារាងប្រតិទិននៃថ្នាំបង្ការតាមការណែនាំរបស់កម្មវិធីជាតិ។ | • ចូលរួមផ្សព្វផ្សាយនិងលើកទឹកចិត្តឪពុកម្ដាយយកកូនទៅទទួលថ្នាំបង្ការ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ (ប័ណ្ណរូបភាពប្រតិទិន ប័ណ្ណសុខភាពកុមារ)។

**៤- ខ្លឹមសារ និងគំនិតសំខាន់ៗ**

ប្រតិទិន និងសេវាផ្ដល់ថ្នាំបង្ការ

- ការចាក់ថ្នាំបង្ការមួយចំនួន ត្រូវបានធ្វើឡើងចាប់ពីទារកទើបនឹងកើតរហូតដល់ធំ ហើយការចាក់ថ្នាំបង្ការ បែងចែកជាពីរ គឺថ្នាំបង្ការដែលយើងត្រូវតែចាក់ និងថ្នាំបង្ការដែលយើងគួរតែចាក់។
- សេវាផ្ដល់ថ្នាំបង្ការមាននៅគ្រប់មណ្ឌលសុខភាព មន្ទីរពេទ្យ និងមន្ទីរពេទ្យបង្អែក តាមរាជធានី ខេត្ត។

**៥- វិធីសាស្ត្រ**

ការសួរសំណួរ និងចម្លើយ ការធ្វើបទបង្ហាញរបស់សិស្ស ការងារជាដៃគូ ឬក្រុម។

**៦- សកម្មភាពបង្រៀន និងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

ទំនាក់ទំនងមេរៀន (ជំហានទី២)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្ដាហ៍**មុន**អ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......

៣- តើអ្នកធ្លាប់បានចាក់ថ្នាំបង្ការអ្វីខ្លះ ? គ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ គ្រូសម្របសម្រួលចម្លើយសិស្ស។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ប្រតិទិននិងសេវាផ្តល់ថ្នាំបង្ការ**

- គ្រូឱ្យសិស្សមើលសៀវភៅសិស្សរួចពន្យល់ : ការចាក់ថ្នាំបង្ការមួយចំនួន ត្រូវបានធ្វើឡើងចាប់ពីទារកទើបនឹងកើតរហូតដល់ធំ ហើយការចាក់ថ្នាំបង្ការ បែងចែកជាពីរ គឺថ្នាំបង្ការដែលយើងត្រូវតែចាក់ និងថ្នាំបង្ការដែលយើងគួរតែចាក់។

**សកម្មភាព** : គ្រូបែងចែកសិស្សជាក្រុមពិភាក្សា និងបំពេញតារាងខាងក្រោម។

- ចូរអ្នកបំពេញឈ្មោះថ្នាំបង្ការ និងពេលវេលាដែលត្រូវចាក់ថ្នាំបង្ការឱ្យបានត្រឹមត្រូវ ក្នុងតារាងប្រតិទិននៃការផ្តល់ថ្នាំបង្ការសម្រាប់កុមារ។ គ្រូទុកពេល ៥ ទៅ៨នាទី ឱ្យសិស្សពិភាក្សា។

| ថ្នាំវ៉ាក់សាំង | អាយុកុមារ | | | | | | |
|---|---|---|---|---|---|---|---|
| | ពេលកើត | ៦ សប្តាហ៍ | ១០ សប្តាហ៍ | ១៤សប្តាហ៍ | ៦ខែ | ១០ខែ | ១៨ខែ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

- តំណាងក្រុមឡើងរាយការណ៍និងបកស្រាយ
- គ្រូសំយោគចម្លើយតាមខ្លឹមសារមេរៀន

| ថ្នាំវ៉ាក់សាំង | អាយុកុមារ | | | | | | |
|---|---|---|---|---|---|---|---|
| | ពេលកើត | ៦ សប្តាហ៍ | ១០ សប្តាហ៍ | ១៤សប្តាហ៍ | ៦ខែ | ១០ខែ | ១៨ខែ |
| ការពារជំងឺរបេង | × | | | | | | |
| ការពារជំងឺថ្លើមប្រភេទបេ | × | | | | | | |
| ការពាជំងឺគ្រុនស្វិតដៃជើងប្រភេទបន្តក់ | | × | × | × | | | |
| ការពាជំងឺគ្រុនស្វិតដៃជើងប្រភេទចាក់ | | | | × | | | |
| ការពារជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកថ្លើមប្រភេទបេ និង រលាកសួត-រលាកស្រោម ខួរក្បាល ដែលបង្ករដោយមេរោគ ហ៊ីប | | × | × | × | | | |
| ការពាររលាកសួត-រលាកស្រោមខួរក្បាលដោយភ្នើម៉ូកូត | | × | × | × | | | |
| ការពារជំងឺកញ្ជ្រិល-ស្អូច | | | | | × | × | × |
| ការពារជំងឺរលាកខួរក្បាលជេអ៊ី | | | | | | × | |




- គ្រូសួរ : តើនៅកន្លែងណាខ្លះដែលមានផ្តល់ថ្នាំបង្ការ ? គ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ**

សេវាផ្តល់ថ្នាំបង្ការមាននៅគ្រប់មណ្ឌលសុខភាព មន្ទីរពេទ្យ និងមន្ទីរពេទ្យបង្អែក តាមរាជធានី ខេត្ត។



❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការចាក់ថ្នាំបង្ការ ពិតជាមានសារៈសំខាន់ណាស់ ពីព្រោះអាចការពារយើងពីជំងឺនានា ពិសេសគឺកុមារ។ សេវាផ្តល់ថ្នាំបង្ការមាននៅគ្រប់ មន្ទីរពេទ្យ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព តាមរាជធានី ខេត្ត៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើថ្នាំបង្ការមានអ្វីខ្លះ ?

២- តើនៅកន្លែងណាខ្លះដែលមានផ្តល់ថ្នាំបង្ការ ?

**៨- លំហាត់** (ជំហានទី៥)

**ការងារស្រាវជ្រាវ** : ចូរអ្នកប្រាប់ឈ្មោះទីកន្លែងដែលផ្តល់ថ្នាំបង្ការដែលមាននៅក្នុងសហគមន៍របស់ប្អូន។ ហើយកត់ត្រា គ្រូប្រមូលនៅម៉ោងក្រោយ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនទំនុកចិត្តនិងការទាក់ទងជាមួយមិត្តភក្តិសម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ទំនុកចិត្តនិងការទាក់ទងជាមួយមិត្តភក្តិ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ប្រាប់និយមន័យ "ទំនុកចិត្ត"<br>- រៀបរាប់ពីការបង្កើតទំនុកចិត្តលើខ្លួនឯងនិងការប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិល្អ។ | - ប្រាប់និយមន័យ "ទំនុកចិត្ត"<br>- រៀបរាប់ពីការបង្កើតទំនុកចិត្តលើខ្លួនឯងនិងការប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិល្អ។ | - បណ្តុះការស្រលាញ់និងមើលថែរក្សាខ្លួនឯង មានភាពក្លាហានក្នុងការចូលរួមសកម្មភាពសង្គម។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**និយមន័យទំនុកចិត្ត** គឺជាអារម្មណ៍ម៉្យាងរបស់មនុស្ស មិនថាជឿជាក់លើខ្លួនឯង អ្នកដទៃ ឬព័ត៌មានផ្សេងៗនោះទេ។ អារម្មណ៍នេះកើតចេញពីការទទួលបានជោគជ័យអ្វីមួយក្នុងជីវិតរបស់យើង ឬ ព័ត៌មានដែលមានភស្តុតាង ឬអំណះអំណាងច្បាស់លាស់។

**ការបង្កើនទំនុកចិត្តលើខ្លួនឯង** រួមមាន កុំមើលងាយខ្លួនឯង មើលពីចំណុចល្អរបស់ខ្លួនឯង ជឿជាក់លើសមត្ថភាពរបស់ខ្លួន ត្រូវគិតវិជ្ជមាន ចេះស្លៀកពាក់ ឬរៀបចំខ្លួនឱ្យបានស្អាតបាត ត្រៀមលក្ខណៈមុននឹងធ្វើអ្វីមួយ និងអនុវត្តជាប្រចាំ។

**ការប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិល្អ** គឺជាធាតុសំខាន់របស់ទំនុកចិត្តលើអ្នកដទៃ អាចទុកចិត្តបាន អាចពឹងពាក់បាន អាចជួយយកអាសារគ្នាទៅវិញទៅមកបាន និងជួយអ្នកបានពេលត្រូវការជាដើម។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ពិភាក្សាក្រុម សំណួរនិងចម្លើយ

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនប្អូនបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យលើកមុន? ចម្លើយសិស្ស : ......

៣- តើអ្នកអាចធ្វើអ្វីបានខ្លះ?" (សិស្សអាចលើកកិច្ចការមិនថាតូច ឬ ធំនោះទេ មិនថានៅផ្ទះ ឬនៅ

សាលានោះទេ)។ សិស្សឆ្លើយ.......................

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យទំនុកចិត្ត**

- គ្រូសួរសំណួរ "តើអ្វីទៅជាទំនុកចិត្ត?" ទុកពេល១ទៅ២នាទីរួចហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយសិស្សតាមខ្លឹមសារមេរៀន រួចពន្យល់

**ចម្លើយ**

ទំនុកចិត្ត ជាអារម្មណ៍ម៉្យាងរបស់មនុស្ស មិនថាជឿជាក់លើខ្លួនឯង អ្នកដទៃ ឬព័ត៌មានផ្សេងៗនោះទេ។ អារម្មណ៍នេះកើតចេញពីការទទួលបានជោគជ័យអ្វីមួយក្នុងជីវិតរបស់យើង ឬ ព័ត៌មានដែលមានភស្តុតាង ឬអំណះអំណាងច្បាស់លាស់។

**ខ្លឹមសារ : ការបង្កើតទំនុកចិត្តលើខ្លួនឯង និងការប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិល្អ**

- គ្រូបែងចែកសិស្សជាក្រុមធ្វើការពិភាក្សាដោយមានសិស្សពី ៤ ទៅ ៨ នាក់ក្នុងមួយក្រុម ទៅលើសំណួរ ៖

១- តើធ្វើដូចម្តេចដើម្បីបង្កើតទំនុកចិត្តលើខ្លួនឯង?

២- តើអ្វីខ្លះជាធាតុសំខាន់នៃការមានទំនុកចិត្តលើអ្នកដទៃ?

- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍លទ្ធផលពិភាក្សា
- គ្រូសម្របសម្រួលនិងសំយោគចម្លើយសិស្សត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ** : ដើម្បីបង្កើនទំនុកចិត្តលើខ្លួនឯង អ្នកត្រូវ៖

- **កុំមើលងាយខ្លួនឯង** : ត្រូវចេះលើកទឹកចិត្តខ្លួនឯង ឱ្យតម្លៃលើខ្លួនឯង គាំទ្រ និងសរសើរនូវអ្វីដែលខ្លួនឯងកំពុងធ្វើ ដោយមិនខ្លាចគេសើចចំអក។
- **មើលពីចំណុចល្អរបស់ខ្លួនឯង** : ការដឹងពីចំណុចល្អរបស់ខ្លួនឯងនឹងធ្វើឱ្យយើងស្គាល់ខ្លួនឯងកាន់តែច្បាស់ និងសប្បាយចិត្តចំពោះអ្វីដែលខ្លួនមាន។ យើងត្រូវចេះកត់សម្គាល់និងស្វែងរកចំណុចល្អរបស់ខ្លួនឯង ដើម្បីរក្សានិងអភិវឌ្ឍបន្ថែមនូវចំណុចល្អទាំងនោះ។
- **ជឿជាក់លើសមត្ថភាពរបស់ខ្លួន** : ត្រូវគិតថាអ្វីដែលគេអាចធ្វើបាន យើងក៏អាចធ្វើបានដែរ ទោះបីមិនបានល្អដូចគេក៏ដោយ។
- **ត្រូវគិតវិជ្ជមាន** : គំនិត ឬការគិតវិជ្ជមានចំពោះខ្លួនឯង ជួយធ្វើឱ្យយើងមានទឹកចិត្ត មានក្ដីសង្ឃឹម និងជឿជាក់លើខ្លួនឯងក្នុងការបំពេញកិច្ចការអ្វីមួយ។ ការគិតវិជ្ជមានចំពោះអ្នកដទៃក៏ជាផ្នែកមួយសំខាន់ក្នុងការជួយយើងកសាងទំនុកចំពោះអ្នកដទៃ ដើម្បីទទួលបាននូវការឱ្យតម្លៃនិងការគោរពពីអ្នកដទៃ។
- **ការស្លៀកពាក់ ឬរៀបចំខ្លួន** : ការរៀបចំខ្លួនឱ្យបានសមរម្យគឺជួយឱ្យយើងមានការប្រាស្រ័យទាក់ទង ឬនិយាយទៅកាន់អ្នកដទៃដោយភាពជឿជាក់និងទំនុកចិត្ត។

- **ត្រៀមលក្ខណៈមុននឹងធ្វើអ្វីមួយ** : នៅពេលដែលអ្នកបានត្រៀមចិត្ត ឬត្រៀមគំនិត និងរៀបចំកិច្ចការអ្វីមួយមុននឹងយកទៅអនុវត្ត ឬបង្ហាញដល់អ្នកដទៃ ជួយយើងក្នុងការបង្កើនទំនុកចិត្ត។
- **អនុវត្ត** : ការហាត់សមធ្វើកិច្ចការមួយដដែលៗឱ្យក្លាយទៅជាទម្លាប់ រហូតដល់យើងដឹងខ្លួនឯងលែងភ័យខ្លាចនិងមានទំនុកចិត្ត។

- គ្រូសំយោគចម្លើយសិស្សនិងពន្យល់បន្ថែម ៖ ដូចគ្នានឹងការមានទំនុកចិត្តលើខ្លួនឯង ការមានទំនុកចិត្តលើនរណាម្នាក់កើតចេញពីភាពជោគជ័យនៃទំនាក់ទំនងបន្តិចម្តងៗ។ ការមានទំនុកចិត្តលើនរណាម្នាក់ ឬមិត្តភក្តិរបស់យើង នឹងជួយបង្កើតឱ្យមានទំនាក់ទំនងល្អជាមួយគ្នា ហើយការធ្វើការងារជាមួយគ្នានឹងបានកាន់តែប្រសើរ។ ការធ្វើការងារជាក្រុម ជាពិសេសជាមួយមិត្តភក្តិ នឹងជួយយើងឱ្យសម្រេចការងារបានងាយស្រួល និងដោះស្រាយនូវការលំបាក ដែលការធ្វើការងារម្នាក់ឯងមិនអាចធ្វើបាន។ ដូចសុភាសិតខ្មែរលើកឡើងថា “ចង្កឹះមួយបាច់ កាច់មិនបាក់”។



ការឱ្យតម្លៃនិងការគោរពសិទ្ធិគ្នាដោយគ្មានការរើសអើង

គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ទំនុកចិត្ត ជាអារម្មណ៍ម៉្យាងរបស់មនុស្ស មិនថាជឿជាក់លើខ្លួនឯង អ្នកដទៃ ឬព័ត៌មាន ផ្សេងៗនោះទេ។ ការមានទំនុកចិត្តលើខ្លួនឯង ជាចំណែកមួយនៃភាពជោគជ័យនៅពេលអនាគត។ ដើម្បីផ្តល់ទំនុកចិត្តបន្ថែមពីការកសាងទំនុកចិត្តលើខ្លួនឯង ឪពុកម្តាយ គ្រូបង្រៀន ឬអ្នកអាណាព្យាបាលគួរធ្វើការលើកទឹកចិត្តទៅលើអ្វីដែលសិស្សអាចធ្វើបាន ជាពិសេសពេលគាត់នៅតូច។ ធាតុសំខាន់របស់ទំនុកចិត្តលើអ្នកដទៃ គឺការអាចទុកចិត្តបាន អាចពឹងពាក់បាន អាចជួយយកអាសារគ្នាទៅវិញទៅមកបាន និងជួយអ្នកបានពេលត្រូវការជាដើម៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសិស្សឱ្យរៀបរាប់ឡើងវិញ៖

១- តើទំនុកចិត្តជាអ្វី?

២- តើធ្វើដូចម្ដេចដើម្បីបង្កើតទំនុកចិត្តលើខ្លួនឯង?

៣- តើការមានទំនុកចិត្តជាមួយមិត្តភក្តិអាចជួយអ្វីបានខ្លះ?

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ**

១- សូមអ្នករកមនុស្សដែលអ្នកទុកចិត្តឱ្យបានយ៉ាងតិច ៥ នាក់ ផ្សេងៗពីគ្នា។

២- ចូរអ្នកមើលមេរៀនការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ

## ខ្លឹមសារម៉ោងទី១ : ការឱ្យតម្លៃខ្លួនឯង

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងអាចមាន ៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ពណ៌នាពីអារម្មណ៍ និង ញ្ញាណទាំងប្រាំ<br>- រៀបរាប់ពីការឱ្យតម្លៃខ្លួនឯង។ | - បង្ហាញអារម្មណ៍របស់ខ្លួនឯង និងអារម្មណ៍អ្នកដទៃ។ | - បណ្តុះគំនិតក្នុងការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**អារម្មណ៍និងញ្ញាណទាំងប្រាំ៖**

**អារម្មណ៍** មានន័យថាជាសភាពចិត្តរបស់មនុស្សដែលឆ្លើយតបទៅនឹងហេតុការណ៍ដែលបានកើតឡើងមកលើយើង ដែលចូលតាមរយៈញ្ញាណទាំងប្រាំរបស់មនុស្ស។ វាមានន័យថា អារម្មណ៍របស់មនុស្សយើងកើតឡើងបាន នៅពេលមានពត៌មាន ឬបាតុភូតអ្វីមួយមកប៉ះនឹងញ្ញាណទាំងប្រាំរបស់មនុស្សយើង ហើយបញ្ជូនទៅក្នុងខួរក្បាល ដែលបង្កើតបានជាចិត្ត ហើយអារម្មណ៍កកើតមកជាមួយនឹងចិត្តដែរ។

**ញ្ញាណទាំងប្រាំមាន** : ចក្ខុវិញ្ញាណ ឃានវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ ជីវ្ហាវិញ្ញាណ

**ការឱ្យតម្លៃខ្លួនឯង** : គឺជាអារម្មណ៍និងការគិតរបស់មនុស្សម្នាក់ ដែលធ្វើការត្រួតពិនិត្យទៅលើគុណតម្លៃរបស់ខ្លួនឯងដែលមាន។ ការឱ្យតម្លៃខ្លួនឯងទទួលបានមកពីប្រភពចំបងពីរគឺ ប្រភពខាងក្រៅខ្លួននិងប្រភពខាងក្នុងខ្លួន។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ពិភាក្សាក្រុម សំណួរនិងចម្លើយ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន ? ចម្លើយសិស្ស : ......

៣- គ្រូសួរសំណួរបំផុស "នៅពេលប្អូនធ្វើអ្វីមួយបានសម្រេច ហើយត្រូវបាននរណាម្នាក់សរសើរ តើប្អូនមានអារម្មណ៍ដូចម្ដេចខ្លះ?" (អារម្មណ៍ខ្លួនឯងដែលធ្វើបានសម្រេចនិងអារម្មណ៍ដែលត្រូវបានគេសរសើរ)។ ចម្លើយសិស្ស................

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : អារម្មណ៍និងញ្ញាណទាំងប្រាំ**

- គ្រូសួរសិស្ស "តើអ្នកដឹងពីវត្ថុនៅជុំវិញខ្លួនបានដោយរបៀបណា?" (គ្រូអាចសួរបន្ថែមដូចជា "តើអ្នកដឹងថាក្ដារខៀនពណ៌អ្វីតាមរយៈអ្វី? ដឹងថាក្រូចឆ្មាមានរសជាតិអ្វី ហើយតាមរយៈអ្វី? ដឹងថាអាកាសធាតុក្ដៅ ឬ ត្រជាក់ដោយរបៀបណា? ដឹងថាមានមនុស្សដើរពីក្រោយយ៉ាងម៉េច (លឺសំរឹបជើង)? អាចដឹងថាមានខ្លិនក្រអូបដោយសារអ្វី?" ) ចម្លើយសិស្ស....................
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន។

**ចម្លើយ**

អារម្មណ៍ មានន័យថាជាសភាពចិត្តរបស់មនុស្សដែលឆ្លើយតបទៅនឹងហេតុការណ៍ដែលបានកើតឡើងមកលើយើង ដែលចូលតាមរយៈញ្ញាណទាំងប្រាំរបស់មនុស្ស។ វាមានន័យថា អារម្មណ៍របស់មនុស្សយើងកើតឡើងបាន នៅពេលមានព័ត៌មាន ឬបាតុភូតអ្វីមួយមកប៉ះនឹងញ្ញាណទាំងប្រាំរបស់មនុស្សយើង ហើយបញ្ជូនទៅក្នុងខួរក្បាល ដែលបង្កើតបានជាចិត្ត ហើយអារម្មណ៍ក៏កើតមកជាមួយនឹងចិត្តដែរ។

- យើងដឹងថាក្ដារខៀនពណ៌ស តាមរយៈចក្ខុវិញ្ញាណ
- យើងដឹងថាក្រូចឆ្មាមានរសជាតិជូរតាមរយៈជីវ្ហាវិញ្ញាណ
- យើងដឹងថាអាកាសធាតុក្ដៅឬត្រជាក់តាមរយៈកាយវិញ្ញាណ
- យើងដឹងថាមានមនុស្សដើរពីក្រោយយ៉ាងម៉េច (ឮសំរឹបជើង) តាមយរៈសោតវិញ្ញាណ
- យើងដឹងថាមានខ្លិនក្រអូបតាមរយៈឃានវិញ្ញាណ។




**ខ្លឹមសារ : ការឱ្យតម្លៃខ្លួនឯង**

- គ្រូចែកសិស្សជាក្រុមពិភាក្សាលើសំណួរ "តើការឱ្យតម្លៃលើខ្លួនឯងជាអ្វី? តើការឱ្យតម្លៃខ្លួនឯងមានប្រភពពីណាខ្លះ? ចូរបកស្រាយ"
- ឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍លទ្ធផលនៃការពិភាក្សាក្រុម

- គ្រូសំយោគចម្លើយសិស្សនិងពន្យល់។

**ចម្លើយ**

ការឱ្យតម្លៃខ្លួនឯង គឺជាអារម្មណ៍និងការគិតរបស់មនុស្សម្នាក់ ដែលធ្វើការត្រួតពិនិត្យទៅលើគុណតម្លៃរបស់ខ្លួនឯងដែលមាន។ បើតាមចិត្តវិទូ ម៉ាស្លូ ការឱ្យតម្លៃខ្លួនឯងទទួលបានមកពីប្រភពចំបងពីរគឺ **ប្រភពខាងក្រៅខ្លួន** : ការទទួលស្គាល់ ឬការសរសើរពីអ្នកដទៃ និងជោគជ័យចំពោះកិច្ចការណាមួយដែលខ្លួនធ្វើ។ **ប្រភពខាងក្នុងខ្លួន** : កើតចេញពីការស្រលាញ់ខ្លួនឯង ទំនុកចិត្តលើខ្លួនឯង និងជំនាញផ្សេងៗដែលខ្លួនឯងមានជាដើម។

**គ្រូពន្យល់បន្ថែម**

- មនុស្សម្នាក់ៗ មានលក្ខណៈពិសេសខុសៗគ្នា ដោយសារតែកត្តាច្រើនយ៉ាង ទាំងកត្តាជីវសាស្ត្រ ហ្សែន សុខភាព បទពិសោធន៍ផ្ទាល់ខ្លួន គ្រួសារ សង្គម និងកត្តាវប្បធម៌ជាដើម។ ដោយ សារកត្តានេះហើយ ទើបធ្វើឱ្យមនុស្សមានលក្ខណៈពិសេសផ្ទាល់ខ្លួន ដែលមិនមានអ្នកណាម្នាក់មានដូចគ្នាសោះឡើយ។
- ដោយសារតែបុគ្គលម្នាក់ៗមានលក្ខណៈពិសេសដាច់ដោយឡែកនេះហើយ ទើបយើងមិនអាចធ្វើការប្រៀបធៀបមនុស្សជាមួយនឹងមនុស្សម្នាក់ទៀតបាននោះទេ។ ទោះបីជាពេលខ្លះ មានមនុស្សយល់ថា ខ្លួនឯងមិនមានតម្លៃ មិនមានប្រយោជន៍ គ្មានសមត្ថភាព ឬមិនគួរឱ្យស្រលាញ់យ៉ាងណាក៏ដោយ ក៏ការដែលទទួលស្គាល់ថា ពួកគាត់មានលក្ខណៈពិសេសខុសពីអ្នកដទៃនឹងជួយឱ្យអ្នកទាំងនោះស្វែងរកឃើញនូវតម្លៃផ្ទាល់ខ្លួនរបស់គាត់មកវិញ។ ការទទួលស្គាល់នូវលក្ខណៈពិសេសផ្សេងៗគ្នារបស់អ្នកដទៃ គឺបង្ហាញពីការយល់ចិត្តនិងឱ្យតម្លៃដល់អ្នកដទៃ។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

អារម្មណ៍ មានន័យថាជាសភាពចិត្តរបស់មនុស្សដែលឆ្លើយតបទៅនឹងហេតុការណ៍ដែលបានកើតឡើងមកលើយើង ដែលចូលតាមរយៈញ្ញាណទាំងប្រាំរបស់មនុស្ស។ ការឱ្យតម្លៃខ្លួនឯង គឺជាអារម្មណ៍និងការគិតរបស់មនុស្សម្នាក់ ដែលធ្វើការត្រួតពិនិត្យទៅលើគុណតម្លៃរបស់ខ្លួនឯងដែលមាន។

## ៧- ខ្វាយតម្លៃ (ជំហានទី៤)

គ្រូសួរសិស្សឱ្យរៀបរាប់ឡើងវិញៈ

១- តើអ្វីជាអារម្មណ៍?

២- តើការឱ្យតម្លៃខ្លួនឯងជាអ្វី? មានប្រភពពីណាខ្លះ?

### ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ**

១- ចូរអ្នកមើលមេរៀនទំនាក់ទំនង សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

២- ចូរស្វែងរកបទពិសោធន៍ផ្ទាល់ខ្លួនដែលប្អូនគិតថាជាប្រភពក្នុងការជួយអ្នកក្នុងការបង្កើនការឱ្យតម្លៃខ្លួនឯង? ចូរស្វែងរកចម្លើយយ៉ាងតិចឱ្យបានបី



# មេរៀនទី២ : ការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ ( តចប់ )

## ខ្លឹមសារម៉ោងទី ២ : ការឱ្យតម្លៃខ្លួនឯង

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងអាចមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីការបង្កើនទំនុកចិត្តលើខ្លួនឯងនិងការឱ្យតម្លៃអ្នកដទៃ | - ហ៊ានទទួលកំហុសនិងទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន | - បណ្តុះគំនិតក្នុងការឱ្យតម្លៃខ្លួនឯងនិងអ្នកដទៃ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**ការឱ្យតម្លៃនិងបង្កើនទំនុកចិត្តខ្លួនឯង** : គឺជាទំនុកចិត្តលើខ្លួនឯង ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការបង្កើននូវការឱ្យតម្លៃលើខ្លួនឯង។ នៅមេរៀនមុនអ្នកបានដឹងរួចមកហើយថា ការមានទំនុកចិត្តលើខ្លួនឯងកើតចេញពីការសម្រេចបាននូវជោគជ័យផ្សេងៗ មិនថាវាតូច ឬធំនោះទេ។

**ការឱ្យតម្លៃនិងយល់ពីអ្នកដទៃ** : ការទទួលស្គាល់នូវ លក្ខណៈពិសេសផ្សេងៗគ្នារបស់អ្នកដទៃ គឺបង្ហាញពីការយល់ចិត្តនិងឱ្យតម្លៃដល់អ្នកដទៃ។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ពិភាក្សាក្រុម សំណួរនិងចម្លើយ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- គ្រូរំលឹកមេរៀនចាស់៖ បែងចែកជាក្រុមតូចៗពី ៤ ទៅ ៦ ក្រុម
    - គ្រូឱ្យក្រុមនីមួយៗ ជជែកពីមេរៀនលើកមុន
    - គ្រូឱ្យក្រុមនីមួយៗ សង្ខេបមេរៀនដែលខ្លួនចងចាំ
    - ធ្វើការទះដៃអបអរសាទរចំពោះការងាររបស់ពួកគាត់។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ការឱ្យតម្លៃនិងបង្កើនទំនុកចិត្តខ្លួនឯង**

- គ្រូឱ្យសិស្សយកក្រដាសម្នាក់មួយសន្លឹកសរសេរដាក់ឈ្មោះខ្លួនឯងឱ្យធំ ហើយឱ្យពួកគាត់សរសេរ

ពីលក្ខណៈពិសេសរបស់ខ្លួន ឬចំណុចល្អរបស់ខ្លួនក្នុងក្រដាស (កន្លែងណាក៏បាន) យ៉ាងតិច៣

- ពេលសរសេរចប់ ប្តូរក្រដាសគ្នាសរសេរ ដោយសមាជិកក្រុមសរសេរពីលក្ខណៈពិសេស ឬចំណុចល្អរបស់ឈ្មោះក្នុងក្រដាស (អ្នកក្នុងក្រុមត្រូវសរសេរទាំងអស់គ្នា)
- គ្រូឱ្យសិស្សដែលមានឈ្មោះក្នុងក្រដាស អានដោយស្ងៀមស្ងាត់ ១នាទី
- គ្រូសួរសិស្សទាំងអស់ "តើមានចំណុចណាថ្មីដែលខ្លួនមិនបានដឹងពីមុនមកទេ?"
- ឱ្យសិស្ស ៣ ទៅ ៤ នាក់និយាយ (អាចនិយាយពីចំណុចល្អរបស់ខ្លួនក៏បាន)
- គ្រូពន្យល់៖ **ទំនុកចិត្តលើខ្លួនឯង** ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការបង្កើននូវការឱ្យតម្លៃលើខ្លួនឯង។ នៅមេរៀនមុនអ្នកបានដឹងរួចមកហើយថា ការមានទំនុកចិត្តលើខ្លួនឯងកើតចេញពីការសម្រេចបាននូវជោគជ័យផ្សេងៗ មិនថាវាតូច ឬធំនោះទេ។ ដើម្បីសម្រេចជោគជ័យក្នុងកិច្ចការណាមួយ អ្នកត្រូវដឹងថាខ្លួនចង់ធ្វើអ្វីជាមុនសិន។ បន្ទាប់ពីដឹងខ្លួនចង់ធ្វើអ្វីហើយ អ្នកត្រូវការអ្នកជួយគាំទ្របន្ថែមទៀត រួមផ្សំនឹងការលើកទឹកចិត្តផ្សេងៗ។ ចំណុចមួយទៀតគឺការស្គាល់ខ្លួនឯងឱ្យបានច្បាស់ជាមុនសិន។ ហើយជាចំណុចសំខាន់ខ្លាំងមួយទៀត គឺការធ្វើដើម្បីប្រយោជន៍រួម ជាជាងគ្រាន់តែអត្មានិយមសម្រាប់តែខ្លួនឯង។
- គ្រូលើកទឹកចិត្តសិស្ស៖ អ្នកទាំងអស់គ្នាសុទ្ធតែមានគោលដៅផ្សេងៗពីគ្នា តើមានអ្វីខ្លះជួយជម្រុញអ្នកបន្ថែមទៀត? តើអ្នកមានភាពខ្លាំង និងចំណុចពិសេសអ្វីខ្លះ? តើវាជួយអ្វីខ្លះដល់ខ្លួនអ្នក និងអ្នកដទៃ? (ឱ្យសិស្សគិតតែមិនចាំបាច់ក្នុងការឆ្លើយនោះទេ)
- ឱ្យសិស្សទាំងអស់គ្នាសរសេរចម្លើយដាក់ក្នុងសៀវភៅមេរៀនរបស់ខ្លួន។

**ខ្លឹមសារ : ឱ្យតម្លៃនិងយល់ពីអ្នកដទៃ**

- គ្រូពន្យល់៖ ដោយសារតែបុគ្គលមានលក្ខណៈពិសេសដាច់ដោយឡែកនេះហើយ ទើបយើងមិនអាចធ្វើការប្រៀបធៀបមនុស្សជាមួយនឹងមនុស្សម្នាក់ទៀតបាននោះទេ។ ទោះបីជាពេលខ្លះ មានមនុស្សយល់ថាខ្លួនឯងមិនមានតម្លៃ មិនមានប្រយោជន៍ គ្មានសមត្ថភាព ឬ មិនគួរឱ្យស្រលាញ់យ៉ាងណាក៏ដោយ ក៏ការដែលទទួលស្គាល់ថា ពួកគាត់មានលក្ខណៈពិសេសខុស ពីអ្នកដទៃ នឹងជួយឱ្យអ្នកទាំងនោះស្វែងរកឃើញនូវតម្លៃផ្ទាល់ខ្លួនរបស់គាត់មកវិញ។



- ដើម្បីអាចដឹងពីភាពខ្លាំងនិងខ្សោយរបស់ខ្លួនឯង មនុស្សគ្រប់គ្នាត្រូវហ៊ាននិយាយប្រាប់អ្នកដទៃពីចំណុចខ្លាំងរបស់ខ្លួននិងទទួលស្តាប់ពីអ្នកដទៃវិញ
- គ្រូសួរសិស្សទាំងអស់ តើពួកគាត់អាចនិយាយប្រាប់ដល់អ្នកដែលគាត់ទុកចិត្តនូវចំណុចល្អ ឬភាពខ្លាំងបានទេ (លើកទឹកចិត្តឱ្យគាត់និយាយទៅកាន់អ្នកដែលគាត់ទុកចិត្ត) ? តើសិស្សទាំងអស់គ្នាទទួលស្តាប់ពីចំណុចខ្វះខាតរបស់ខ្លួនដែរទេ ? តើសិស្សធ្វើឱ្យប្រសើរចំណុចទាំងនោះបានដែរទេ ?

៣. គ្រូសង្ខេបមេរៀននិងអានឱ្យសិស្សកត់។



**មេរៀនសង្ខេប**

ការឱ្យតម្លៃលើខ្លួនឯងមានប្រភពចំបងពីរ គឺប្រភពពីខាងក្រៅខ្លួននិងប្រភពខាងក្នុងខ្លួន។ ដើម្បីបង្កើននូវទំនុកចិត្តលើខ្លួន មនុស្សម្នាក់ៗត្រូវមាន គោលដៅ ការលើកទឹកចិត្ត ការស្គាល់ពីខ្លួនឯង និងធ្វើសម្រាប់ប្រយោជន៍រួម។ ការទទួលស្គាល់នូវ លក្ខណៈពិសេសផ្សេងៗគ្នារបស់អ្នកដទៃ គឺបង្ហាញពីការយល់ចិត្តនិងឱ្យតម្លៃដល់អ្នកដទៃ៕

### ៧- វាយតម្លៃ (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើអ្វីជាចំណុចសំខាន់ដើម្បីធ្វើឱ្យមានការឱ្យតម្លៃលើខ្លួនឯង ?

២- តើធ្វើយ៉ាងណាដើម្បីដឹងពីភាពខ្លាំង និងចំណុចខ្វះខាតរបស់ខ្លួនឯង ?

### ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ**

១- តើការឱ្យតម្លៃលើខ្លួនឯងជាអ្វី ? មានប្រភពពីណាខ្លះ ?

២- ចូរអ្នកមើលមេរៀនទំនាក់ទំនង សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ទំនាក់ទំនង

## ខ្លឹមសារម៉ោងទី១ : និយមន័យនៃទំនាក់ទំនងគ្រួសារ និងការគោរពនៅក្នុងគ្រួសារ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ "គ្រួសារ"<br>• រៀបរាប់ពីវិធីសាស្ត្រក្នុងការបង្ហាញពីការគោរពនៅក្នុងគ្រួសារ។ | • បង្ហាញពីទំនាក់ទំនងនិងការគោរពនៅក្នុងគ្រួសារ។ | • បណ្ដុះទម្លាប់ឱ្យមានការទំនាក់ទំនងល្អនៅក្នុងគ្រួសារមានទំនាក់ទំនងមិត្តភាពល្អប្រកប ដោយការជឿជាក់ការគោរពនិងចែករំលែក។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

ទំនាក់ទំនងគ្រួសារ គឺជាទំនាក់ទំនងរវាងក្រុមមនុស្សមួយក្រុម ដែលមានឪពុកម្ដាយ អ្នកអាណាព្យាបាល កូន ជីដូន ជីតា មីង ពូ អ៊ុំ បងប្អូនជីដូនមួយ និងសាច់ថ្លៃ កើតមានឡើងដោយសារការគោរព ការស្រឡាញ់ មានហេតុមានផល និងយកចិត្តទុកដាក់រវាងគ្នានិងគ្នា។

ការគោរពនៅក្នុងគ្រួសារ គឺជាការគោរពគួរសម ការរៀននិយាយដោយមានហេតុផល ការបង្ហាញការយកចិត្តទុកដាក់និងសេចក្ដីស្រឡាញ់ដោយបើកចំហ និងឥរិយាបថគោរពគ្នាដោយមិនប្រកាន់ឋានៈក្នុងគ្រួសារ។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល ការងារជាក្រុម ការពិភាក្សា។

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

ទំនាក់ទំនងមេរៀន (ជំហានទី២)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅសប្ដាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្ដាហ៍មុន? ចម្លើយសិស្ស : ......

៣- តើបច្ចុប្បន្នអ្នករស់នៅជាមួយអ្នកណាខ្លះក្នុងគ្រួសារ?

៤- តើក្នុងគ្រួសារអ្នកមានការគោរពគ្នាយ៉ាងដូចម្ដេចខ្លះ? មានសកម្មភាពអ្វីខ្លះ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន និងគោលបំណងមេរៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យទំនាក់ទំនងគ្រួសារ**

គ្រូសួរសំណួរ តើគ្រួសារមានន័យដូចម្ដេច? ទុកពេល១ទៅ២នាទីរួចហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ

- សិស្សឆ្លើយ : ...................
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ**



គ្រួសារ គឺជាក្រុមមនុស្សមួយក្រុម ដែលមានឪពុកម្ដាយ អ្នកអាណាព្យាបាល និងកូន។ ក្រៅពីនេះមាន ជីដូន ជីតា មីង ពូ អ៊ំ បងប្អូនជីដូនមួយ និងសាច់ថ្លៃ ។ល។ ដែលរស់នៅជាមួយគ្នាក្រោមដំបូលតែមួយ។ ដើម្បីឱ្យការរស់នៅជាមួយគ្នាប្រកបដោយសុខសប្បាយ សមាជិកគ្រួសារម្នាក់ៗ ត្រូវមានការគោរពគ្នា ការស្រឡាញ់ និយាយមានហេតុផល មានទំនួលខុសត្រូវ និងយកចិត្តទុកដាក់រវាងគ្នានិងគ្នា។

**គ្រូពន្យល់សារគន្លឹះ : ការគោរពនៅក្នុងគ្រួសារ** : ដោយប្រកាន់ឥរិយាបថគោរពគ្នាមិនថាកូនឬឪពុក ម្ដាយ និងដោយប្រើពាក្យ "សូម..." ឬ"សូមអភ័យទោស..." និង "អរគុណ"។ ទទួលស្គាល់លើទង្វើរបស់អ្នកដែលមិនត្រូវ និងរៀននិយាយដោយមានហេតុផល ការជឿជាក់ ការគោរព ការអធ្យាស្រ័យ ចែករំលែក ក្នុងមិត្តភាព ការបង្កើតមិត្តថ្មី អាចមានទាំងល្អទាំងអាក្រក់។

- គ្រូសួរសំណួរ : តើការគោរពនៅក្នុងគ្រួសារមានអ្វីខ្លះ? ទុកពេល១ទៅ២នាទីរួចហៅសិស្ស ២-៣នាក់ឱ្យឆ្លើយ។ សិស្សឆ្លើយ : .........................

- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន។

**ចម្លើយ**

ការគោរពនៅក្នុងគ្រួសារមានវិធីបួនយ៉ាងដែលត្រូវអនុវត្តគឺ៖

១- ការគោរពគួរសម

២- រៀននិយាយដោយមានហេតុផល

៣- បង្ហាញការយកចិត្តទុកដាក់ដោយសេចក្ដីស្រឡាញ់ និង

៤- ឥរិយាបថគោរពគ្នាដោយមិនប្រកាន់ឋានៈក្នុងគ្រួសារ។

- គ្រូចែកសិស្សជា៤ក្រុម ឱ្យពិភាក្សាពីឥរិយាបថនៃការគោរពគ្នាទាំង៤ខាងលើ រយៈពេល១០នាទី
  - តំណាងក្រុមនីមួយៗបង្ហាញលទ្ធផល
  - គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ**

- **ការគោរព និងការគួរសម** ដោយប្រើពាក្យ «សូមអធ្យាស្រ័យ...» ឬ«សូមអភ័យទោស» និង «អរគុណ» ប្រើកាយវិការ ភាសា និងសំឡេងឱ្យបានសមរម្យ មិនគំហ៊ក មិនស្រែក និងមិនច្រងេងច្រងាង។
- **រៀននិយាយដោយមានហេតុផល** : ស្តាប់អត្ថន័យការនិយាយរបស់ដៃគូសន្ទនាដោយប្រុងប្រយ័ត្ន
  រៀនដកដង្ហើមវែងៗនៅពេលដែលអ្នកមានភាពតានតឹង មុននឹងនិយាយស្តី ឆ្លើយតបដោយនិយាយមានហេតុផល រាល់ការឆ្លើយតបមិនត្រូវស្រែកតតាំងភ្លាមៗ ដោយមិនទាន់យល់ពីអត្ថន័យច្បាស់លាស់ និយាយទទួលកំហុស ទោះតូចតាចក្តី បង្ហាញពីអារម្មណ៍របស់អ្នកជាជាងបន្ទោសទៅដៃគូសន្ទនា ឧទាហរណ៍ “ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនទទួលបានការគោរព...” ឬ “ ខ្ញុំមិនសប្បាយចិត្ត ព្រោះ...”។
- **បង្ហាញការយកចិត្តទុកដាក់ដោយសេចក្តីស្រឡាញ់** ក្នុងការជួយគាំទ្រនូវអ្វីដែលសមាជិកគ្រួសារដោយជួយធ្វើការងារធ្ងន់ស្រាលក្នុងគ្រួសារ ជួយលើកទឹកចិត្តនៅពេលមានទុក្ខព្រួយ ចំណាយពេលនៅជាមួយគ្នា ជជែកនិងពិភាក្សា ដើម្បីឱ្យបានយល់ពីគ្នាឱ្យបានច្រើន។




- **ប្រកាន់ឥរិយាបថគោរពគ្នា** ដោយមិនប្រកាន់ឋានៈថាកូនឬឪពុកម្តាយ ដោយប្រើពាក្យថា «ស្រឡាញ់» ឧទាហរណ៍ : កូនស្រឡាញ់ម៉ែ ឬពុកស្រឡាញ់កូន។ លើកសរសើរពីគ្នាទៅវិញ



ឥរិយាបថគោរពគ្នាក្នុងគ្រួសារ

ទៅមកនៅពេលសមាជិកណាម្នាក់ធ្វើបានល្អ។ គោរពឯកជនភាពរបស់សមាជិកគ្រួសារម្នាក់ៗ (មុនចូលបន្ទប់ត្រូវជូនដំណឹងឬសញ្ញា)។ រៀនអត់ធ្មត់ស៊ូប្រឈមនឹងបញ្ហាដែលកើតឡើង ហាត់ពត់ចិត្តឱ្យរក្សានូវភាពស្ងប់ នឹងមិនរំជើបរំជួលតាមស្ថានភាព។ គោរពតួនាទីរបស់ខ្លួនដោយមិនប្រើ ឋានៈនៅក្នុងគ្រួសារមកដាក់សម្ពាធ ឧទាហរណ៍ បងបង្ខំឱ្យប្អូនធ្វើអ្វីមួយជំនួសខ្លួន។

❖ គ្រូសំយោគចម្លើយ និងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

គ្រួសារ គឺជាក្រុមមនុស្សមួយក្រុមដែលមានឪពុកម្ដាយ អ្នកអាណាព្យាបាល និងកូន ហើយក៏អាចមានជីដូន ជីតា មីងពូ អ៊ុំ បងប្អូនជីដូនមួយ និងសាច់ថ្លៃ រស់នៅជាមួយគ្នាក្រោមដំបូលតែមួយផងដែរ។ មានវិធីបួនយ៉ាង ដែលបង្ហាញពី ការគោរពនៅក្នុងគ្រួសារ គឺការគោរពនិងការគួរសម រៀននិយាយដោយ មានហេតុផល បង្ហាញការយកចិត្តទុកដាក់និងសេចក្ដីស្រឡាញ់ ឥរិយាបថគោរពគ្នាដោយមិនប្រកាន់ឋានៈក្នុងគ្រួសារ។

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើទំនាក់ទំនងគ្រួសារមានន័យដូចម្ដេច?

២- តើការគោរពនៅក្នុងគ្រួសារមានអ្វីខ្លះ?

## ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនត្រង់ចំណងជើងទំនាក់ទំនងមិត្តភាព សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ទំនាក់ទំនង (តចប់)

## ខ្លឹមសារម៉ោងទី២ : ទំនាក់ទំនងមិត្តភាព

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីទំនាក់ទំនងមិត្តភាព។ | • បកស្រាយពីទំនាក់ទំនងមិត្តភាពល្អ ការជឿជាក់ ការគោរព ការចែករំលែក និងការបង្កើតមិត្តភាព។ | • បណ្តុះទម្លាប់ឱ្យមានការទំនាក់ទំនងល្អនៅក្នុងគ្រួសារ<br>• ទំនាក់ទំនងមិត្តភាពល្អប្រកបដោយការជឿជាក់ ការគោរពនិងចែករំលែក។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

ទំនាក់ទំនងមិត្តភាព មានច្រើនប្រភេទដូចជា មិត្តដែលស្គាល់និងឆ្លងកាត់សុខទុក្ខជាមួយគ្នាយូរអង្វែង មិត្តដែលគ្រាន់តែជាអ្នកស្តាប់រឿងរ៉ាវ គោរពយោបល់ និងការសម្រេចចិត្តរបស់អ្នក មិត្តកំប្លែងសប្បាយ ចំណាយពេលលេង និងសើចរីករាយជាមួយគ្នា មិត្តរួមថ្នាក់ ជួយគ្នាក្នុងការរៀនសូត្រហើយដែលអាចទុកចិត្តបាន មិត្តចែករំលែកចំណេះដឹង ឬផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល ការងារជាក្រុម ការពិភាក្សា។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន បន្ទាប់មកគ្រូសួរៈ តើទំនាក់ទំនងមិត្តភាពមានអ្វីខ្លះ?
- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ

- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្តារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន និងគោលបំណងមេរៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ទំនាក់ទំនងមិត្តភាព**

១- គ្រូសួរសំណួរ : តើមិត្តភាពមានប៉ុន្មានប្រភេទ? ហើយប្រភេទនីមួយៗត្រូវប្រកាន់គោលការណ៍អ្វីខ្លះ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ**

**មិត្តភាពមានច្រើនប្រភេទដូចជា៖**

- មិត្តដែលស្គាល់ និងឆ្លងកាត់សុខទុក្ខជាមួយគ្នាយូរអង្វែង
- មិត្តដែលគ្រាន់តែជាអ្នកស្តាប់រឿងរ៉ាវ គោរពយោបល់ និងការសម្រេចចិត្តរបស់អ្នក
- មិត្តកំប្លែងសប្បាយ ចំណាយពេលលេង និងសើចរីករាយជាមួយគ្នា
- មិត្តរួមថ្នាក់ ជួយគ្នាក្នុងការរៀនសូត្រហើយដែលអាចទុកចិត្តបាន
- មិត្តចែករំលែកចំណេះដឹង ឬផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

**គោលការណ៍ដែលត្រូវប្រកាន់នៅក្នុងមិត្តភាពមាន៖**

- ការគោរព និងយោគយល់ ឬអធ្យាស្រ័យ
- ការជឿជាក់ និង
- ការចែករំលែក



ការចែករំលែកគំនិតគ្នាដោយការគោរពនិងយោគយល់

សកម្មភាព

**សំដែងតួ "ការបង្កើតមិត្តភាព"**

- ជ្រើសរើសយកអ្នកស្ម័គ្រចិត្តពីរនាក់ (ប្រុសម្នាក់ ស្រីម្នាក់) មកសំដែងតួតាមសាច់រឿងខាងក្រោម:

| |
|---|
| កុសលបានទៅលេងស្រុកកំណើតរបស់ម្តាយជាលើកដំបូង គាត់រីករាយណាស់និងនាំកូនឆ្កែស្រស់ស្អាតរបស់គាត់ទៅជាមួយផង។ ព្រលឹមថ្ងៃទី១ គាត់បានបណ្តើរកូនឆ្កែនៅតាមផ្លូវមើលស្រុកភូមិយ៉ាងរីករាយ។ ដារីជាក្មេងស្រីរស់នៅក្នុងភូមិ បានដើរបញ្ច្រាសទិសនឹងកុសល។ ដារីជាក្មេងចូលចិត្តសត្វ ពេលឃើញកូនឆ្កែរបស់កុសល នាងពេញចិត្តយ៉ាងខ្លាំងហើយនិយាយថា៖ |

| ដារី | កុសល |
|---|---|
| • អូហ៎! កូនឆ្កែតូចស្អាតណាស់ ! | |
| • តើអាចឱ្យខ្ញុំលេងវាបន្តិចបានទេ ? | • បាទ បាន! វាស្លូតនិងគួរឱ្យស្រឡាញ់ណាស់ មែនទេ ? |
| • ចា! មែនហើយ តើវាមានអាយុប៉ុន្មាន ? | • បាទវាមានអាយុ៨ខែ ១២ថ្ងៃ ! |
| • អូហ៎! វាគួរឱ្យស្រឡាញ់ណាស់។ តើផ្ទះនៅទីណា! ?ឱ្យខ្ញុំសុំទៅលេងនឹងវារាល់ថ្ងៃបានទេ | • អូ ! ផ្ទះខ្ញុំនៅភ្នំពេញឯណោះទេ ខ្ញុំមកលេងទីនេះបីថ្ងៃ។ មានអីក្នុងកំឡុងប៉ុន្មានថ្ងៃនេះ យើងអាចមកលេងនឹងវាបាន។ |
| • មិនអីទេ បីថ្ងៃក៏បានដែរ។ តើយើងអាចរាប់គ្នាជាមិត្តបានទេ ? | • បាទ ពិតជាបាន។ ! |

- ពេលសំដែងតួចប់ឱ្យសិស្សពិភាក្សារកចំណុចរួម ហេតុអ្វីបានជាដារីនិងកុសលក្លាយជាមិត្ត? គ្រូកត់ចម្លើយនៅលើក្តារខៀន រួចសំយោគចម្លើយសំខាន់ៗដូចជា៖ ពួកគេមានចំណង់ចំណូលចិត្តដូចគ្នា មានការគោរពនិងយោគយល់ មានការជឿជាក់ មានការចែករំលែក។



**មេរៀនសង្ខេប**

ដើម្បីឱ្យទំនាក់ទំនងមិត្តភាព មានភាពល្អប្រសើរ យើងត្រូវប្រកាន់ យកគោលការណ៍៤យ៉ាងគឺ ការជឿជាក់ ការគោរព ការយោគយល់ និងការចែករំលែកគ្នាទៅវិញទៅមក៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

តើមិត្តភាពមានប៉ុន្មានប្រភេទ? ហើយប្រភេទនីមួយៗត្រូវប្រកាន់គោលការណ៍អ្វីខ្លះ?

**៨- លំហាត់** (ជំហានទី៥)

បណ្តាំផ្ញើ : ចូរអ្នកបង្កើនមិត្ត ជាជាងមានសត្រូវ

សំណួរស្រាវជ្រាវ : ចូរអ្នកស្រាវជ្រាវការបង្កើតមិត្តល្អមានអ្វីខ្លះ? គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការបង្កើតមិត្តល្អ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីលក្ខណៈសម្បត្តិមិត្តល្អ សារៈសំខាន់នៃការមានមិត្តល្អ<br>• រៀបរាប់ពីការបង្កើត និងរក្សាមិត្តល្អ។ | • បង្ហាញឥរិយាបថ និង លក្ខណៈសម្បត្តិដើម្បីបង្កើត និងរក្សាមិត្តល្អ។ | • បណ្ដុះគំនិតបង្កើត និងរក្សា ទំនាក់ទំនងមិត្តភាពល្អ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**១- លក្ខណៈសម្បត្តិរបស់មិត្តល្អ** គឺជាមិត្តល្អអាចពឹងពាក់បាន មិនលាក់លៀមនិងគ្នា មានភក្តីភាពចំពោះគ្នា ចេះគោរពគ្នា មានភាពសប្បុរស ចេះជួយការពារគ្នា មានភាពស្មើគ្នា ចេះអត់ឱនឱ្យគ្នា ជាអ្នកស្ដាប់ល្អ និងជួយផ្ដល់ការគាំទ្រដល់មិត្ត។

**២- ដើម្បីបង្កើតនិងរក្សាមិត្តភាពល្អ** អ្នកត្រូវរក្សាទំនាក់ទំនង និងការឆ្លើយតបការសន្ទនារបស់មិត្ត ដោយមិនទុកចោលយូរពេក មិនគួរឃ្លាតឆ្ងាយគ្នាយូរពេក មិនគួរខ្ចីអ្វីៗគ្រប់យ៉ាងញឹកពេកនិងមិនទៀងទាត់ ដែលជាមូលហេតុធ្វើឱ្យទំនាក់ទំនងមិត្តមានការប្រេះឆា រង្គោះរង្គើរ។ សារៈសំខាន់នៃការមានមិត្តល្អធ្វើឱ្យយើងមានភាពរីកចម្រើន សប្បាយចិត្ត មានទំនុកចិត្ត ចែករំលែកសុខទុក្ខ ជួយគាំទ្រលើកទឹកចិត្តពេលយើងមានទុក្ខលំបាក ជួយកាត់បន្ថយភាពតប់ប្រមល់ ធ្វើឱ្យយើងយល់ថាខ្លួនមានតម្លៃ ជួយលើកទឹកចិត្តឱ្យយើងកែប្រែទម្លាប់អាក្រក់របស់យើង។

**៥- វិធីសាស្ត្រ**

ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល ការងារជាក្រុម ការពិភាក្សា ពន្យល់ សម្ដែងតួ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ....

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន រួចសួរ តើការបង្កើតមិត្តល្អមានអ្វីខ្លះ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : លក្ខណៈសម្បត្តិរបស់មិត្តល្អ**



ការបង្កើតមិត្តភាព

- គ្រូពន្យល់ថា នៅពេលឈានចូលវ័យជំទង់ ទំនាក់ទំនងជាមួយមិត្តភក្តិក្លាយជារឿងសំខាន់ណាស់ គឺផ្ដោតលើការយកចិត្តទុកដាក់ក្នុងទំនាក់ទំនងជាមួយមិត្តភក្តិ និងត្រូវពិនិត្យពីប្រភេទមិត្តដែលមានតម្លៃសក្តិសមគួរជាទីរាប់អាន។

- **ការឆ្លុះបញ្ចាំងជាបុគ្គលៈ** សូមធ្វើសកម្មភាពដូចខាងក្រោមៈ
  - គ្រូសរសេរឃ្លានេះនៅលើក្ដារខៀនៈ "...........គឺជាមិត្តល្អរបស់ខ្ញុំ ព្រោះ......." និងចែកក្រដាសឱ្យសិស្សម្នាក់មួយសន្លឹក ដើម្បីសិស្សសរសេរនិងបំពេញឃ្លានោះឱ្យបានពេញលេញ។
  - ប្រាប់សិស្សឱ្យគិតពីនរណាម្នាក់ដែលពួកគេគិតថា គឺជាមិត្តល្អ អាចជាមិត្តជិតស្និទ្ធបំផុតរបស់ខ្លួន ហើយបំពេញឈ្មោះមិត្តជិតស្និទ្ធ និងលក្ខណៈសម្បត្តិ ដែលធ្វើឱ្យមិត្តនោះក្លាយជាមិត្តល្អរបស់ខ្លួន?
  - ប្រាប់សិស្សថា ពុំមាននរណាម្នាក់ដឹងពីចម្លើយរបស់ប្អូន ក្រៅពីគ្រូឡើយ។ បន្ទាប់មក សូមយកក្រដាសដែលបំពេញហើយដាក់ចូលក្នុងថង់
  - គ្រូនឹងអានក្រដាសនីមួយៗ ដោយមិនអានឈ្មោះមិត្តភក្តិ ប៉ុន្តែគ្រូនឹងអានតែលក្ខណៈសម្បត្តិដែលបានសរសេរ
  - គ្រូសំយោគចម្លើយនៅលើក្ដារខៀន។ ឧទាហរណ៍ : សម្រួលប្រយោគ "តែងតែនិយាយការពិតពីអ្វីគ្រប់យ៉ាងប្រាប់ខ្ញុំ" សំយោគទៅជា "ស្មោះត្រង់" ។ "មិនដែលបោះបង់ខ្ញុំចោល" ទៅជា "ការគាំទ្រនិងលើកទឹកចិត្ត"
  - ប្រសិនបើលក្ខណៈសម្បត្តិនោះត្រូវបានលើកឡើងច្រើនដង សូមដាក់សញ្ញាផ្កាយនៅក្បែរពាក្យនោះ ដើម្បីបញ្ជាក់ថា ពាក្យនោះត្រូវបានលើកឡើងច្រើន។
- **ការងារជាក្រុមៈ ការចាត់លំដាប់ថ្នាក់**
  - គ្រូចែកសិស្សទៅជាក្រុមតូចៗ ដោយពិភាក្សារយៈពេល១០នាទី។ ក្រុមនីមួយៗជ្រើសរើស "លក្ខណៈសម្បត្តិ" ចំនួនប្រាំ ហើយដាក់តាមលំដាប់ថ្នាក់ គឺលេខ "១" សម្រាប់លក្ខណៈសម្បត្តិដែលសំខាន់បំផុត និងលេខ "៥" សម្រាប់លក្ខណៈសម្បត្តិសំខាន់តិចជាងគេ
- តំណាងក្រុមនីមួយៗឡើងបកស្រាយលទ្ធផលក្រុម។
- **សំណួរពិភាក្សាៈ បែងចែកសិស្សជាក្រុម ( ពីរក្រុមពិភាក្សា១សំណួរ ) រយៈពេល១០នាទី**

១- តើលក្ខណៈសម្បត្តិរបស់មិត្តល្អមានអ្វីខ្លះ ?

២- ចូររៀបរាប់ពីសារៈសំខាន់នៃការមានមិត្តល្អ ?

៣- តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីបង្កើត និងរក្សាមិត្តភាពល្អឱ្យបានគង់វង្ស ?

- គ្រូសំយោគចម្លើយតាមខ្លឹមសារមេរៀន



**មេរៀនសង្ខេប**

មិត្តល្អអាចពឹងពាក់បាន មិនលាក់លៀមនិងគ្នា មានភក្តីភាពចំពោះគ្នា ចេះគោរពគ្នា មានភាពសប្បុរស ចេះជួយការពារគ្នា មានភាពស្មើគ្នា ចេះអត់ឱនឱ្យគ្នា ជាអ្នកស្ដាប់ល្អ និងជួយផ្ដល់ការគាំទ្រដល់មិត្ត។ ដើម្បីបង្កើតនិងរក្សាមិត្តភាពល្អ អ្នកគួរប្រកាន់យកឥរិយាបថដូចជា ត្រូវរក្សាទំនាក់ទំនង និងការឆ្លើយតបការសន្ទនារបស់មិត្តដោយមិនទុកចោលយូរពេក មិនគួរឃ្លាតឆ្ងាយគ្នាយូរពេក មិនគួរខ្ញីអ្វីៗគ្រប់យ៉ាងញឹកពេកនិងមិនទៀងទាត់ ដែលជាមូលហេតុធ្វើឱ្យទំនាក់ទំនងមិត្តមានការប្រេះឆា រង្គោះរង្គើរ។

**៧- វាយតម្លៃ** ( ជំហានទី៤ )

គ្រូហៅសិស្ស ៣ ឬ៤ នាក់ សរុបឡើងវិញអំពីចំណុចសំខាន់ៗដែលពួកគេបានរៀនសូត្រពីមេរៀននេះ។ បន្ទាប់មកគ្រូបន្ថែមចំណុចដែលពួកគេមិនបានលើកឡើង។

**៨- លំហាត់** ( ជំហានទី៥ )

**កិច្ចការផ្ទះ**

១- ចូរអ្នកស្រាវជ្រាវ តើគុណសម្បត្តិអ្វីខ្លះ ដែលមិត្តភក្តិរបស់អ្នកមាន ដែលធ្វើឱ្យគេជាមិត្តល្អ ?

២- ចូរអ្នកមើលមេរៀនការស្វែងយល់ពីយេនឌ័រ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : ការស្វែងយល់ពីយេនឌ័រ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ "ភេទ និង យេនឌ័រ"<br>• ពណ៌នាពីភាពខុសគ្នារវាងភេទ និងយេនឌ័រ។ | • បង្ហាញបានពីភាពខុសគ្នារវាង ភេទ និងយេនឌ័រ និងគុណតម្លៃ នៃយេនឌ័រ។ | • ស្វែងយល់ពីយេនឌ័រ និង ប្រកាន់ខ្ជាប់ពីគុណតម្លៃនៃ យេនឌ័រ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**ភេទ** : ភាពខុសគ្នាតាមលក្ខណៈជីវសាស្ត្ររវាងមនុស្សប្រុស និងស្រី មានតាំងពីកំណើត ហើយមិនអាចផ្លាស់ប្តូរបាន។

**យេនឌ័រ** : ភាពខុសគ្នារវាងមនុស្សប្រុសនិងមនុស្សស្រី អំពីសិទ្ធិ តួនាទី ការទទួលខុសត្រូវ និងការសម្រេចចិត្ត ដែលកំណត់ដោយសង្គម សាសនា និងវប្បធម៌ ហើយអាចផ្លាស់ប្តូរបាន ព្រោះមិនមែនកើតមានពីធម្មជាតិ។ គុណតម្លៃនៃយេនឌ័រ គឺបុរសនិងស្ត្រីស្មើភាពគ្នាក្នុងសង្គម។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ធ្វើបទបង្ហាញ ធ្វើការជាដៃគូ ពន្យល់ ពិភាក្សា។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......
  ៣- អ្នកធ្លាប់ឮពាក្យ "ភេទ" និង "យេនឌ័រ" រួចមកហើយ ដូច្នេះតើពាក្យទាំងនេះ មានន័យដូចម្តេច? នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីអត្ថន័យរបស់ពាក្យទាំងនេះ ហើយវាជះឥទ្ធិពលយ៉ាងណាខ្លះចំពោះពួកយើង។ គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ

- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យភេទនិងយេនឌ័រ**

- គ្រូសម្របសម្រួល សំយោគ និងសង្ខេបចម្លើយ តាមខ្លឹមសារនៃមេរៀន

- **ភេទ** ៖ ភាពខុសគ្នាតាមលក្ខណៈជីវសាស្ត្រ មានតាំងពីកំណើតហើយមិនអាចផ្លាស់ប្ដូរបាន
- **យេនឌ័រ** ៖ភាពខុសគ្នារវាងក្រុមប្រុស និងក្រុមស្រី ដែលបានកំណត់ដោយសង្គមនិងវប្បធម៌ ដូចជាអាកប្បកិរិយា ការស្លៀកពាក់ ការប្រកបការងារ ការនិយាយស្ដី។ យើងអាចផ្លាស់ប្ដូរកត្តាទាំងនេះបានព្រោះមិនមែនកើតមានពីធម្មជាតិទេ។

**ខ្លឹមសារ : ភាពខុសគ្នារវាងភេទនិងយេនឌ័រ**

- លំហាត់ : ក- គ្រូគូសតារាងខាងក្រោមដាក់លើក្ដារខៀន។ ទុកពេលឱ្យសិស្សគិត ២ទៅ៣នាទីគិត រួចបន្ទាប់មកហៅសិស្សឡើងសរសេរពាក្យក្នុងប្រអប់តារាងខាងក្រោម រួចឡើងបិទលើតារាងឱ្យបានត្រឹមត្រូវ។

| យេនឌ័រ របស់មនុស្សប្រុសនិងមនុស្សស្រី | យេនឌ័រ របស់មនុស្សប្រុស | យេនឌ័រ របស់មនុស្សស្រី |
|---|---|---|
| | | |

- ធ្វើការជាកម្មករ
- មើលថែកូន
- យំ
- ដេរប៉ាក់
- ដាំស្ល
- សើចឮ
- សង់ដំបូល
- ដងទឹក
- រកខុស
- ឆ្ការដីដើម្បីដាំដុះ
- លាងចាន
- និយាយឮ
- ក្លាហាន
- ធ្វើជាអ្នកនយោបាយ
- ធ្វើជាគ្រូបង្រៀន
- ខ្មាសអៀន
- បោកសម្លៀកបំពាក់
- បោចស្មៅ
- ថែទាំសត្វក្នុងកសិដ្ឋាន
- ធ្វើជាគិលានុបដ្ឋាក
- ជាមេដឹកនាំសាសនា
- ជាទាហាន
- រកប្រាក់
- បោសជូត
- បើកឡានដឹក
- ឱ្យអាហារទារក
- រឹងមាំ
- ធ្វើជាលេខា
- ធ្វើជាវេជ្ជបណ្ឌិត
- ធ្វើជាឪពុកម្ដាយ
- ដើរលឿន និងឮ
- អត់ធ្មត់
- អង្គុយបត់ជើង
- ស្មោះមួយទល់នឹងមួយ

| យេនឌ័រ<br>របស់មនុស្សប្រុស និងមនុស្សស្រី | យេនឌ័រ<br>របស់មនុស្សប្រុស | យេនឌ័រ<br>របស់មនុស្សស្រី |
|---|---|---|
| - ធ្វើជាកម្មករ<br>- រកឧស<br>- ឆ្កាព្រៃ<br>- ធ្វើជាអ្នកនយោបាយ<br>- ធ្វើជាគ្រូបង្រៀន<br>- បោចស្មៅ<br>- ថែទាំសត្វក្នុងកសិដ្ឋាន<br>- ធ្វើជាគិលានុបដ្ឋាក<br>- មេដឹកនាំសាសនា<br>- ធ្វើវេជ្ជបណ្ឌិត | - សើចឮ<br>- និយាយឮ<br>- ក្លាហាន<br>- រឹងមាំ<br>- ដើរលឿន និងឮ<br>- សង់ដំបូលផ្ទះ<br>- ធ្វើទាហាន<br>- រកប្រាក់<br>- បើកឡានដឹកទំនិញ | - យំ<br>- ខ្មាសអៀន<br>- អត់ធ្មត់<br>- អង្គុយបត់ជើង<br>- ទន់ភ្លន់<br>- ស្មោះត្រង់មួយទល់មួយ<br>- បោសជូត<br>- ដាំស្ល<br>- ឱ្យអាហារទារក<br>- ធ្វើការលេខាធិការ<br>- មើលថែកូន<br>- ដេរប៉ាក់<br>- លាងចាន<br>- បោកសម្លៀកបំពាក់ |

**ខ្លឹមសារ : គុណតម្លៃនៃយេនឌ័រ**

- **ការងារជាដៃគូ** : ក្មេងស្រីចាប់ដៃគូជាមួយក្មេងស្រី ក្មេងប្រុសចាប់ដៃគូជាមួយក្មេងប្រុស រួចនិយាយទៅកាន់គ្នាទៅវិញទៅមកតាមខ្លឹមសារដូចខាងក្រោម ៖
  - ប្រាប់ក្មេងស្រីឱ្យនិយាយទៅកាន់គ្នាថា៖
    - ខ្ញុំរីករាយដែលខ្ញុំជាក្មេងស្រី ព្រោះ ...
    - ខ្ញុំប្រាថ្នាចង់ក្លាយជាក្មេងប្រុស ព្រោះ ...
  - ប្រាប់ក្មេងប្រុសឱ្យនិយាយទៅកាន់គ្នាថា៖
    - ខ្ញុំរីករាយដែលខ្ញុំជាក្មេងប្រុស ព្រោះ ...
    - ខ្ញុំប្រាថ្នាចង់ក្លាយជាក្មេងស្រី ព្រោះ ...
    - .........................................................................។
  - ឱ្យសិស្សឡើងចែករំលែកពីលទ្ធផលនៃការពិភាក្សាដល់ក្រុមធំ តាមការស្ម័គ្រចិត្ត។
  - គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



## មេរៀនសង្ខេប

ភេទ : ភាពខុសគ្នាតាមលក្ខណៈជីវសាស្ត្ររវាងមនុស្សប្រុស និងស្រី មានតាំងពីកំណើត ហើយមិនអាចផ្លាស់ ប្តូរបាន។

យេនឌ័រ : ភាពខុសគ្នារវាងមនុស្សប្រុស និងមនុស្សស្រី អំពីសិទ្ធិ តួនាទី ការទទួលខុសត្រូវ និងការសម្រេចចិត្ត ដែលកំណត់ដោយសង្គម សាសនានិងវប្បធម៌ ហើយអាចផ្លាស់ប្តូរបាន ព្រោះមិនមែនកើតមានពីធម្មជាតិ។ គុណតម្លៃយេនឌ័រ : បុរសនិងស្ត្រីស្មើភាពគ្នាក្នុងសង្គម។ មនុស្សគ្រប់រូប ទាំងប្រុស ស្រី និងភេទដទៃទៀត (ភេទទី៣) មានសិទ្ធិស្មើគ្នា និងទទួលបានការគោរពស្រឡាញ់ ការលើកទឹកចិត្តពីសង្គមដូចគ្នា លើអ្វីដែលពួកគេចង់ធ្វើនិងគោលដៅរបស់គេនាពេលអនាគត៕

### ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ចូរបង្ហាញពីភាពខុសគ្នារវាងភេទនិងយេនឌ័រ?

២- តើអ្នកធ្វើដូចម្តេចខ្លះ ដើម្បីបង្កើនការយល់ដឹងនិងឱ្យតម្លៃយេនឌ័រ?

### ៨- **លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ឱ្យសិស្សយកចំណេះដឹងពីមេរៀននេះ ទៅចែករំលែកដល់សមាជិកគ្រួសារនិងមិត្តភក្តិ

**សំណួរ** : ដើម្បីលើកកម្ពស់សមភាពយេនឌ័រ តើប្អូនគួរធ្វើអ្វីខ្លះ? ចូររៀបរាប់?

**កិច្ចការផ្ទះ** : ចូរប្អូនមើលមេរៀនការគោរពគ្នាទៅវិញទៅមក សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៤ : ការគោរពគ្នាទៅវិញទៅមក

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យការគោរពគ្នាទៅវិញទៅមក<br>• រៀបរាប់ពីឥរិយាបថនិងសារៈសំខាន់នៃការគោរពគ្នាទៅវិញទៅមក។ | • បង្ហាញពីឥរិយាបថនៃការគោរពគ្នាទៅវិញទៅមក។ | • បណ្ដុះទម្លាប់ប្រាស្រ័យទាក់ទងប្រកបដោយការគោរពគ្នាទៅវិញទៅមក។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- **ការគោរពគ្នាទៅវិញទៅមក** មានន័យថា ជាការប្រព្រឹត្តល្អប្រកបដោយការយកចិត្តទុកដាក់រវាងគ្នានិងគ្នា និងបង្ហាញពីការឱ្យតម្លៃដល់មនុស្សគ្រប់រូប ចំពោះជំនឿ គំនិត និងរបៀបរស់នៅ បើទោះបីជាពួកគេខុសប្លែកពីយើង ឬទោះបីជាពួកយើងពុំយល់ស្របជាមួយគំនិត ឬជំនឿរបស់ពួកគេក្ដី។
- **សារៈសំខាន់ក្នុងការគោរពសិទ្ធិគ្នាទៅវិញទៅមក** គឺដើម្បីបញ្ឈប់គំនិតបុរេនិច្ឆ័យការរើសអើងនឹងជួយឱ្យមនុស្សមានអារម្មណ៍រីករាយ ចំពោះខ្លួនឯង គ្រួសារ វប្បធម៌ ជំនឿសាសនា គ្មានការបង្កជំលោះ គ្មានអំពើហិង្សា ធ្វើឱ្យមនុស្សគ្រប់រូបរស់នៅក្នុងសន្តិភាពនិងសេចក្ដីថ្លៃថ្នូរ ។

**៥- វិធីសាស្ត្រ**

ការងារជាដៃគូ សំណួរនិងចម្លើយ បទបង្ហាញខ្នាតតូច ការបំផុសគំនិត ការសម្ដែងតួ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្ដាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្ដាហ៍មុន? ចម្លើយសិស្ស : ......

៣- តើក្នុងគ្រួសាររបស់អ្នកមានការគោរពគ្នាដោយរបៀបណា?

៤- តើមិត្តភ័ក្តិរបស់អ្នកបង្ហាញការគោរពគ្នាដោយរបៀបណា? គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ។

- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្តារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ការគោរពគ្នាទៅវិញទៅមក**

- **គ្រូពន្យល់:** លក្ខណៈដូចគ្នា និងខុសគ្នាខាងលើនេះ ធ្វើឱ្យយើងម្នាក់ៗ ឬគ្រួសារមានលក្ខណៈ ជារបស់ខ្លួនខុសប្លែកពីគេ ដែលយើងត្រូវទទួលស្គាល់ និងមិនត្រូវរើសអើងអ្នកដទៃ។
- គ្រូសួរ : តើ "ការគោរពគ្នាទៅវិញទៅមក" មានន័យដូចម្តេច?
- គ្រូឱ្យសិស្សចាប់ដៃគូពីរនាក់ពិភាក្សាគ្នារកចម្លើយក្នុងរយៈពេល ១ទៅ២ នាទី។ រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់តំណាងឱ្យដៃគូ ឱ្យឆ្លើយ
- គ្រូសម្របសម្រួល សំយោគ និងសង្ខេបចម្លើយតាមខ្លឹមសារនៃមេរៀន

**ចម្លើយ**

«ការគោរពគ្នាទៅវិញទៅមក មានន័យថាជាការប្រព្រឹត្តល្អប្រកបដោយសេចក្តីមេត្តា ករុណា ការយកចិត្តទុកដាក់រវាងគ្នា និងបង្ហាញការឱ្យតម្លៃដល់មនុស្សគ្រប់រូបចំពោះជំនឿ គំនិត និងរបៀបរស់នៅ បើទោះបីជាពួកគេខុសប្លែកពីយើង ឬបើទោះបីជាពួកយើងពុំយល់ស្របជាមួយគំនិត ឬជំនឿរបស់ពួកគេក្តី»។



**ខ្លឹមសារ : ឥរិយាបថនៃការគោរពគ្នាទៅវិញទៅមក**

- គ្រូចែកសិស្សជាក្រុមតូចៗ ពិភាក្សាលើសំណួរខាងក្រោមក្នុងរយៈពេល១០នាទី៖
  - ១- តើឥរិយាបថនៃការគោរពគ្នាទៅវិញទៅមកមានអ្វីខ្លះ?
  - ២- ចូររៀបរាប់ពីសារៈសំខាន់នៃការគោរពគ្នាទៅវិញទៅមក?
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួលចម្លើយតាមខ្លឹមសារនៃមេរៀន ដោយលើកយករូបភាពមកបញ្ជាក់

ចម្លើយ :

ឥរិយាបថសំខាន់ៗមួយចំនួនដើម្បីបង្ហាញពីការគោរពគ្នាទៅវិញទៅមកមាន៖

- ស្តាប់គ្នាទៅវិញទៅមកដោយយកចិត្តទុកដាក់
- គោរពភាពខុសគ្នារវាងបុគ្គលនិងបុគ្គល (ភាពខុសៗគ្នាក្នុងចំណោមក្មេងប្រុសៗនិងភាព ខុសៗគ្នាក្នុងចំណោមក្មេងស្រីៗ)



- សរសើររាល់គំនិតល្អៗរបស់គ្នាទៅវិញទៅមក
- ឱ្យតម្លៃនិងគាំទ្រទស្សនៈយល់ឃើញរបស់អ្នកដទៃ
- ការយល់ពីអារម្មណ៍និងលើកទឹកចិត្តអ្នកដទៃ
- ប្រើកាយវិការនិងសម្តីទន់ភ្លន់។



**ឥរិយាបថដែលមិនគួរធ្វើរមមាន** : ការទម្លាក់កំហុសដល់អ្នកដទៃ ស្តីបន្ទោស ចំអកឡកឡឺយ ធ្វើបាប ឬប្រមាថអ្នកដទៃ ប្រកាន់យកឈ្នះរៀងៗខ្លួន សម្លុតឬគំរាមកំហែងអ្នកដទៃ បៀតបៀនកេរ្តិ៍ខ្មាស់អ្នកដទៃនិយាយក្រោយខ្នងឬដាក់សម្ពាធអ្នកដទៃឱ្យធ្វើអ្វីម៉្យាងដែលពួកគេមិនចង់ធ្វើ។

ការស្តីបន្ទោស



**ខ្លឹមសារ : សារៈសំខាន់នៃការគោរពគ្នាទៅវិញទៅមក**

- គ្រូសួរសំណួរ តើការគោរពគ្នាទៅវិញទៅមកផ្តល់សារៈសំខាន់សម្រាប់មនុស្សគ្រប់រូបដូចម្តេចខ្លះ ?
- គ្រូឱ្យសិស្សចាប់ដៃគូពីរនាក់ពិភាក្សាគ្នារកចម្លើយក្នុងរយៈពេល ១ទៅ២ នាទី។ រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់តំណាងឱ្យដៃគូរ ឱ្យឆ្លើយ
- គ្រូសម្របសម្រួល សំយោគ និងសង្ខេបចម្លើយ តាមខ្លឹមសារនៃមេរៀន

**ចម្លើយ**

ជាការសំខាន់ណាស់ដែលត្រូវប្រព្រឹត្តចំពោះមនុស្សគ្រប់រូបដោយមានការគោរពនិងសេចក្តីថ្លៃថ្នូរ។ ការប្រព្រឹត្តល្អនេះ នឹងបង្ហាញការឱ្យតម្លៃដល់រូបគេ មិនថាពួកគេដូចឬខុសប្លែកពីយើងឡើយ។ ការគោរពគ្នាទៅវិញទៅមករបស់មនុស្សគ្រប់រូបមានសារៈសំខាន់ណាស់ ដើម្បីបញ្ឈប់គំនិត បុរេនិច្ឆ័យការរើសអើងនឹងជួយឱ្យមនុស្សមានអារម្មណ៍រីករាយ ចំពោះខ្លួនឯង គ្រួសារ វប្បធម៌ ជំនឿសាសនា គ្មានការបង្កជម្លោះ គ្មានអំពើហិង្សា ធ្វើឱ្យមនុស្សគ្រប់រូបរស់នៅក្នុងសន្តិភាពនិងសេចក្តីថ្លៃថ្នូរ ។ យើងមានភារកិច្ចត្រូវបង្កើតសង្គម ឬសហគមន៍មួយ ដែលមនុស្សគ្រប់រូបត្រូវបានចាត់ទុកថា មានសេចក្តីថ្លៃថ្នូរនិងទទួលបានការគោរព។ យើងទាំងអស់គ្នាចាំបាច់ត្រូវរក្សា ការប្តេជ្ញាចិត្តរបស់យើងចំពោះគោលដៅនេះ ព្រោះថា យើងទាំងអស់គ្នាសុទ្ធតែមានលក្ខណៈពិសេសសក្តិសមនឹងទទួលបានការគោរព។

គ្រូសរុបខ្លឹមសារមេរៀនដោយឱ្យសិស្សរំលឹកឡើងវិញអំពីអ្វីដែលពួកគេបានរៀននិងបន្ថែមចំណុចសំខាន់ៗទាំងឡាយណាដែលពួកគេរំលងនិងពន្យល់ថា ការរើសអើងកើតមានជាសាមញ្ញក្នុងគ្រប់សង្គមទាំងអស់ ហើយយើងចាំបាច់ត្រូវខិតខំកែតម្រូវ ព្រោះថាយើងទាំងអស់សុទ្ធតែទទួលបានអត្ថប្រយោជន៍ និងមានអារម្មណ៍រីករាយនៅពេលមនុស្សទាំងអស់បានទទួលការប្រព្រឹត្តល្អចំពោះខ្លួន។

- ការបង្កើតពិភពលោកមួយដែលមនុស្សគ្រប់រូបបានទទួលការប្រព្រឹត្តចំពោះខ្លួនប្រកបដោយសេចក្ដីថ្លៃថ្នូរ និងការគោរព ត្រូវការកិច្ចខិតខំជាបន្តបន្ទាប់។
- យើងទាំងអស់គ្នាត្រូវរួមគ្នា និងខិតខំជាលក្ខណៈបុគ្គល ដើម្បីរក្សាការប្ដេជ្ញាចិត្តរបស់យើងចំពោះគោលដៅនេះ និងត្រូវរលឹកគ្នាទៅវិញទៅមក និងរំលឹកខ្លួនឯងនៅពេលចាំបាច់។

• គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប



**មេរៀនសង្ខេប**

ការគោរពគ្នាទៅវិញទៅមកមានន័យថា ជាការប្រព្រឹត្តល្អប្រកបដោយសេចក្ដីមេត្តាករុណា ការយកចិត្ត ទុកដាក់រវាងគ្នា និងបង្ហាញពីការឱ្យតម្លៃដល់មនុស្សគ្រប់រូប ចំពោះជំនឿ គំនិត និងរបៀបរស់នៅ។ ឥរិយាបថនៃការគោរពគ្នាមានដូចជា ការស្ដាប់ ការឱ្យតម្លៃ ការយកចិត្តទុកដាក់ និងយល់អំពីអារម្មណ៍របស់អ្នកដទៃ។ ការគោរពគ្នាទៅវិញទៅមក មានសារៈសំខាន់ណាស់ ដើម្បីបញ្ឈប់គំនិតបុរេនិច្ឆ័យ ការរើសអើង និងជួយឱ្យយើងមានអារម្មណ៍រីករាយចំពោះខ្លួនឯង គ្រួសារ វប្បធម៌ ជំនឿសាសនា គ្មានការបង្កជម្លោះ គ្មានអំពើហិង្សា ធ្វើឱ្យមនុស្សគ្រប់រូបរស់នៅក្នុងសន្តិភាពនិងសេចក្ដីថ្លៃថ្នូរ។

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្ស២ឬ៣នាក់ឆ្លើយឡើងវិញនឹងសំណួរៈ

១- តើការគោរពគ្នាទៅវិញទៅមកទទួលបានផលអ្វីខ្លះ ?

២- តើសកម្មភាពអ្វីខ្លះដែលបង្ហាញពីការមិនគោរពគ្នាទៅវិញទៅមក ?

## ៨- លំហាត់ (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកធ្វើការគោរពគ្នាទៅវិញទៅមកដោយយកអ្វីដែលយើងបានរៀនមកអនុវត្ត។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការប៉ះពាល់ដោយសុជីវធម៌ និងខ្វះសុជីវធម៌ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៥ : ការប៉ះពាល់ដោយសុជីវធម៌ និងខ្វះសុជីវធម៌

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីការប៉ះពាល់ដោយសមរម្យ និង មិនសមរម្យ។ | • បង្ហាញពីការប៉ះពាល់ដោយសមរម្យ និងមិនសមរម្យ។ | • បណ្តុះស្មារតីដំណោះស្រាយនៅពេលមានការប៉ះពាល់ដោយមិនសមរម្យ ឬបំពាន។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

ការប៉ះពាល់ដោយសុជីវធម៌ ឬការប៉ះពាល់ដោយសមរម្យ គឺជាការប៉ះពាល់ទាំងឡាយណាដែលធ្វើឱ្យអ្នកមានអារម្មណ៍រីករាយ កក់ក្តៅ និងសុវត្ថិភាពនៅក្នុងចិត្ត។

ការប៉ះពាល់ដោយខ្វះសុជីវធម៌ ឬការប៉ះពាល់បំពាន គឺជាការប៉ះពាល់ទាំងឡាយណា ដែលមិនមានសុវត្ថិភាព មិនសមរម្យ ធ្វើឱ្យមានអារម្មណ៍ឈឺចាប់ក្នុងចិត្ត ឬភ័យខ្លាច។ ការប៉ះពាល់ទាំងនេះ រាប់បញ្ចូលទាំងការប៉ះពាល់ផ្នែកឯកជននៃរាងកាយផងដែរ ដែលយើងពុំចង់ឱ្យនរណាម្នាក់ សូម្បីតែមិត្តភក្តិ ឬសមាជិកគ្រួសារប៉ះពាល់ដោយគ្មានការអនុញ្ញាត។

**៥- វិធីសាស្ត្រ**

សន្លឹកកិច្ចការ ការធ្វើបទបង្ហាញខ្នាតតូច ការងារជាក្រុម ពន្យល់ សំណួរ និងចម្លើយ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : ......
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន ? ចម្លើយសិស្ស : ......
  ៣- តើឪពុកម្តាយអ្នកបង្ហាញពីសេចក្តីស្រលាញ់ដោយរបៀបណា ?
  ៤- តើមិត្តភ័ក្តិអ្នកបង្ហាញពីសេចក្តីស្រលាញ់និងការគោរពគ្នាដោយរបៀបណា ?
  ៥- តើអ្នកមានអារម្មណ៍បែបណាពីការប៉ះពាល់ដល់រាងកាយប្អូនពីឪពុកម្តាយ ឬមិត្តភ័ក្តិ ?
- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ការប៉ះពាល់ដោយសុជីវធម៌ ឬការប៉ះពាល់ដោយសមរម្យ**

១- គ្រូពន្យល់ ការប៉ះពាល់ជាច្រើនប្រភេទផ្សេងៗគ្នា ដូចជា៖

- **ការប៉ះពាល់ដោយសមរម្យ** គឺជាការប៉ះពាល់ទាំងឡាយណាដែលធ្វើឱ្យអ្នកមានអារម្មណ៍រីករាយ កក់ក្តៅ និងសុវត្ថិភាពនៅក្នុងចិត្ត។ ឧ. ម្តាយថើបកូនរបស់ខ្លួន។ តើមានឧទាហរណ៍ណាមួយផ្សេងទៀតឬទេ ?



ឪពុកម្តាយឱបកូន



បងប្រុសឱបប្អូន



ការប៉ះពាល់ល្អ

- **ការប៉ះពាល់ដោយមិនសមរម្យ ឬបំពាន** គឺជាការប៉ះពាល់ទាំងឡាយណា ដែលមិនមានសុវត្ថិភាព មិនសមរម្យ ធ្វើឱ្យមានអារម្មណ៍ឈឺចាប់ក្នុងចិត្ត ឬភ័យខ្លាច។ ការប៉ះពាល់ទាំងនេះ រាប់បញ្ចូលទាំងការប៉ះពាល់ផ្នែកឯកជននៃរាងកាយផងដែរ ដែលយើងពុំចង់ឱ្យនរណាម្នាក់ សូម្បីតែមិត្តភក្តិ ឬសមាជិកគ្រួសារប៉ះពាល់ដោយគ្មានការអនុញ្ញាត។ ឧទាហរណ៍: បងជីដូនមួយដែលមានអាយុច្រើន ប៉ះពាល់សរីរាង្គភេទរបស់ប្អូនជីដូនមួយដែលមានវ័យតិចជាង។ ពុំមាននរណាម្នាក់គួរប៉ះពាល់កន្លែងទាំងអស់នេះទេ លើកលែងតែអ្នកបានផ្តល់ការអនុញ្ញាតឱ្យពួកគេ ហើយការប៉ះពាល់នោះ គឺផ្អែកលើហេតុផលដ៏ល្អ ឧទាហរណ៍: គ្រូពេទ្យអាចប៉ះពាល់ផ្នែកឯកជនរបស់អ្នក ដោយមានការអនុញ្ញាតពីអ្នក ដើម្បីពិនិត្យសុខភាព។ ប្រសិនបើនរណាម្នាក់ប៉ះពាល់ផ្នែកឯកជនរបស់អ្នក ដោយពុំមានការអនុញ្ញាតនោះ គឺជាការប៉ះពាល់ដោយខ្វះសុជីវធម៌ ឬការប៉ះពាល់បំពាន។



មនុស្សធំសម្រាតខោកូនក្មេងជាការលេងសើច



មនុស្សធំបង្ខំឱ្យកុមារប៉ះប្រដាប់ភេទរបស់ខ្លួន



ការសើយសំពត់ក្មេងស្រីជាការលេងសើច



ប៉ះពាល់មិនល្អ

**២- គ្រូចែកសន្លឹកកិច្ចការ៖** ចែកឯកសារសន្លឹកកិច្ចការ «រាងកាយរបស់ខ្ញុំជាកម្មសិទ្ធិរបស់ខ្ញុំ!»។ ប្រាប់សិស្សឱ្យអានការណែនាំ។ សួរសិស្ស តើពួកគេមានសំណួរអ្វីឬទេ? ទុករយៈពេល ៥នាទី បន្ទាប់មកប្រាប់សិស្សឱ្យប្រៀបធៀបគំនូររបស់ខ្លួនជាមួយគំនូររបស់អ្នកអង្គុយក្បែរខ្លួន និងពិនិត្យមើលថា តើមានភាពខុសគ្នាណាមួយឬទេ?

**ការណែនាំ៖** សូមគូសគំនូសបន្ទាត់បញ្ឆិតនៅលើផ្នែកនៃរាងកាយ ដែលអ្នកមិនប្រកាន់ពេលគ្រួសារ មិត្តភក្តិ និងអ្នកជិតស្និទ្ធជាមួយអ្នកដទៃទៀត ប៉ះពាល់នៅត្រង់កន្លែងទាំងនោះ ដើម្បីបង្ហាញក្តីស្រឡាញ់ ដើម្បីទាញចំណាប់អារម្មណ៍របស់អ្នក ឬដើម្បីឱ្យអ្វីម្យ៉ាងទៅអ្នក។ សូមគូសគំនូសស្រមោលនៅផ្នែកទាំងឡាយណាដែលអ្នកពុំចង់ឱ្យមិត្តភក្តិ ឬគ្រួសារប៉ះពាល់នៅពេលនេះ ដោយសារអ្នកធំហើយ។ ចំពោះក្មេងស្រី សូមប្រើរូបភាពមនុស្សស្រី។ ក្មេងប្រុស សូមប្រើរូបភាពមនុស្សប្រុស។




រាងកាយរបស់ខ្ញុំ

**៣- គ្រូសួរសំណួរ** : ប្រសិនបើមាននរណាម្នាក់ប៉ះពាល់ក្នុងលក្ខណៈខុសឆ្គង តើអ្នកត្រូវធ្វើដូចម្តេចខ្លះ? គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ ។ ចម្លើយសិស្ស...

- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្តារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ**

**ប្រសិនបើមាននរណាម្នាក់ប៉ះពាល់ក្នុងលក្ខណៈខុសឆ្គង យើងត្រូវ៖**

- និយាយថា ទេ! ប្រាប់ជននោះថា "ខ្ញុំមិនចូលចិត្តទេ ដែលអ្នកប៉ះពាល់ខ្ញុំបែបនេះ"។
- ដើរឬគេចចេញឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។ អ្នកមិនត្រូវនៅតែម្នាក់ឯងជាមួយជននោះម្តងទៀតឡើយ។
- ស្រែកឱ្យគេជួយ។ ឧទាហរណ៍ ស្រែកខ្លាំងៗថា ជួយផងៗ ...!

- សូមជឿជាក់លើខ្លួនឯងថា អ្នកពុំបានធ្វើអ្វីខុសទេ។ រឿងនេះកើតឡើងចំពោះអ្នក ពុំមែនដោយសារកំហុសរបស់អ្នកឡើយ។
- ប្រាប់នរណាម្នាក់ដែលអ្នកទុកចិត្តអំពីអ្វីដែលបានកើតឡើង។ កុំបណ្តោយឱ្យការគំរាមមកបំភ័យអ្នកឱ្យរក្សាភាពស្ងៀមស្ងាត់។
- មិនត្រូវរក្សាការសម្ងាត់ណាដែលធ្វើឱ្យអ្នកមានអារម្មណ៍ពុំស្រួលក្នុងខ្លួននោះឡើយ។ ត្រូវប្រាប់ការសម្ងាត់នោះទៅមនុស្សដែលអ្នកទុកចិត្តដូចជាឪពុកម្តាយ សាច់ញាតិ ឬគ្រូបង្រៀន។
- ធ្វើគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីនៅឱ្យឆ្ងាយពីជនដែលប៉ះពាល់អ្នកក្នុងលក្ខណៈមិនត្រឹមត្រូវ ឬធ្វើឱ្យអ្នកមិនស្រួលក្នុងចិត្ត។
- សូមកុំនៅតែម្នាក់ឯងជាមួយជនដែលប៉ះពាល់អ្នក និងធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ ឬធ្វើឱ្យអ្នកមានអារម្មណ៍ពុំមានសុវត្ថិភាព។

❖ គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប



**មេរៀនសង្ខេប**

**ការប៉ះពាល់ដោយសុជីវធម៌ ឬការប៉ះពាល់ដោយសមរម្យ** គឺជាការប៉ះពាល់ទាំងឡាយណាដែលធ្វើឱ្យអ្នកមានអារម្មណ៍រីករាយ កក់ក្តៅ និងសុវត្ថិភាពនៅក្នុងចិត្ត ឧ. ឪពុកម្តាយថើបកូនរបស់ខ្លួន។ **ការប៉ះពាល់ដោយខ្វះសុជីវធម៌ ឬការប៉ះពាល់បំពាន** គឺជាការប៉ះពាល់ទាំងឡាយណា ដែលមិនមានសុវត្ថិភាព មិនសមរម្យ ធ្វើឱ្យមានអារម្មណ៍ឈឺចាប់ក្នុងចិត្ត ឬភ័យខ្លាច។ ការប៉ះពាល់ទាំងនេះ រាប់បញ្ចូលទាំងការប៉ះពាល់ផ្នែកឯកជន នៃរាងកាយផងដែរ ។ រាងកាយរបស់អ្នកជាកម្មសិទ្ធិរបស់ អ្នក។ ផ្នែកមួយចំនួននៃរាងកាយរបស់អ្នក ជាផ្នែកឯកជន គ្មាននរណាអាចប៉ះពាល់ដោយគ្មានការអនុញ្ញាតឡើយ ៕

## ៧- វាយតម្លៃ (ជំហានទី៤)

- **សន្លឹកកិច្ចការៈ ប្រភេទនៃការប៉ះពាល់**
- **ការណែនាំៈ** សូមពិភាក្សាលើឧទាហរណ៍នីមួយៗនៃការប៉ះពាល់ នៅក្នុងក្រុមរបស់អ្នក និងសម្រេចចិត្តថា តើនោះជាការប៉ះពាល់ល្អ ឬការប៉ះពាល់មានសុវត្ថិភាព ការប៉ះពាល់ធ្វើឱ្យភាន់ច្រឡំ ឬការប៉ះពាល់អាក្រក់ ឬមិនមានសុវត្ថិភាព។ សូមសរសេរចម្លើយរបស់ក្រុមអ្នកនៅក្នុងតួឡោននៅខាងស្តាំដៃ។

| ឧទាហរណ៍នៃការប៉ះពាល់ | ប្រភេទនៃការប៉ះពាល់ |
|---|---|
| ១- ឪពុកថើបកូនស្រីរបស់ខ្លួនមុនពេលចូលគេង | |

| ឧទាហរណ៍នៃការប៉ះពាល់ | ប្រភេទនៃការប៉ះពាល់ |
|---|---|
| ២- វេជ្ជបណ្ឌិតពិនិត្យប្រដាប់ភេទរបស់កុមារ ដោយមានឳពុកម្តាយកុមារនៅក្នុងបន្ទប់ | |
| ៣- មិត្តភក្តិរបស់ឳពុកក្មេងស្រីម្នាក់ថើបមាត់ក្មេងស្រីនោះ | |
| ៤- ដៃរបស់បងប្អូនជីដូនមួយប៉ះបរិវេណឯកជនរបស់បងប្អូនជីដូនមួយខ្លួនបន្តិចនៅពេលចាក់ក្រឡេកនៅត្រង់ពោះ | |
| ៥- ជីដូន ឬជីតាប៉ះពាល់ប្រដាប់ភេទចៅរបស់ខ្លួននៅលើគ្រែនៅពេលយប់ | |
| ៦- មិត្តភក្តិឳពុកជាបុរសឱបក្មេងស្រីយ៉ាងជំទង់ | |
| ៧- ម្តាយឱបកូនប្រុសរបស់ខ្លួនមុនពេលបែកគ្នា | |
| ៨- ដៃរបស់មិត្តភក្តិម្នាក់ប៉ះប្រដាប់ភេទរបស់មិត្តភក្តិខ្លួនពេលកំពុងលេងបោកចំបាប់ | |
| ៩- អ្នកជិតខាងបង្ខំក្មេងស្រី ឬក្មេងប្រុសវ័យជំទង់ឱ្យរួមភេទ | |
| ១០- បងស្រីសិតសក់ឱ្យប្អូនស្រីរបស់នាង | |
| ១១- ជនមិនដែលស្គាល់មុខម្នាក់រុញប្រដាប់ភេទរបស់ខ្លួនទៅបុកនរណាម្នាក់នៅលើឡានក្រុងដែលមានមនុស្សកកកុញ | |
| ១២- ដៃរបស់គ្រូបង្រៀនម្នាក់ប៉ះទ្រូងសិស្សស្រីម្នាក់ដែលកំពុងជួយដោះស្រាយលំហាត់គណិតវិទ្យារបស់នាង | |
| ១៣- គ្រូបង្រៀនម្នាក់ដាក់ដៃរបស់នាងនៅលើខោ ឬសំពត់របស់អ្នកសិក្សា | |
| ១៤- ឳពុកមាម្នាក់អង្អែលខ្នងក្មួយប្រុសរបស់ខ្លួនពេលនៅតែពីរនាក់ | |
| ១៥- មិត្តភក្តិកាន់ដៃគ្នាពេលដើរតាមផ្លូវ | |

- **គន្លឹះចម្លើយរបស់គ្រូ**

| ការប៉ះពាល់សមរម្យ | ការប៉ះពាល់ដែលធ្វើឱ្យភាន់ច្រឡំ | ការប៉ះពាល់មិនសមរម្យ ឬការបំពាន |
|---|---|---|
| ១- ឳពុកថើបកូនស្រីរបស់ខ្លួនមុនពេលចូលគេង | ៤- ដៃរបស់បងប្អូនជីដូនមួយម្នាក់ប៉ះបរិវេណឯកជនរបស់បងប្អូនជីដូនមួយបន្តិចនៅពេលចាក់ក្រឡេកនៅត្រង់ពោះ | ៣- មិត្តភក្តិរបស់ឳពុកក្មេងស្រីម្នាក់ថើបមាត់ក្មេងស្រីនោះ |

| ការប៉ះពាល់សមរម្យ | ការប៉ះពាល់ដែលធ្វើឱ្យភាន់ច្រឡំ | ការប៉ះពាល់មិនសមរម្យ ឬការបំពាន |
|---|---|---|
| ២- វេជ្ជបណ្ឌិតពិនិត្យប្រដាប់ភេទរបស់កុមារ ដោយមានឪពុកម្ដាយកុមារនៅក្នុងបន្ទប់ | ៦- មិត្តភក្តិរបស់ឪពុកជាបុរសឱបក្មេងស្រីយំជំទង់ | ៥- ជីដូន ឬជីតាប៉ះពាល់ប្រដាប់ភេទចៅរបស់ខ្លួននៅលើគ្រែនៅពេលយប់ |
| ៧- ម្ដាយឱបកូនប្រុសរបស់ខ្លួនមុនពេលបែកគ្នា | ៨- ដៃរបស់មិត្តភក្តិម្នាក់ប៉ះប្រដាប់ភេទរបស់មិត្តភក្តិខ្លួនពេលកំពុងលេងបោកចំបាប់ | ៩- អ្នកជិតខាងបង្ខំក្មេងស្រី ឬក្មេងប្រុសវ័យជំទង់ឱ្យរួមភេទ |
| ១០- បងស្រីសិតសក់ឱ្យប្អូនស្រីរបស់នាង | ១២- ដៃរបស់គ្រូបង្រៀនម្នាក់ប៉ះទ្រូងអ្នកសិក្សាស្រីពេលកំពុងជួយដោះស្រាយលំហាត់គណិតវិទ្យានាង | ១១- ជនមិនដែលស្គាល់មុខម្នាក់រុញប្រដាប់ភេទរបស់ខ្លួនទៅបុកនរណាម្នាក់នៅលើឡានក្រុងដែលមានមនុស្សកកកុញ |
| ១៥- មិត្តភក្តិកាន់ដៃគ្នាពេលដើរតាមផ្លូវ។ | ១៤- ឪពុកមាម្នាក់អង្អែលខ្នងក្មួយប្រុសរបស់ខ្លួនពេលនៅតែពីរនាក់។ | ១៣- គ្រូបង្រៀនម្នាក់ដាក់ដៃរបស់នាងនៅលើខោ ឬសំពត់របស់អ្នកសិក្សា។ |

## ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ**

១- តើអ្នកគួរធ្វើអ្វីខ្លះ នៅពេលមានគេមកប៉ះពាល់ដោយសុជីវធម៌និងខ្វះសុជីវធម៌ ?

២- ចូរអ្នកមើលមេរៀនការសម្រេចចិត្ត ជំនាញចរចា និងបដិសេធ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៦ ៖ ការសម្រេចចិត្ត ជំនាញចរចា និងបដិសេធ

## ខ្លឹមសារម៉ោងទី១ ៖ ការសម្រេចចិត្ត ( ជំហានទាំងប្រាំក្នុងការសម្រេចចិត្ត )

**១- រយៈពេល ៖** ១ ម៉ោងសិក្សា

**២- វត្ថុបំណង** ៖ ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ពន្យល់ពាក្យការសម្រេចចិត្ត<br>• រៀបរាប់ពីការសម្រេចចិត្តជំនាញ និងចរចា ។ | • បង្ហាញពីការសម្រេចចិត្ត<br>• ពន្យល់អំពីជំហាននានាក្នុងការធ្វើការសម្រេចចិត្តដ៏ល្អ។ | • បណ្ដុះគំនិតចេះពិចារណា ស្វែងយល់ពីព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវប្រកបដោយគំរិយាបថវិជ្ជមាន។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- ការសម្រេចចិត្ត ( ជំហានទាំងប្រាំក្នុងការសម្រេចចិត្ត ) ៖ គឺការជ្រើសរើសនូវជម្រើសណាមួយដែលពេញចិត្តនិងយល់ថាត្រឹមត្រូវ។

  ជំហានទី ១ ៖ ពិចារណា និងរាយរាល់ជម្រើសទាំងអស់ដែលអាចមាន
  ជំហានទី ២ ៖ កំណត់ពីផលប្រយោជន៍ និងគុណវិបត្តិនៃជម្រើសនីមួយៗ ដោយប្រុងប្រយ័ត្ន
  ជំហានទី ៣ ៖ ស្វែងរកព័ត៌មាន ឬដំបូន្មានពីមនុស្សដែលអ្នកទុកចិត្តនៅទីកន្លែងដែលសមស្រប
  ជំហានទី ៤ ៖ ធ្វើការសម្រេចចិត្ត
  ជំហានទី ៥ ៖ ពិចារណាឡើងវិញលើការសម្រេចចិត្តនោះ បើសិនចាំបាច់។

**៥- វិធីសាស្ត្រ**

បំផុសគំនិត ករណីសិក្សា ពិភាក្សា ពន្យល់ សំណួរ និងចម្លើយ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅសប្ដាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស ៖ .............
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្ដាហ៍មុន ? ចម្លើយសិស្ស ៖ ......
  ៣- តើមានការសម្រេចចិត្តសាមញ្ញៗអ្វីខ្លះ ដែលអ្នកត្រូវធ្វើជារៀងរាល់ថ្ងៃ ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ការសម្រេចចិត្ត ( ជំហានទាំងប្រាំក្នុងការសម្រេចចិត្ត )**

- គ្រូជ្រើសរើសឧទាហរណ៍ណាមួយដែលសិស្សបានផ្តល់ឱ្យ និងសួរសិស្សថា តើអាចមានផលអ្វីខ្លះដែលកើតចេញពីសេចក្តីសម្រេចចិត្តនោះ ? ឧទាហរណ៍ ប្រសិនបើពួកគេសម្រេចចិត្តចូលគេងយឺត នោះពួកគេនឹងមានអារម្មណ៍នឿយហត់នៅថ្ងៃបន្ទាប់ ហើយមិនអាចរៀនបានល្អ
- គ្រូសម្របសម្រួល សំយោគចម្លើយតាមខ្លឹមសារនៃមេរៀន។

ចម្លើយ

ការសម្រេចចិត្តមានន័យថា គឺការជ្រើសរើសនូវជម្រើសណាមួយដែលពេញចិត្តនិងយល់ថាត្រឹមត្រូវ។ ការសម្រេចចិត្តខ្លះមានសារៈសំខាន់ណាស់សម្រាប់ជីវិតរបស់យើងទាំងបច្ចុប្បន្ននិងថ្ងៃអនាគត។ ការសម្រេចចិត្ត ជាផ្នែកមួយដ៏សំខាន់នៃការវិវត្តន៍ចិត្តគំនិត គឺការរៀនឱ្យចេះ មានការវិនិច្ឆ័យល្អសម្រាប់ធ្វើការសម្រេចចិត្ត។

ការសម្រេចចិត្តមានពីរគឺ៖

១- ការសម្រេចចិត្តដែលមិនធ្វើឱ្យប៉ះពាល់ដល់អនាគត វាជារឿងសាមញ្ញ ទោះបីជាយើងសម្រេចចិត្តខុសក៏ដោយ។ ឧទាហរណ៍ : ការសម្រេចចិត្តទិញសម្លៀកបំពាក់ ការសម្រេចចិត្តញ៉ាំអាហារ។ល។

២- ការសម្រេចចិត្តដែលធ្វើឱ្យប៉ះពាល់ដល់អនាគត។ ឧទាហរណ៍ : ការសម្រេចចិត្តរួមភេទដោយមិនបានគិតពីវិធីការពារ ការសេពគប់មិត្តមិនល្អ ការគេចមិនចូលរៀន ។ល។

- គ្រូពន្យល់ពីជំហាននៃការសម្រេចចិត្តរួមមាន៖

**ជំហានទី ១** : ពិចារណា និងរាយរាល់ជម្រើសទាំងអស់។
  - សម្រាប់ការសម្រេចចិត្តជាច្រើន គឺមានជម្រើសច្រើនដែលយើងមិនបានគិតដល់
  - អ្នកដទៃប្រហែលជាអាចជួយកំណត់រកជម្រើសបន្ថែមទៀត

**ជំហានទី ២** : កំណត់រកផលប្រយោជន៍ និងគុណវិបត្តិនៃជម្រើសនីមួយៗ ដោយប្រុងប្រយ័ត្ន។
  - រាប់បញ្ចូលរាល់គ្រោះថ្នាក់នៃជម្រើសទាំងអស់ដែលអាចកើតមានចំពោះខ្លួនឯង ឬអ្នកដទៃ
  - សរសេរផលវិបាកដែលអាចកើតចេញពីជម្រើសនីមួយៗនៅក្នុងបញ្ជីមួយ។

**ជំហានទី ៣** : ស្វែងរកព័ត៌មាន ឬដំបូន្មានពីមនុស្សដែលអ្នកទុកចិត្តនៅទីកន្លែងដែលសមស្រប។

**ជំហានទី ៤** : ធ្វើការសម្រេចចិត្ត រើសយកជម្រើសមួយ ដែលសមស្របសម្រាប់អ្នក។

**ជំហានទី ៥** : ពិចារណាឡើងវិញលើការសម្រេចចិត្តនោះ បើសិនចាំបាច់។ ព្យាយាមប្រើពេលវេលាឱ្យបានច្រើនតាមដែលអ្នកត្រូវការដើម្បីពិនិត្យមើលលើជំហានទាំងអស់ក្នុងការធ្វើការសម្រេចចិត្ត។

**ពិភាក្សាក្រុមករណីសិក្សា៖**

• គ្រូបែងចែកសិស្សជា ៤ក្រុម ក្រុមនីមួយៗពិភាក្សាករណីសិក្សាខាងក្រោម រយៈពេល១០ នាទី ដោយប្រើតារាងគំរូការសម្រេចចិត្ត។ ក្រុមនីមួយៗត្រូវមានតំណាងឡើងបង្ហាញលទ្ធផល គ្រូសម្របសម្រួល និងសំយោគលទ្ធផល។

**ក្រុមទី១ ៖ គំរូការសម្រេចចិត្ត**

**ជំហានទី ១៖** តើអ្នកមានជម្រើសអ្វីខ្លះ? សូមរាយឈ្មោះជម្រើសទាំងអស់ដែលអ្នកអាចគិតឃើញ។

ជម្រើសទី ១៖

ជម្រើសទី ២៖

ជម្រើសទី ៣៖

ជម្រើសទី ៤៖

**ជំហានទី ២៖** តើជម្រើសនីមួយៗមានផលដែលកើតចេញជាវិជ្ជមាន និងអវិជ្ជមានដែលអាចកើតមានអ្វីខ្លះ? សូមសរសេរផលទាំងអស់នេះនៅក្នុងចន្លោះខាងក្រោម

| **ជម្រើស** | **ផលដែលកើតចេញជាវិជ្ជមាន ឬផលដែលកើតចេញជាលទ្ធផលល្អ** | **ផលដែលអាចកើតចេញជាអវិជ្ជមាន ឬផលដែលកើតចេញជាលទ្ធផលអាក្រក់** |
|---|---|---|
| **១** | | |
| **២** | | |
| **៣** | | |

**ជំហានទី ៣៖** ស្វែងរកព័ត៌មាន ឬដំបូន្មានពីមនុស្សដែលអ្នកទុកចិត្តនៅទីកន្លែងដែលសមស្រប និងធ្វើការសម្រេចចិត្ត : អ្នកអាចជជែកជាមួយ ឪពុកម្តាយ បងប្អូន លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិល្អដែលរៀនបានពូកែ ។ល។

**ជំហានទី ៤៖** សម្រេចចិត្តថាតើត្រូវធ្វើអ្វី។ តើអ្នកសម្រេចចិត្តយ៉ាងណា?

**ជំហានទី ៥៖** វាយតម្លៃលើសេចក្តីសម្រេចចិត្តរបស់អ្នក។ តើហេតុអ្វីអ្នកធ្វើការសម្រេចចិត្តបែបនេះ?

## ករណីសិក្សា

១. **កន្និដ្ឋា** បានទៅហាងមួយនិងទិញស្បែកជើង។ នៅពេលអ្នកលក់អាប់លុយឱ្យនាង អ្នកលក់ឱ្យច្រឡំលើសលុយ ៥០,០០០ រៀល។ នេះជាកំហុសរបស់អ្នកលក់ ព្រោះគាត់មិនប្រយ័ត្នប្រយែង ប៉ុន្តែកន្និដ្ឋាប្រាកដក្នុងចិត្តថា នៅទីបំផុតលុយនោះនឹងត្រូវគេកាត់ពីប្រាក់ខែរបស់អ្នកលក់។ តើកន្និដ្ឋាគួរធ្វើដូចម្តេច?

២. **សំនិត** ចង់ទៅដើរលេងជាមួយក្មេងប្រុសធំៗដែលមានប្រជាប្រិយភាពនៅសាលារបស់ខ្លួន។ រសៀលថ្ងៃមួយ សំនិតបានជួបអ្នកទាំងនោះនៅហាងមួយក្រោយពេលចេញរៀន។ ពួកគេទាំងនោះជក់បារី ហើយក្មេងប្រុសម្នាក់បានហុចបារីមួយដើមឱ្យសំនិត។ សំនិត តែងគិតថា ការជក់បារីជាទម្លាប់អាក្រក់គួរឱ្យស្អប់ខ្ពើម បើទោះបីមិត្តភក្តិជាច្រើនរបស់គេបានធ្លាប់សាកល្បងជក់បារីក្តី។ តើសំនិតគួរធ្វើដូចម្តេច?

៣. **រចនា** អាយុ ១៥ឆ្នាំ ហើយកំពុងរៀនថ្នាក់ទី ៩។ នាងជាសិស្សល្អ ហើយនាងចង់បន្តការសិក្សានៅមហាវិទ្យាល័យ និងក្លាយជាគ្រូបង្រៀនកម្រិតមធ្យមសិក្សា។ ឪពុកម្តាយរបស់នាងកំពុងបង្ខំនាងឱ្យរៀបការ និងប្រាប់នាងថា ដល់ពេលហើយ ដោយនាងពុំអាចរស់នៅជាមួយឪពុកម្តាយជារៀងរហូតទេ។ តើរចនាគួរធ្វើ យ៉ាងណា?

៤. **គិរី** គឺជាសិស្សពូកែផ្នែកភាសា ប៉ុន្តែគាត់ខ្សោយមុខវិជ្ជាគណិតវិទ្យាខ្លាំង។ ឆាប់ៗនេះនឹងមានការប្រឡងដ៏ធំមួយ ហើយគិរីបារម្ភខ្លាចខ្លួនប្រឡងធ្លាក់។ គិរី បានសុំមិត្តភក្តិជិតស្និទ្ធរបស់គាត់ឈ្មោះ វិជ្ជា ថាគាត់សុំចម្លងផងនៅពេលប្រឡង ដោយឱ្យវិជ្ជាមកអង្គុយជាប់គាត់ក្នុងពេលប្រឡង ហើយឱ្យគាត់អាចមើលក្រដាសប្រឡងរបស់ វិជ្ជា។ តើវិជ្ជាគួរធ្វើដូចម្តេច?

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការសម្រេចចិត្ត គឺការជ្រើសរើសនូវជម្រើសណាមួយដែលពេញចិត្តនិងយល់ថាត្រឹមត្រូវ។ ការសម្រេចចិត្តមាន៥ជំហានដូចខាងក្រោម៖

ជំហានទី ១ : ពិចារណា និងរាយរាល់ជម្រើសទាំងអស់ដែលអាចមាន

ជំហានទី ២ : កំណត់ពីផលប្រយោជន៍ និងគុណវិបត្តិនៃជម្រើសនីមួយៗ ដោយប្រុងប្រយ័ត្ន

ជំហានទី ៣ : ស្វែងរកព័ត៌មាន ឬដំបូន្មានពីមនុស្សដែលអ្នកទុកចិត្តនៅទីកន្លែងដែលសមស្រប

ជំហានទី ៤ : ធ្វើការសម្រេចចិត្ត

ជំហានទី ៥ : ពិចារណាឡើងវិញលើការសម្រេចចិត្តនោះ បើសិនចាំបាច់។

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីការសម្រេចចិត្តនិងជំហានក្នុងការសម្រេចចិត្ត។

## ៨- លំហាត់ (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរប្អូនយកចំណេះដឹងពីមេរៀននេះ ទៅចែករំលែកដល់សមាជិកគ្រួសារនិងមិត្តភក្តិ។

**កិច្ចការផ្ទះ**

១- តើអ្នកត្រូវធ្វើដូចម្តេចដើម្បីឱ្យភាគីម្ខាងទៀតទទួលយកសំណើរបស់អ្នក?

២- តើត្រូវប្រើឥរិយាបថបែបណានៅពេលឆ្លើយបដិសេធជាមួយភាគីម្ខាងទៀត?

៣- ចូរប្អូនមើលមេរៀនការសម្រេចចិត្ត ជំនាញចរចា និងបដិសេធ ត្រង់ចំណងជើង: ជំនាញចរចានិងបដិសេធ និងលទ្ធផលនៃការសម្រេចចិត្ត សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៦ : ការសម្រេចចិត្ត ជំនាញចរចា និងបដិសេធ (តចប់)

## ខ្លឹមសារម៉ោងទី២ : ជំនាញចរចានិងបដិសេធ និងលទ្ធផលនៃការសម្រេចចិត្ត

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីការសម្រេចចិត្តជំនាញចរចានិងបដិសេធ<br>• រៀបរាប់ពីលទ្ធផលនៃការសម្រេចចិត្ត។ | • បង្ហាញពីការសម្រេចចិត្ត ជំនាញចរចា និងបដិសេធ<br>• បកស្រាយបានលទ្ធផលនៃការសម្រេចចិត្ត។ | • បណ្តុះគំនិតចេះពិចារណា ស្វែងយល់ពីព័ត៌មានគ្រប់ជ្រុងជ្រោយដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវប្រកប ដោយឥរិយាបថវិជ្ជមាន។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- **ជំនាញចរចានិងបដិសេធ** គឺជាការបង្ហាញហេតុផលនិងពន្យល់ភាគីម្ខាងទៀតឱ្យយល់ព្រមនិងទទួលយកបានទាំងសងខាង (ឈ្នះ ឈ្នះទាំងអស់គ្នា)។ អ្នកអាចព្យាយាមចរចាជាមួយភាគីម្ខាងទៀតនោះបានដែរ ដោយអ្នកត្រូវលើកឡើងនូវគំនិតឬមតិយោបល់ផ្សេងទៀត និងពិនិត្យថាតើជននោះយល់ស្របចំពោះអ្វីដែលអ្នកកំពុងស្នើឡើងឬទេ។ ការបដិសេធ អ្នកអាចនិយាយថា "ទេ" ដោយពុំមានអារម្មណ៍ថាខ្លួនអ្នកមានកំហុស។
- **លទ្ធផលនៃការសម្រេចចិត្ត** គឺជាការសម្រេចចិត្តថាមួយណាល្អជាង។ ជារឿយៗ មិនមានចម្លើយ "ត្រូវ" ឬ "ខុស" ចំពោះបញ្ហាប្រឈមក្នុងជីវិតឡើយ។ ការសម្រេចចិត្តដែលល្អបំផុត គឺត្រូវផ្អែកលើព័ត៌មាន បទពិសោធន៍ ស្ថានភាពជាក់ស្តែង និងសេចក្តីត្រូវការរបស់អ្នក ដែលឆ្លើយតបទៅនឹងគុណតម្លៃ មិនមានហានិភ័យដល់សុខភាព សុវត្ថិភាពផ្ទាល់ខ្លួននិងអ្នកដទៃ ព្រមទាំងមិនរំលោភច្បាប់។

**៥- វិធីសាស្ត្រ**

បំផុសគំនិត ករណីសិក្សា ល្បែងដើរតួ សំណួរ និងចម្លើយ។

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅសប្ដាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្ដាហ៍មុន? គ្រូប្រមូលកិច្ចការផ្ទះពីម៉ោងមុនរួចសួរសំណួរ

  ៣- តើអ្នកត្រូវធ្វើដូចម្ដេចដើម្បីឱ្យភាគីម្ខាងទៀតទទួលយកសំណើរបស់អ្នក?

  ៤- តើត្រូវប្រើឥរិយាបថបែបណានៅពេលឆ្លើយបដិសេធជាមួយភាគីម្ខាងទៀត?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ជំនាញចរចានិងបដិសេធ**

- **គ្រូពន្យល់** : ពេលដែលយើងធ្វើការសម្រេចចិត្ត មានមនុស្សព្យាយាមបញ្ចុះបញ្ចូលយើងកុំឱ្យប្រកាន់ខ្ជាប់តាមការសម្រេចចិត្តនោះ។ ដូច្នេះយើងនឹងរៀនអំពីរបៀបចរចា និងបដិសេធ នៅក្នុងស្ថានភាពនោះ។
- គ្រូបែងចែកសិស្សជាក្រុមពិភាក្សាករណីសិក្សារយៈពេល៥ទៅ១០នាទី លើសំណួរខាងក្រោម៖ **ករណីសិក្សា ៖ ភិរុណ** ចង់ឱ្យភួងជក់បារី តែភួងមិនចង់ជក់ទេ។ នាងខ្លាចញៀននិងប៉ះពាល់សុខភាព។ តើភួងត្រូវឆ្លើយតបទៅភិរុណយ៉ាងដូចម្ដេច? តើភួងត្រូវប្រើបំណិនអ្វីខ្លះ ដើម្បីកុំឱ្យភិរុណបង្ខំខ្លួនឱ្យជក់បារីនៅពេលក្រោយទៀត?
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សំយោគ និងសង្ខេបចម្លើយ តាមខ្លឹមសារនៃមេរៀន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅកិច្ចការ។

**ខ្លឹមសារ : លទ្ធផលនៃការសម្រេចចិត្ត**

- **គ្រូពន្យល់** : មនុស្សខ្លះមានការភ័យខ្លាចនៅពេលធ្វើការសម្រេចចិត្ត ព្រោះពួកគេខ្លាចខុស។ នៅពេល
  ដែលអ្នកមានជម្រើសលើសពីមួយ អ្នកអាចធ្វើការពិចារណាមុននឹងសម្រេចចិត្តថាមួយណាល្អជាង។ ជារឿយៗមិនមានចម្លើយ "ត្រូវ" ឬ "ខុស" ចំពោះបញ្ហាប្រឈមក្នុងជីវិតឡើយ។ អ្នកត្រូវធ្វើការជ្រើសរើសការសម្រេចចិត្តណាមួយដែលល្អបំផុត ដោយផ្អែកលើព័ត៌មាន បទពិសោធន៍ ស្ថានភាពជាក់ ស្ដែង និងសេចក្ដីត្រូវការរបស់អ្នក។ ការសម្រេចចិត្តដែលល្អបំផុត គឺឆ្លើយតបទៅនឹងគុណតម្លៃ មិនមានហានិភ័យដល់សុខភាព សុវត្ថិភាពផ្ទាល់ខ្លួននិងអ្នកដទៃ ព្រមទាំងមិនរំលោភច្បាប់។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

**ជំនាញចរចានិងបដិសេធ** គឺជាការបង្ហាញហេតុផលនិងពន្យល់ភាគីម្ខាងទៀតឱ្យយល់ព្រមនិងទទួលយកបានទាំងសងខាង (ឈ្នះ ឈ្នះទាំងអស់គ្នា)។ ការសម្រេចចិត្តដែលល្អបំផុត គឺត្រូវផ្អែកលើព័ត៌មាន បទពិសោធន៍ ស្ថានភាពជាក់ស្តែង និងសេចក្តីត្រូវការរបស់អ្នកដែលឆ្លើយតបទៅនឹងគុណតម្លៃ មិនមានហានិភ័យដល់សុខភាព សុវត្ថិភាពផ្ទាល់ខ្លួននិងអ្នកដទៃ ព្រមទាំងមិនរំលោភច្បាប់៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសំណួរ៖

១- តើអ្នកត្រូវប្រើកិរិយាបថបែបណានៅពេលឆ្លើយបដិសេធជាមួយភាគីម្ខាងទៀត?

២- ល្បែងដើរតួតាមករណីសិក្សាខាងលើ។

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរអ្នកយកចំណេះដឹងពីមេរៀននេះទៅប្រើក្នុងសកម្មភាពប្រចាំថ្ងៃ ទៅចែករំលែកដល់សមាជិកគ្រួសារ និងមិត្តភក្តិ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការប្រែប្រួលនៅពេលពេញវ័យ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ការប្រែប្រួលនៅពេលពេញវ័យ

## ខ្លឹមសារម៉ោងទី១ : ការប្រែប្រួលរាងកាយពេលពេញវ័យ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ការប្រែប្រួលរាងកាយ អារម្មណ៍ និងអាកប្បកិរិយា នៅពេលពេញវ័យ។ | • បង្ហាញពីការប្រែប្រួលអារម្មណ៍ និងការគ្រប់គ្រងអារម្មណ៍នៅពេលពេញវ័យ។ | • បណ្តុះទម្លាប់គ្រប់គ្រងអារម្មណ៍ឱ្យបានល្អនៅពេលពេញវ័យ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

ការប្រែប្រួលរាងកាយពេលពេញវ័យ គឺក្មេងស្រីភាគច្រើនចាប់ផ្តើមពេញវ័យនៅចន្លោះពី ៩ដល់១៣ឆ្នាំ ហើយក្មេងប្រុសយឺតជាងក្មេងស្រីបន្តិចក្នុងចន្លោះអាយុ ១០ដល់១៤ឆ្នាំ។ នៅពេលពេញវ័យក្មេងស្រីមានការប្រែប្រួលរាងកាយដូចជា សុដន់រីកធំ ត្រគាកសាយ បែកសំឡេង អាចមានមុនលើមុខនិងខ្នង មានដុះរោមក្លៀក និងបរិវេណប្រដាប់ភេទ អូវ៉ែចាប់ផ្តើមបង្កើតមេជីវិតញីនិងអាចបង្កកំណើតបាន។ ចំណែកក្មេងប្រុស មានការប្រែប្រួលដូចជា ដុះរោមក្លៀក ដៃជើង និង ប្រដាប់ភេទ ដុះពុកមាត់ សំឡេងគ្រលរ មានគ្រាប់ពោន ស្មានិងទ្រូងរីក កើតមុននៅមុខនិងខ្នង លិង្គនិងពងស្វាសលូតលាស់ធំ មានក្លិនខ្លួន ពងស្វាសចាប់ផ្តើម ផលិតទឹកកាមនិងមេជីវិតឈ្មោល និងអាចបង្កកំណើត។

**៥- វិធីសាស្ត្រ**

សំណួរបំផុស សំណួរចម្លើយ ពិភាក្សាក្រុម ធ្វើការងារជាដៃគូ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

 ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

 ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន? ចម្លើយសិស្ស : ......

 ៣- នៅពេលពេញវ័យ តើមនុស្សយើងមានការប្រែប្រួលអ្វីខ្លះ?

៤- តើរាងកាយផ្នែកខាងក្រៅមានការប្រែប្រួលដូចម្តេចខ្លះ ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ការប្រែប្រួលរាងកាយពេលពេញវ័យ**

- បង្ហាញរូបភាពនិងពន្យល់ពីការប្រែប្រួលរាងកាយផ្នែកខាងក្រៅតាមខ្លឹមសារមេរៀន





- ក្មេងស្រីភាគច្រើនចាប់ផ្តើមពេញវ័យនៅចន្លោះពី ៩ដល់១៣ឆ្នាំ ហើយក្មេងប្រុសយឺតជាងក្មេងស្រីបន្តិចក្នុងចន្លោះអាយុ ១០ដល់១៤ឆ្នាំ។ នៅពេលពេញវ័យក្មេងស្រីមានការប្រែប្រួលរាងកាយដូចជា សុដន់រីកធំ ត្រគាកសាយ បែកសំឡេង អាចមានមុនលើមុខនិងខ្នង មានដុះរោមក្លៀក និង បរិវេណប្រដាប់ភេទអូវែចាប់ផ្តើម បង្កើតមេជីវិតញីនិងអាចបង្កកំណើតបាន។ ចំណែកក្មេងប្រុសមានការប្រែប្រួលដូចជា ដុះរោមក្លៀក ដៃជើង និង ប្រដាប់ភេទ ដុះពុកមាត់ សំឡេងគ្រលរ មាន

គ្រាប់ពោន ស្មានិងទ្រូងរីក កើតមុននៅមុខនិង ខ្នង លិង្គនិងពងស្វាសលូតលាស់ធំ មានក្លិនខ្លួន ពងស្វាសចាប់  ផ្ដើមផលិតទឹកកាមនិងមេជីវិតឈ្មោល និងអាចអាចបង្កកំណើត។

**ខ្លឹមសារ : ការអភិវឌ្ឍផ្នែកអារម្មណ៍** (ការប្រែប្រួលអារម្មណ៍ និងការគ្រប់គ្រងអារម្មណ៍ផ្លូវភេទ)

- គ្រូចែកសិស្សជាក្រុមតូចពិភាក្សាលើសំណួរខាងក្រោម (១០នាទី)៖
  - ១- តើយុវវ័យមានការប្រែប្រួលអារម្មណ៍ដូចម្ដេចខ្លះ?
  - ២- តើយុវវ័យគ្រប់គ្រងអារម្មណ៍ផ្លូវភេទដូចម្ដេចខ្លះ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេបតាមខ្លឹមសារនៃមេរៀន ។



**មេរៀនសង្ខេប**

ក្មេងស្រីភាគច្រើនចាប់ផ្ដើមពេញវ័យនៅចន្លោះពី ៩ ដល់ ១៣ឆ្នាំ ហើយក្មេងប្រុសយឺតជាងក្មេងស្រីបន្តិចក្នុងចន្លោះអាយុ ១០ ដល់១៤ឆ្នាំ។ ការប្រែប្រួលផ្នែកអារម្មណ៍និងសង្គមរបស់ក្មេងស្រីនិងក្មេងប្រុសមានដូចជា រំភើបនៅពេលប៉ះត្រង់កេរភេទ ស្រងេះស្រងោចឯកា ទាមទារការចាប់អារម្មណ៍ពីអ្នកដទៃនិងឱ្យគេសរសើរ ចូលចិត្តតុបតែងខ្លួន ចង់សប្បាយ ជឿជាក់លើមិត្តភក្តិជាងឪពុកម្ដាយ។ល។ ដើម្បីគ្រប់គ្រងអារម្មណ៍ផ្លូវភេទគួរពិភាក្សាជាមួយ មិត្តភក្តិ លោកគ្រូ អ្នកគ្រូ បងប្អូន ឪពុកម្ដាយ គ្រូពេទ្យនិងអ្នកមានបទពិសោធន៍។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

- គ្រូសរសេរឬព្រីនព័ត៌មានខាងក្រោមនៅលើក្រដាសអេ៤ រួចច្របល់ព័ត៌មានទាំងនោះមានដូចជា៖ ចូលចិត្តតុបតែងខ្លួន ចង់សប្បាយ  តម្រូវចិត្តខ្លួនឯងជាធំ ប្រឹក្សាជាមួយមិត្តភក្តិ លោកគ្រូ អ្នកគ្រូបងប្អូន ឪពុកម្ដាយ គ្រូពេទ្យនៅតាមមណ្ឌលសុខភាពឬមន្ទីរពេទ្យ ភ្នាក់ងាររបស់អង្គការ អ្នកមានបទពិសោធន៍។
- ចែកសិស្សម្នាក់១សន្លឹកឱ្យសិស្សឡើងបិទលើក្ដារខៀនដូចតារាងខាងក្រោម៖

| ការប្រែប្រួលអារម្មណ៍ និងការគ្រប់គ្រងអារម្មណ៍ផ្លូវភេទ | | |
|---|---|---|
| ក្មេងប្រុស | ក្មេងស្រី | ទាំងពីរ |
| ការប្រែប្រួលផ្នែកអារម្មណ៍ | | |
| | | ប្រែប្រួលឆាប់រហ័ស ចង់ដឹងនិងយល់ពីខ្លួនឯង មានភាពទាក់ទាញផ្លូវភេទ អភិវឌ្ឍគុណតម្លៃផ្ទាល់ខ្លួន ព្រួយបារម្មណ៍ច្រើន។ |
| ការគ្រប់គ្រងអារម្មណ៍ផ្លូវភេទ | | |

| | | |
|---|---|---|
| | | ដើម្បីគ្រប់គ្រងអារម្មណ៍ផ្លូវភេទគួរពិភាក្សាជាមួយមិត្តភក្តិ លោកគ្រូអ្នកគ្រូ បងប្អូន ឪពុកម្តាយ គ្រូពេទ្យនិងអ្នកមានបទពិសោធន៍។ |

## ៨- **លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ:** ចូរអ្នកមើលមេរៀនត្រង់ចំណងជើងការអភិវឌ្ឍផ្នែកអាកប្បកិរិយា និងការអភិវឌ្ឍផ្នែកសង្គមនៅពេលពេញវ័យ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ការប្រែប្រួលនៅពេលពេញវ័យ (តចប់)

## ខ្លឹមសារម៉ោងទី២ : ការអភិវឌ្ឍផ្នែកអាកប្បកិរិយា និងការអភិវឌ្ឍផ្នែកសង្គមនៅពេលពេញវ័យ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ការប្រែប្រួលនិងអភិវឌ្ឍផ្នែកអាកប្បកិរិយានិងផ្នែកសង្គមនៅពេលពេញវ័យ។ | • បង្ហាញពីការប្រែប្រួលនិងអភិវឌ្ឍផ្នែកអាកប្បកិរិយានិងផ្នែកសង្គមនៅពេលពេញវ័យ។ | • បណ្តុះទម្លាប់គ្រប់គ្រងអារម្មណ៍ឱ្យបានល្អនៅពេលពេញវ័យ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- **ការអភិវឌ្ឍផ្នែកអាកប្បកិរិយា** រួមមាន: ស្រងេះស្រងោច ឯកា មានសេចក្តីស្រឡាញ់ ទាមទារការចាប់អារម្មណ៍ពីអ្នកដទៃនិងឱ្យគេសរសើរ ចូលចិត្តតុបតែងខ្លួន ចង់សប្បាយ តម្រូវចិត្តខ្លួនឯងជាធំ ជឿជាក់លើមិត្តភក្តិជាងឪពុកម្តាយ ចូលចិត្តប្រកួតប្រជែងនិងមានការអៀនច្រើន (ចំពោះក្មេងស្រី) ចង់ឯករាជ្យនិងចង់សាកល្បងអ្វីដែលថ្មី ងាយទទួលការអូសទាញ ឆាប់ឆេវឆាវ និងឆាប់ខឹង។
- **ការអភិវឌ្ឍផ្នែកសង្គមនៅពេលពេញវ័យ** រួមមាន : ចង់មានឯកជនភាពនិងចង់ឯករាជ្យពីឪពុកម្តាយ ចង់ចូលរួមជាមួយមិត្តភក្តិឬទទួលការអូសទាញពីមិត្តភក្តិ មានចំណាប់អារម្មណ៍ក្នុងរឿងស្នេហា និងមនោសញ្ចេតនាជាដើម។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ធ្វើបទបង្ហាញ ធ្វើការងារជាដៃគូ ពិភាក្សាក្រុម ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្ដាហ៍មុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន។

- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ការអភិវឌ្ឍផ្នែកអាកប្បកិរិយា និងការអភិវឌ្ឍផ្នែកសង្គមនៅពេលពេញវ័យ**

- គ្រូសួរសំណួរៈ

៣- តើការអភិវឌ្ឍផ្នែកអាកប្បកិរិយានៅពេលមនុស្សពេញវ័យមានអ្វីខ្លះ?

៤- តើការអភិវឌ្ឍផ្នែកសង្គមនៅពេលមនុស្សពេញវ័យមានអ្វីខ្លះ?

- គ្រូហៅសិស្ស៣ ឬ៤ នាក់ ឆ្លើយ។ ចម្លើយសិស្ស...
- គ្រូសម្របសម្រួល សំយោគ និងសង្ខេបចម្លើយ តាមខ្លឹមសារនៃមេរៀន។

**ចម្លើយ**

- **ការអភិវឌ្ឍផ្នែកអាកប្បកិរិយា**រួមមាន : ស្រងេះស្រងោច ឯកា មានសេចក្ដីស្រឡាញ់ ទាមទារការចាប់អារម្មណ៍ពីអ្នកដទៃនិងឱ្យគេសរសើរ ចូលចិត្តតុបតែងខ្លួន ចង់សប្បាយ តម្រូវចិត្តខ្លួនឯងជាធំ ជឿជាក់លើមិត្តភក្ដិជាងឪពុកម្ដាយ ចូលចិត្តប្រកួតប្រជែងនិងមានការអៀនច្រើន (ចំពោះក្មេងស្រី) ចង់ឯករាជ្យនិងចង់សាកល្បងអ្វីដែលថ្មី ងាយទទួលការអូសទាញ ឆាប់ឆេវឆាវ និងឆាប់ខឹង។
- **ការអភិវឌ្ឍផ្នែកសង្គមនៅពេលពេញវ័យមាន** : ចង់មានឯកជនភាពនិងចង់ឯករាជ្យពីឪពុកម្ដាយ ចង់ចូលរួមជាមួយមិត្តភក្ដិឬទទួលការអូសទាញពីមិត្តភក្ដិ មានចំណាប់អារម្មណ៍ក្នុងរឿងស្នេហា និងមនោសញ្ចេតនាជាដើម។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការអភិវឌ្ឍផ្នែកអាកប្បកិរិយា និងសង្គមរួមមាន : ស្រងេះស្រងោច ឯកា ការស្រឡាញ់ ទាមទារការចាប់អារម្មណ៍ពីអ្នកដទៃនិងឱ្យគេសរសើរ ចូលចិត្តតុបតែងខ្លួន ចង់សប្បាយ តម្រូវចិត្តខ្លួនឯងជាធំ ជឿជាក់លើមិត្តភក្ដិជាងឪពុកម្ដាយ ចូលចិត្តប្រកួតប្រជែងនិងមានការអៀនច្រើន (ចំពោះក្មេងស្រី) ចង់ឯករាជ្យនិងចង់សាកល្បងអ្វីដែលថ្មី ងាយទទួលការអូសទាញ ឆាប់ឆេវឆាវ និងឆាប់ខឹង។

## ៧- ខ្លាយតម្លៃ ( ជំហានទី៤ )

- គ្រូសរសេរឬព្រីនព័ត៌មានខាងក្រោមនៅលើក្រដាសអេ៤ រួចច្របល់ព័ត៌មានទាំងនោះមានដូចជា: ស្រងេះស្រងោច ឯកា ចូលចិត្តតុបតែងខ្លួន ចង់សប្បាយ តម្រូវចិត្តខ្លួនឯងជាធំ ជឿជាក់លើមិត្តភក្តិជាងឪពុកម្តាយ ចូលចិត្តប្រកួតប្រជែងនិងមានការអៀនច្រើន ( ចំពោះក្មេងស្រី ) ចង់ឯករាជ្យនិងចង់សាកល្បងអ្វីដែលថ្មី ងាយទទួលការអូសទាញ ឆាប់ឆេវឆាវ និងឆាប់ខឹង ចង់មានឯកជនភាព និងចង់ឯករាជ្យពីឪពុកម្តាយ ចង់ចូលរួមជាមួយមិត្តភក្តិឬទទួលការអូសទាញពីមិត្តភក្តិ មានចំណាប់អារម្មណ៍ក្នុងរឿងស្នេហា
- ចែកសិស្សម្នាក់១សន្លឹកឱ្យសិស្សឡើងបិទលើក្តារខៀនដូចតារាងខាងក្រោម៖

| ការអភិវឌ្ឍផ្នែកការប្រែប្រួលអាកប្បកិរិយានិងផ្នែកសង្គម | | |
|---|---|---|
| ក្មេងប្រុស | ក្មេងស្រី | ទាំងពីរ |
| ការអភិវឌ្ឍផ្នែកអាកប្បកិរិយានៅពេលពេញវ័យ | | |
| | មានការអៀនច្រើន | ការអភិវឌ្ឍផ្នែកអាកប្បកិរិយា រួមមាន ស្រងេះស្រងោច ឯកា មានសេចក្តីស្រឡាញ់ ទាមទារការចាប់អារម្មណ៍ពីអ្នកដទៃនិងឱ្យគេសរសើរ ចូលចិត្តតុបតែងខ្លួន ចង់សប្បាយ តម្រូវចិត្តខ្លួនឯងជាធំ ជឿជាក់លើមិត្តភក្តិជាងឪពុកម្តាយ ចូលចិត្តប្រកួតប្រជែង ចង់ឯករាជ្យនិងចង់សាកល្បងអ្វីដែលថ្មី ងាយទទួលការអូសទាញ ឆាប់ឆេវឆាវ និងឆាប់ខឹង។ |
| ការអភិវឌ្ឍផ្នែកសង្គមនៅពេលពេញវ័យ | | |
| | | ចង់មានឯកជនភាពនិងចង់ឯករាជ្យពីឪពុកម្តាយ ចង់ចូលរួមជាមួយមិត្តភក្តិឬទទួលការអូសទាញពីមិត្តភក្តិ មានចំណាប់អារម្មណ៍ក្នុងរឿងស្នេហា និងមនោសញ្ចេតនាជាដើម។ |

## ៨- លំហាត់ ( ជំហានទី៥ )

**កិច្ចការផ្ទះ:**

១- ចូរអ្នកធ្វើការសង្កេតនិងកត់ត្រាលើការប្រែប្រួលរបស់អ្នកចំពោះ ការប្រែប្រួលរាងកាយខាងក្រៅ ការប្រែប្រួលអារម្មណ៍ ការអភិវឌ្ឍផ្នែកអាកប្បកិរិយា និងការអភិវឌ្ឍផ្នែកសង្គម។

២- ចូរអ្នកមើលមេរៀនសរីរាង្គភេទ សម្រាប់រៀននៅម៉ោងអប់រំសុខភាពសប្តាហ៍ក្រោយ។

# មេរៀនទី ២ : សរីរាង្គភេទ

## ខ្លឹមសារម៉ោងទី១ : សរីរាង្គភេទ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមានៈ

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ពណ៌នាពីសរីរាង្គភេទមនុស្ស ប្រុស ស្រី និងអន្តរភេទ | • បង្ហាញពីផ្នែកផ្សេងៗ និងតួនាទីនៃសរីរាង្គភេទ | • បណ្តុះទម្លាប់ថែទាំនិងធ្វើអនាម័យសរីរាង្គភេទទាំងប្រុស ស្រី និងអន្តរភេទ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្ស និងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ (ផ្ទាំងរូបភាព ឬបណ្ណពាក្យពាក់ព័ន្ធនឹងប្រព័ន្ធបន្តពូជមនុស្សប្រុស)។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- សរីរាង្គភេទមនុស្ស គឺជាប្រព័ន្ធបន្តពូជ ដែលមានតួនាទីក្នុងការបង្កកំណើត។ សរីរាង្គភេទចែកចេញជា សរីរាង្គភេទប្រុស (បុំលិង្គ) ភេទស្រី (ឥត្ថីលិង្គ)។ ប៉ុន្តែមានទារកខ្លះកើតមកប្រដាប់ភេទមានលក្ខណៈមិនច្បាស់លាស់ ហៅថាអន្តរភេទ (នបុំសកលិង្គ)។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ពន្យល់ ការពិភាក្សាក្រុមធំ បទបង្ហាញខ្នាតតូច។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ ណែនាំចំណងជើងមេរៀន។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូសួរសំណួរទំនាក់ទំនង ឬបំផុសៈ

 ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

 ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន? ចម្លើយសិស្ស : ......

 ៣- តើមានអ្នកណាអាចប្រាប់គ្រូនូវសរីរាង្គណាមួយនៃរាងកាយ ដែលមនុស្សគ្រប់រូបមាន?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- កំណត់សម្គាល់ចំពោះគ្រូ : (អាចមានចម្លើយច្រើន) ចម្លើយទាំងអស់សុទ្ធតែជាចម្លើយល្អ អ្វីដែលសំខាន់នៅក្នុងសំណួរនេះ គឺដើម្បីបង្ហាញឱ្យឃើញថា មនុស្សយើងមានលក្ខណៈប្រហាក់ប្រហែល

គ្នាកម្រិតណា? ប្រសិនបើនរណាម្នាក់លើកឡើងថា ពុំមែនគ្រប់មនុស្សទាំងអស់ សុទ្ធតែមានដៃ ម្រាមដៃ។ល។ នោះទេ សូមទទួលស្គាល់ថា អ្វីដែលគេលើកឡើងនោះជាការពិត ប៉ុន្តែមនុស្សភាគ ច្រើនសុទ្ធតែមានសរីរាង្គទាំងនេះ។

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារ : សរីរាង្គភេទបុរស ស្ត្រី និងអន្តរភេទ**

- គ្រូបង្ហាញរូបភាពសរីរាង្គភេទបុរស ស្ត្រី និង អន្តរភេទ ផ្នែកខាងក្រៅ ខាងក្នុង និងមុខងារ









- គ្រូពន្យល់ខ្លឹមសារខាងក្រោម៖
  - សរីរាង្គភេទបុរសផ្នែកខាងក្រៅមាន៖ លិង្គ ពងស្វាស
  - សរីរាង្គភេទបុរសផ្នែកខាងក្នុងមាន៖ ថង់ទឹកកាម ក្រពេញប្រូស្តាត ក្រពេញខប់ភ័រ ក្រពេញ អេពីឌីឌីម បំពង់បង្ហូរមេជីវិតឈ្មោល បង្ហូរនោម និងរន្ធនោម។
  - សរីរាង្គភេទស្ត្រីផ្នែកខាងក្រៅ៖ ថ្ងាសយោនី ទ្វារមាស បបូរធំ ឬបបូរក្រៅ បបូរតូចឬបបូរ ខាងក្នុង ឆ្អេញ (សិរ) រន្ធនោម។
  - សរីរាង្គភេទស្ត្រីផ្នែកខាងក្នុងមាន៖ ទ្វារមាសផ្នែកខាងក្នុង (**Vagina**) មាត់ស្បូននិងស្បូន ដៃស្បូន ក្រពេញអូវែ (កន្សោមពងញី) មានចំនួន ២ នៅសងខាង (ឆ្វេងនិងស្តាំ) គឺ សម្រាប់បង្កើតមេជីវិតញី និងបង្កើតអ័រម៉ូនស្ត្រី ដូចជា អ៊ីស្ត្រូសែន (**Oestrogen**) និងប្រូ ហ្សេសស្តេរ៉ូន (**Progesterone**)។ **សន្ទះព្រហ្មចារីយ៍** ស្ថិតនៅជម្រៅ ១ ទៅ ២ ស.ម ពី រន្ធទ្វារមាស។ វាមានរូបរាង ទំហំ ពណ៌ សណ្ឋាន និងកម្រាស់ខុសៗគ្នា ពីមនុស្សម្នាក់ទៅ មនុស្សម្នាក់ទៀត។ វាជាសន្ទះជាលិកាភ្នាសដែលយឺតនិងមិនងាយដាច់រហែក និងមាន ពណ៌ផ្កាឈូកស្រាលថ្លា ប៉ុន្តែប្រសិនបើវាក្រាស់ វាមានពណ៌ស្លេកឬពណ៌ស។

- **គ្រូបញ្ជាក់បន្ថែម៖** មនុស្សទាំងអស់សុទ្ធតែមានសរីរាង្គភាគច្រើនដូចៗគ្នា ប៉ុន្តែមានសរីរាង្គមួយ ចំនួនតូចប៉ុណ្ណោះ ដែលមានលក្ខណៈភេទមិនតាមជីវសាស្ត្រជាមនុស្សប្រុស និងមនុស្សស្រី។ សរី រាង្គទាំងនោះ គឺជាផ្នែកនៃប្រដាប់បន្តពូជរបស់យើង ដែលយើងនឹងសិក្សាក្នុងមេរៀនថ្ងៃនេះ។ ប្រាប់ ពួកគេថា ប្រព័ន្ធបន្តពូជ គឺផ្សំឡើងដោយសរីរាង្គដែលត្រូវបានប្រើប្រាស់ក្នុងការបន្តពូជ ឬក្នុងការ បង្កើត និងធ្វើឱ្យមានទារក។ មនុស្សភាគច្រើនមានសរីរាង្គភេទជាប្រុស ឬជាស្រី ប៉ុន្តែពេលខ្លះ មនុស្សមានសរីរាង្គភេទដែលពុំច្បាស់ជាប្រុស ឬជាស្រី។ អ្នកទាំងនេះហៅថា អន្តរភេទ។

- គ្រូរៀបចំបណ្ណពាក្យ ដែលទាក់ទងនឹងសរីរាង្គបុរស ស្ត្រី និង អន្តរភេទ។
- គ្រូចែកសិស្សជាក្រុម ដើម្បីផ្តុំឃ្លា ដោយទុករយៈពេលពី ៥ទៅ១០នាទី ឱ្យសិស្សពិភាក្សា។ បន្ទាប់មកគ្រូចែកបណ្ណពាក្យតូចៗក្នុងឃ្លាទី១ និងឃ្លាទី២ ខាងក្រោមឱ្យក្រុមពិភាក្សា។
- តំណាងក្រុមឡើងបកស្រាយ
- គ្រូសំយោគ និងសម្របសម្រួលចម្លើយសិស្ស។

**ចម្លើយ៖**

| ឃ្លាទី ១ | ឃ្លាទី ២ |
|---|---|
| លិង្គ | ឡើងរឹងនៅពេលមានអារម្មណ៍រំភើបផ្លូវភេទ និងសម្រាប់រួមភេទ និងបញ្ចេញទឹកកាម។ |
| ពងស្វាស | សម្រាប់ផលិតមេជីវិតឈ្មោល និងផលិតអ័រម៉ូនភេទរបស់បុរស។ |
| មេជីវិតឈ្មោល | មានតួនាទី ទៅបង្កកំណើតជាមួយមេជីវិតញីក្នុងដៃស្បូនរបស់ស្ត្រី។ |
| ថ្វាសយោនី | ជាបរិវេណដែលមានដុះរោម។ |
| ទ្វារមាស | នៅក្រោមរន្ធនោមមានរន្ធមួយបញ្ចេញទឹករំអិល ឈាមរដូវ និងផ្លូវបង្កើតកូន។ |
| បបូរធំ ឬបបូរក្រៅ | មាននាទីគ្រប និងការពារផ្នែកខាងក្នុងរបស់ទ្វារមាស។ |
| បបូរតូចឬបបូរខាងក្នុង | មិនសូវមានរោមទេវាគ្របពីលើរន្ធទ្វារមាស។ |
| ឆ្គេញ (សិរ) | មានទំហំប៉ុនគ្រាប់សណ្តែក នៅពីលើរន្ធនោម ហើយនៅកៀកជាប់និងបបូរតូចផ្នែកខាងលើ។ |
| រន្ធនោម | គឺជារន្ធមួយនៅពីខាងក្រោមឆ្គេញ និងនៅខាងលើរន្ធទ្វារមាស។ |

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

សរីរាង្គភេទមនុស្ស គឺជាប្រព័ន្ធបន្តពូជ ដែលមានតួនាទីក្នុងការបង្កកំណើត ។

សរីរាង្គភេទចែកចេញជា សរីរាង្គភេទបុរស សរីរាង្គភេទស្ត្រី អន្តរភេទ(នបុំសកលិង្គ)។ សរីរាង្គភេទបុរស និងស្ត្រី ចែកចេញជា ផ្នែកខាងក្រៅនិងខាងក្នុង។

## ៧- ខ្វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើសរីរាង្គភេទបុរសមួយណាដែលផលិតស្ពែមម៉ាតូសូអ៊ីត?

២- តើសរីរាង្គភេទស្ត្រីផ្នែកខាងក្នុងមានអ្វីខ្លះ?

**៨- លំហាត់** ( ជំហានទី៥ )

**បណ្តាំផ្ញើ** : ចូរអ្នកយកចំណេះដឹងនេះទៅចែករំលែកបន្តដល់មិត្តភក្តិនិងគ្រួសារ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនសរីរាង្គភេទ ត្រង់ចំណុចជើង □ដំណើរការនិងតួនាទីសរីរាង្គភេទ និង □ អនាម័យសរីរាង្គភេទស្ត្រី សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ ៖ សរីរាង្គភេទ (តចប់)

## ខ្លឹមសារម៉ោងទី២ ៖ ដំណើរការនិងតួនាទីសរីរាង្គភេទ និងអនាម័យសរីរាង្គភេទស្ត្រី

**១- រយៈពេល** ៖ ១ ម៉ោងសិក្សា

**២- វត្ថុបំណង** ៖ ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីដំណើរការនិងតួនាទីសរីរាង្គភេទ។<br>• រៀបរាប់ពីវិធានការអនាម័យសរីរាង្គភេទ។ | • បង្ហាញពីផ្នែកផ្សេងៗ និងតួនាទីនៃសរីរាង្គភេទ<br>• បង្ហាញពីវិធានការអនាម័យសរីរាង្គភេទ។ | • បណ្តុះទម្លាប់ថែទាំនិងធ្វើអនាម័យសរីរាង្គភេទទាំងប្រុស ស្រី និងអន្តរភេទ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ (ផ្ទាំងរូបភាព ឬបណ្ណពាក្យពាក់ព័ន្ធនឹងប្រព័ន្ធបន្តពូជមនុស្សប្រុស)។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- ដំណើរការ**និង**តួនាទីសរីរាង្គភេទ បុរសមាន លិង្គ ឡើងរឹងនៅពេលដែលមានចរន្តឈាមបាញ់ទៅបំពេញសាច់ដុំស្តោត។ ដំណើរការនិងតួនាទីសរីរាង្គភេទរបស់ស្ត្រីមាន **ថ្វាសយោនី** ដែលមានដុះរោមនិងមានសម្រើប **ទ្វារមាស** បញ្ចេញទឹករំអិលផ្លូវភេទ ឈាមរដូវ និងផ្លូវបង្កើតកូន។ **បបូរធំ ឬបបូរក្រៅ** មាននាទីគ្របនិងការពារផ្នែកខាងក្នុងរបស់ទ្វារមាស **បបូរតូចឬបបូរខាងក្នុង** មានមុខងារធ្វើឱ្យមានអារម្មណ៍សម្រើបនៅពេលដែលប៉ះវា **ឆ្អែញ (សិរ)** ជាសរីរាង្គមានរំញោចដែលផ្តល់ភាពសុខស្រួលនៃផ្លូវភេទ **រន្ធនោម** មានមុខងារបញ្ចេញទឹកនោមតែមួយមុខប៉ុណ្ណោះ ។
- **អនាម័យសរីរាង្គភេទ** ត្រូវងូតទឹកសម្អាតរាងកាយនិងសរីរាង្គភេទផ្នែកខាងក្រៅឱ្យបានស្អាតជានិច្ចជាមួយសាប៊ូ និងទឹកស្អាតឱ្យបានពីរទៅបីដងក្នុងមួយថ្ងៃ។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុមធំ ពន្យល់ បទបង្ហាញខ្នាតតូច។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្ដាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្ដាហ៍មុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន បន្ទាប់មកគ្រូសួរៈ តើមុខងារនិងរបៀបអនាម័យនៃសរីរាង្គភេទស្ត្រីមានអ្វីខ្លះ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ដំណើរការនិងតួនាទីសរីរាង្គភេទ**

- គ្រូពន្យល់ៈ ដំណើរការនិងតួនាទីសរីរាង្គភេទរបស់បុរសមាន លិង្គ ឡើងរឹងនៅពេលដែលមានចរន្តឈាមបាញ់ទៅបំពេញសាច់ដុំស្ពោត។ នៅពេលដែលមានការប៉ះ ឬមានរំញោចផ្លូវភេទលិង្គនឹងឡើងរឹង។ **ពងស្វាស** មានតួនាទីសម្រាប់ផលិតស្ពែម៉ាតូសូអ៊ីត (**Spermatozoid**) និងអ័រម៉ូនភេទបុរស។ ស្រោមពងស្វាស គឺសម្រាប់ទ្រនិងស្រោបពងស្វាសនិងជួយទ្រទ្រង់ការផលិតមេជីវិតឈ្មោល។

- គ្រូរៀបចំបណ្ណពាក្យពាក់ព័ន្ធនឹងដំណើរការ និងតួនាទីសរីរាង្គភេទស្ត្រី
- គ្រូណែនាំសិស្ស ឱ្យរៀបឃ្លាផ្គុំពាក្យឱ្យបានត្រឹមត្រូវ។ គ្រូទុកពេល៥ ទៅ១០នាទី
- គ្រូចែកកាតឃ្លាក្នុងឃ្លាទី១ និងឃ្លាទី២ ឱ្យសិស្សម្នាក់មួយសន្លឹក រួចឱ្យពួកគាត់ដើររកដៃគូដែលកាតមានអត្ថន័យនិងខ្លឹមសារត្រូវគ្នា។ បន្ទាប់មកដៃគូនីមួយៗត្រូវអានខ្លឹមសារក្នុងកាតរបស់ខ្លួនឱ្យយល់
- គ្រូសម្របសម្រួល និងបង្ហាញចម្លើយដែលមានរូបភាព និងពន្យល់អំពីដំណើរការ និងតួនាទីសរីរាង្គភេទស្ត្រី។

**ឯកសារឃ្លាដែលត្រូវផ្គុំគ្នា (ល្បែងរកដៃគូ)៖**

| ឃ្លាទី ១ | ឃ្លាទី ២ |
|---|---|
| ឆ្អេញ (សិរ) | ជាសរីរាង្គមានរំញោចដែលផ្ដល់ភាពសុខស្រួលនៃផ្លូវភេទ។ |
| បបូរធំ | មាននាទីគ្របនិងការពារផ្នែកខាងក្នុងរបស់ទ្វារមាស។ |
| បបូរតូច | មានមុខងារធ្វើឱ្យមានអារម្មណ៍សម្រើបនៅពេលដែលប៉ះវា។ |
| ទ្វារមាស | បញ្ចេញទឹករំអិលផ្លូវភេទ ឈាមរដូវ និងផ្លូវបង្កើតកូន។ |
| **រន្ធនោម** | មានមុខងារបញ្ចេញទឹកនោមតែមួយមុខប៉ុណ្ណោះ។ |

| ឃ្លាទី ១ | ឃ្លាទី ២ |
|---|---|
| ស្បូន | មានមុខងារយ៉ាងសំខាន់ដូចជា ជាប្រភពនៃឈាមរដូវ ជាផ្លូវរបស់មេជីវិតឈ្មោលធ្វើដំណើរទៅជួបមេជីវិតញីនៅដៃស្បូន ជាកន្លែងសម្រាប់ទារកលូតលាស់ និងជាសាច់ដុំកន្ត្រាក់នៅពេលបញ្ចេញឈាមរដូវ និងសម្រាលកូន។ |
| ដៃស្បូន | មាននាទីជាផ្លូវដែលមេជីវិតឈ្មោល និងមេជីវិតញីធ្វើដំណើរទៅជួបគ្នា។ |
| កន្សោមពងញី | មានតួនាទីផលិតមេជីវិតញីជារៀងរាល់ខែ និងខ្ទាក់មេជីវិតញីទុំទៅក្នុងដៃស្បូន វាមានតួនាទីផលិតអ័រម៉ូនភេទស្រ្តី គឺអឺស្រ្តូហ្សែន និងប្រូហ្សេស្តេរ៉ូន។ |
| មេជីវិតញី | គឺជាកោសិកាភេទញីបញ្ចេញដោយកន្សោមពងញី។ ប្រសិនបើគ្មានការបង្កកំណើតទេ វានឹងរលាយបាត់ទៅវិញ។ |

- គ្រូត្រូវពន្យល់បន្ថែមមានមនុស្សខ្លះមានក្រូម៉ូសូមភេទ អង្គជាតិភេទខាងក្រៅឬលក្ខណៈភេទទាំងពីរដែលមិនមែនជាប្រុស ឬជាស្រីសុទ្ធសាធ។
- គ្រូចែកសិស្សជាក្រុម ពិភាក្សាសំណួរ តើក្មេងស្រី ក្មេងប្រុស និងអន្តរភេទ ត្រូវធ្វើអនាម័យសរីរាង្គភេទដូចម្តេចខ្លះ ?
- គ្រូគូសតារាងខាងក្រោមឱ្យសិស្សបំពេញ៖

| ក្មេងស្រី | ក្មេងប្រុស | អន្តរភេទ |
|---|---|---|
| | | |

- តំណាងក្រុមឡើងបកស្រាយ
- គ្រូសំយោគ និងសម្របសម្រួលចម្លើយ។

**ចម្លើយ**

| ក្មេងស្រី | ក្មេងប្រុស | អន្តរភេទ |
|---|---|---|
| ត្រូវងូតទឹកសម្អាតរាងកាយនិងទ្វារមាសផ្នែកខាងក្រៅឱ្យបានស្អាតជានិច្ចជាមួយសាប៊ូនិងទឹកស្អាតឱ្យបានពីរទៅបីដងក្នុងមួយថ្ងៃ។ ក្រោយពេលបន្ទោរបង់រួច ស្ត្រីត្រូវជូត | ត្រូវងូតទឹកដុសសម្អាតរាងកាយនិងសរីរាង្គបន្តពូជឱ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូដុសខ្លួនឱ្យបានពីរឬបីដងក្នុងមួយថ្ងៃ។ ត្រូវដុសលាងលិង្គឱ្យបានស្អាតជានិច្ច ជាពិសេសផ្នែកខាងក្នុងនៃស្បែកគ្របក្បាលលិង្គ។ ក្នុង | ត្រូវងូតទឹកដុសសម្អាតរាងកាយនិងប្រដាប់ភេទឱ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូដុសខ្លួនឱ្យបានពីរឬបីដងក្នុងមួយថ្ងៃ។ គួរទៅពិគ្រោះជាមួយគ្រូពេទ្យឯក |

| | | |
|---|---|---|
| ឬលាងសម្អាតទ្វារមាសពីមុខទៅក្រោយ (ពីទ្វារមាសទៅរន្ធគូថ)។ ការជូតសម្អាតត្រូវប្រើក្រដាសទន់ស្អាត ការប្រើទឹកលាងសម្អាតជាការប្រសើរ។ | ករណីមានស្បែកគ្របក្បាលលិង្គ (Phimosis) មិនទាន់ពន្លាត់ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេស។ | ទេសអំពីការលូតលាស់ប្រដាប់ភេទឱ្យបានញឹកញាប់។ |

❖ គ្រូឱ្យសិស្សកត់ត្រាមេរៀនសង្ខេបចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ដំណើរការនិងតួនាទីសរីរាង្គភេទរបស់បុរសនៅពេលដែលមានការប៉ះ ឬមានរំញោចផ្លូវភេទ លិង្គនឹងឡើងរឹង ដោយចរន្តឈាមបាញ់ទៅបំពេញសាច់ដុំស្ពោត។ ដំណើរការនិងតួនាទី សរីរាង្គភេទរបស់ស្ត្រីមានទ្វារមាសបញ្ចេញទឹករំអិលផ្លូវភេទ ឈាមរដូវ និងផ្លូវបង្កើតកូន។ អនាម័យសរីរាង្គភេទត្រូវជូតទឹកសម្អាតរាងកាយនិងសរីរាង្គភេទផ្នែកខាងក្រៅឱ្យបានស្អាតជានិច្ចជាមួយសាប៊ូ និងទឹកស្អាតឱ្យបានពីរទៅបីដងក្នុងមួយថ្ងៃ៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើសរីរាង្គភេទស្ត្រីមួយណាដែលផលិតមេជីវិតញី (ស៊ុត) ?

២- តើក្មេងស្រី ក្មេងប្រុស និងអន្តរភេទត្រូវធ្វើអនាម័យប្រដាប់បន្តពូជតាមរបៀបណាខ្លះ ?

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ**

១- ចូរអ្នកយកចំណេះដឹងនេះទៅចែករំលែកបន្តដល់មិត្តភក្តិបន្ត។

២- ចូរអ្នកធ្វើអនាម័យជាប្រចាំនូវសរីរាង្គភេទរបស់អ្នក។ ក្នុងករណីមានភាពមិនធម្មតាលើប្រដាប់ភេទ (ឧទាហរណ៍ ៖ ពងបែក រមាស់ បូស ។ល។) ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេស។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការមករដូវ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : ការមករដូវ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យការមករដូវ និងវដ្តរដូវ<br>• រៀបរាប់ពីអាការៈនិងអនាម័យនៅពេលមករដូវ។ | • បង្ហាញពីអាការៈនៃការមករដូវដែលត្រូវជួបគ្រូពេទ្យជំនាញ<br>• បង្ហាញពីវិធានអនាម័យនៅពេលមករដូវ។ | • បណ្ដុះទម្លាប់ទៅពិគ្រោះជាមួយពេទ្យជំនាញនៅពេលមានបញ្ហានៃការមករដូវ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- **និយមន័យ** : ការមករដូវមានន័យថា រាងកាយរបស់ក្មេងស្រីកំពុងធ្វើការលូតលាស់ និងកំពុងត្រៀមខ្លួន សម្រាប់អនាគតរបស់នាង ពីព្រោះវាគឺជាពេលវេលាដែលនាងអាចពពោះនិងមានកូនបាន។
- **វដ្តរដូវរបស់ក្មេងស្រី** : ជាធម្មតាចាប់ពីថ្ងៃទីមួយនៃការមករដូវ (ពេលមានការហូរឈាមចាប់ផ្ដើម) រហូតដល់ថ្ងៃទីមួយនៃរដូវបន្ទាប់ គឺមានរយៈពេល ២៨ថ្ងៃ (១ខែ) ប៉ុន្តែចំនួនថ្ងៃនេះអាចប្រែប្រួលពី ២១ថ្ងៃ ទៅ ៣៥ថ្ងៃ អាស្រ័យទៅតាមក្មេងស្រី ឬស្ត្រីនោះ។
- **អាការៈនៃការមករដូវ** : ពេលមករដូវដំបូងមានអាការៈឈឺចាប់តិចតួចដូចជា ឆាយចង្កេះ ឈឺសុដន ចុកនៅក្រោមថ្ងាស សភាពបែបនេះជារឿងធម្មតា នៅពេលមករដូវ អស់ឈាមប្រហែលជា៤ ស្លាបព្រាបាយប៉ុណ្ណោះ។
- **អាការៈនៃការមករដូវដែលគួរទៅជួបគ្រូពេទ្យ** : ប្រសិនបើពេលមករដូវ មានការឈឺចាប់ខ្លាំង ហើយឈាមធ្លាក់ច្រើន ក្ដៅខ្លួន និងលើសពី៧ថ្ងៃ។
- **អនាម័យពេលមករដូវ** : ប្រើប្រាស់សំឡីអនាម័យត្រូវផ្លាស់ប្ដូរ២ទៅ៣ម៉ោងម្ដង ត្រូវលាងប្រដាប់ភេទ២ទៅ៣ដងក្នុងមួយថ្ងៃ និងត្រូវងូតទឹកដុសសម្អាតខ្លួនប្រាណ ត្រូវញ៉ាំអាហារឱ្យបានគ្រប់គ្រាន់ ពិសេសញ៉ាំបន្លែ និងផ្លែឈើ ដើម្បីជួយដល់សុខភាពសម្រាកឱ្យបានច្រើន និងធ្វើលំហាត់ប្រាណ។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ក្រុមពិភាក្សា បកស្រាយ ពន្យល់ សំណួរ ចម្លើយ សម្ដែងតួ។

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុសៈ

  ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន ?

  - គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
  - គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : និយមន័យនៃការមករដូវ**

១- គ្រូសួរសំណួរ តើការមករដូវមានន័យដូចម្តេច ? ទុកពេល១ទៅ២នាទីរួចហៅសិស្ស៣-៤នាក់ ឱ្យឆ្លើយ

- កត់ត្រាចម្លើយសិស្សពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេបតាមខ្លឹមសារនៃមេរៀន

ចម្លើយ : ការមករដូវមានន័យថា រាងកាយរបស់ក្មេងស្រីកំពុងធ្វើការលូតលាស់ និងកំពុងត្រៀមខ្លួនសម្រាប់អនាគតរបស់នាង ពីព្រោះវាគឺជាពេលវេលាដែលនាងអាចពពោះនិងមានកូនបាន។

- គ្រូបង្ហាញរូបភាពនិងសួរសំណួរ តើដូចម្តេចដែលហៅថាវដ្តនៃការមករដូវ ?



- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេបតាមខ្លឹមសារនៃមេរៀន។

ចម្លើយ : វដ្តរដូវរបស់ក្មេងស្រីភាគច្រើន មករដូវជាលើកដំបូងនៅចន្លោះអាយុពី១១ ទៅ១៤ឆ្នាំ។ ក្មេងស្រីខ្លះអាចចាប់ផ្តើមតាំងពីអាយុ ៨ឆ្នាំ រីឯក្មេងស្រីខ្លះទៀតអាចយឺតរហូតទៅដល់អាយុ១៧ឆ្នាំ ឬក៏យឺតជាងនេះ។ ជាធម្មតាចាប់ពីថ្ងៃទីមួយនៃការមករដូវ ( ពេលមានការហូរឈាមចាប់ផ្តើម ) រហូតដល់ថ្ងៃទីមួយនៃ

រដូវបន្ទាប់ គឺមានរយៈពេល ២៨ថ្ងៃ ( ១ខែ ) ប៉ុន្តែចំនួនថ្ងៃនេះអាចប្រែប្រួលពី ២១ថ្ងៃ ទៅ ៣៥ថ្ងៃ អាស្រ័យទៅតាមក្មេងស្រី ឬស្ត្រីនោះ។




២- ក្រុមតូចពិភាក្សា (១០នាទី) : គ្រូចែកសិស្សជា៣ក្រុមពិភាក្សាសំណួរខាងក្រោម៖

ក- ចូររៀបរាប់អាការៈពេលមករដូវ

ខ- ចូររៀបរាប់ពីរបៀបអនាម័យនៅពេលមករដូវ

គ- ចូររៀបរាប់ពីអាការៈនៃការមករដូវដែលត្រូវទៅជួបគ្រូពេទ្យ

- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេប តាមខ្លឹមសារនៃមេរៀនរួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅកិច្ចការ។

**ចម្លើយ**

**ក- អាការៈនៃការមករដូវដំបូង**

ក្មេងស្រីខ្លះមិនមានអារម្មណ៍ឈឺចាប់ នៅពេលដែលពួកគេមានរដូវទេប៉ុន្តែក្មេងស្រីខ្លះមានការឈឺចាប់តិចៗនៅក្រោមផ្ចិត និងចង្កេះហើយក្មេងស្រីខ្លះទៀតមានការឈឺចាប់ខ្លាំង ដែលនាងប្រហែលជាត្រូវលេបថ្នាំបំបាត់ការឈឺចាប់។ ធម្មតាការឈឺចាប់មិនសូវខ្លាំងហើយយូរទេ។ គេហៅឈឺចាប់នេះថា "ការចុករមួល" ពីព្រោះវាបណ្តាលមកពីសាច់ដុំស្បូនកន្ត្រាក់ខ្លាំង។ ការកន្ត្រាក់នេះហើយរុញទម្លាក់ស្រទាប់ភ្នាសស្តើងនៅក្នុងស្បូនដែលដាច់ ចេញមកក្រៅរៀងរាល់ខែ។

**ខ- អនាម័យពេលមករដូវ**

- ពេលមករដូវត្រូវសម្អាតប្រដាប់ភេទ២ឬ៣ដងក្នុងមួយថ្ងៃ
- ពេលសម្អាតត្រូវសម្អាតពីទ្វារមាសទៅខាងក្រោយទ្វារលាមកចៀសវាងការចម្លងរោគ
- ត្រូវងូតទឹកសម្អាតខ្លួនប្រាណ និងអនាម័យប្រដាប់ភេទ
- ត្រូវផ្លាស់ប្តូរសំឡីអនាម័យរាល់២ទៅ៣ម៉ោងម្តង
- ក្មេងស្រីពេលមករដូវត្រូវដាក់សំឡីអនាម័យទៅផ្លាស់នៅសាលារៀន
- បើប្រើកំណាត់សំពត់ត្រូវបោកគក់សម្អាតជាមួយទឹកនិងសាប៊ូឱ្យស្អាត និងហាលឱ្យត្រូវពន្លឺថ្ងៃ
- មិនត្រូវទៅហែលទឹក បឹង ត្រពាំង ទន្លេទេ
- បើអ្នកប្រើប្រាស់សំឡីអនាម័យ អ្នកត្រូវរុំខ្ចប់សំឡីអនាម័យជាមួយក្រដាសដូច្នេះ វាមិនមានភាពកខ្វក់ ហើយយកវាទៅបោះចោលក្នុងធុងសំរាម និងអាចដុតវាចោលនៅពេលក្រោយ។



ងូតទឹកសម្អាតខ្លួនប្រាណ និងអនាម័យប្រដាប់ភេទ

**គ- អាការៈនៃការមករដូវដែលគួរទៅជួបគ្រូពេទ្យ៖**

- ខួបឈាមរដូវខ្លីតិចជាង២១ថ្ងៃ ឬលើសពី៣៥ថ្ងៃ
- រយៈពេលធ្លាក់ឈាមរដូវលើសពី១០ថ្ងៃ
- ធ្លាក់ឈាមមិនទៀងទាត់ចន្លោះរដូវ
- រាំងរដូវ២-៣ខែ
- បរិមាណឈាមរដូវមកតិចពេក ឬមកច្រើនពេក
- ឈឺចាប់ក្នុងពោះខ្លាំងពេលមានឈាមរដូវ
- ឆាប់មករដូវលើកដំបូងពេក (ឆាប់គ្រប់ការ ក្រោមអាយុ៩ឆ្នាំ)
- ក្រមកឈាមរដូវលើកដំបូងពេក (ក្រគ្រប់ការលើសពី១៨ឆ្នាំ)។

• គ្រូហៅសិស្សពី៤ ទៅ៥នាក់ឱ្យឆ្លើយសំណួរៈ តើក្មេងស្រីត្រូវប្រើប្រាស់សំឡីអនាម័យរបៀបណា?

• គ្រូសំយោគចម្លើយតាមខ្លឹមសារមេរៀន និងបង្ហាញរូបភាព របៀបប្រើប្រាស់សំឡីអនាម័យ

**ចម្លើយ** : **របៀបប្រើប្រាស់សំឡីអនាម័យ៖**

- អំឡុងពេលមករដូវ ក្មេងស្រីឬស្ត្រី ប្រើប្រាស់សំឡីអនាម័យ ឬកំណាត់ទ្រាប់ ដើម្បីស្រូបយកឈាមដែលធ្លាក់ និងកុំឱ្យឈាមនោះលេចជ្រាបទៅលើខោទ្រនាប់ ឬសម្លៀកបំពាក់របស់ខ្លួន។
- សំឡីអនាម័យមួយចំនួនមានជ័រការស្អិតតូចនៅម្ខាងទៀត ដើម្បីទប់សំឡីនោះនៅមួយកន្លែង។ ប្រសិនបើក្មេងស្រីពុំអាចរកសំឡីអនាម័យបានទេ នាងក៏អាចប្រើកំណាត់ក៏បានដែរ។
- ក្មេងស្រីឬ ស្ត្រីគួរផ្លាស់សំឡី ឬកំណាត់ ឱ្យបានញឹកញាប់តាមការចាំបាច់ ប៉ុន្តែត្រូវប្តូរឱ្យបានយ៉ាងតិចរៀងរាល់ ២-៣ ម៉ោងម្តង ឬប្រហែលជាបួនដងក្នុងមួយថ្ងៃ។
- សំឡីអនាម័យយករាមកបកស្រោមចេញ ហើយយកផ្នែកស្អិត បិទភ្ជាប់ទៅនឹងខោទ្រនាប់។



❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការមករដូវ ជាលក្ខណៈធម្មជាតិរបស់ក្មេងស្រី និងស្ត្រី នៅពេលក្មេងស្រីមករដូវបញ្ជាក់ថាពួកគេអាចនឹងមានកូនប្រសិនបើរួមភេទគ្មានការការពារ។ ការមករដូវនៅចន្លោះអាយុ ៩ ទៅ១៨ ឆ្នាំ ហើយរដូវធម្មតាមាន រយៈពេល ៤ ថ្ងៃ ទៅ ៧ ថ្ងៃ វដ្តរដូវមាន ២១ ថ្ងៃទៅ ៣៥ ថ្ងៃ ជាមធ្យមគឺ២៨ថ្ងៃ។ ប្រសិនបើមកឈាមរដូវលើសពី១០ថ្ងៃ ឈឺចាប់ក្នុងពោះខ្លាំង ឈាមរដូវមកតិចពេក ឬមកច្រើនពេក ឆាប់គ្រប់ការក្រោមអាយុ៩ឆ្នាំ ឬយឺតក្នុងការមករដូវលើកដំបូង (ក្រគ្រប់ការលើសពី១៧ឆ្នាំ )។ ពេលមករដូវ គួរផ្លាស់ប្តូរសំឡីអនាម័យ២ ទៅ៣ម៉ោងម្តង ត្រូវលាងប្រដាប់ភេទ២ទៅ៣ដងក្នុងមួយថ្ងៃ និងត្រូវងូតទឹកដុសសម្អាតខ្លួនប្រាណជាប្រចាំ ។

## ៧- វាយតម្លៃ ( ជំហានទី៤ )

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ការមករដូវចាប់ផ្តើមនៅចន្លោះអាយុប៉ុន្មានឆ្នាំ? ចូររៀបរាប់អាការៈពេលមករដូវ។

២- តើវដ្តរដូវមានរយៈពេលប៉ុន្មានថ្ងៃ? និងជាមធ្យមប៉ុន្មានថ្ងៃដែរ? ពេលមករដូវប្អូនត្រូវតមអ្វីខ្លះ?

៣- ចូររៀបរាប់ពីរបៀបប្រើសំឡីអនាម័យ និងរបៀបអនាម័យនៅពេលមករដូវ។

## ៨- លំហាត់ ( ជំហានទី៥ )

**បណ្តាំផ្ញើ**

១- ចូរអ្នកយកចំណេះដឹងនេះទៅចែករំលែកបន្តដល់មិត្តភក្តិ។

២- ចូរអ្នកធ្វើអនាម័យជាប្រចាំនៅពេលមករដូវ។

**កិច្ចការផ្ទះ** : ចូរប្អូនមើលមេរៀនកាកសំណល់និងផលប៉ះពាល់សុខភាព សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : កាកសំណល់និងផលប៉ះពាល់សុខភាព

**ខ្លឹមសារម៉ោងទី១** : កាកសំណល់រឹង កាកសំណល់រាវ និងផលប៉ះពាល់នៃកាកសំណល់ចំពោះសុខភាព

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ "កាកសំណល់"<br>• ពណ៌នាពីកាកសំណល់រឹង រាវ និងផលប៉ះពាល់ ។ | • បង្ហាញពីផលវិបាកនិងផលប៉ះពាល់នៃកាកសំណល់ចំពោះសុខភាព | • ដើម្បីជួយកាត់បន្ថយសំរាមប្រចាំថ្ងៃ ។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- **សំណល់** គឺជាសារធាតុ រឹង រាវ និងឧស្ម័នទាំងឡាយ ដែលពុំមានតម្លៃតទៅទៀតសម្រាប់អ្នកប្រើប្រាស់ ហើយត្រូវគេបោះចោលទៅក្នុងបរិស្ថាន។
- **កាកសំណល់រឹង** គឺជារូបធាតុនានាដែលគ្មានសារប្រយោជន៍ទៀត នៅក្នុងទម្រង់ឬលក្ខខណ្ឌបច្ចុប្បន្នរបស់វា។ សំណល់រឹងចែកជាបីក្រុម : សំណល់រឹងគ្មានគ្រោះថ្នាក់ សំណល់រឹងប្រកបដោយគ្រោះថ្នាក់ និងសំណល់វិទ្យុសកម្ម។
- **កាកសំណល់រាវ** គឺជាសំណល់រាវ រួមមានប្រភពសំណល់រាវចេញពីខ្លាញ់ ប្រេង ឬទឹក ដែលប្រើប្រាស់ហើយមានប្រភពមកពីលំនៅឋាន កសិដ្ឋាន និងឧស្សាហកម្ម។
- **ផលប៉ះពាល់នៃកាកសំណល់ចំពោះសុខភាពមាន**: ការបំពុលខ្យល់ ការបំពុលទឹក ការចម្លងជំងឺដល់មនុស្ស ធ្វើឱ្យកខ្វក់ដល់បរិស្ថាន ប៉ះពាល់ដល់សុខភាពទាំងផ្លូវចិត្ត និងផ្លូវកាយរបស់មនុស្ស។ ធ្វើឱ្យប៉ះពាល់ដល់ជីវិតសត្វ រុក្ខជាតិ និងមានឥទ្ធិពលអាក្រក់ដល់ទេសចរណ៍ និងសេដ្ឋកិច្ច។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន? ចម្លើយសិស្ស : ......

  ៣- តើកាកសំណល់មានអ្វីខ្លះ? គេចែកកាកសំណល់ជាប៉ុន្មានប្រភេទ?

- គ្រូទុកពេល២នាទីឱ្យសិស្សគិត រួចហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្តារខៀន ។
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : កាកសំណល់រឹង កាកសំណល់រាវ និងផលប៉ះពាល់នៃកាកសំណល់ចំពោះសុខភាព**

- គ្រូបង្ហាញរូបភាព រួចសួរសិស្ស តើរូបនីមួយៗប្អូនឃើញមានអ្វីខ្លះ?









- គ្រូសម្របសម្រួលចម្លើយ។
- គ្រូបែងចែកសិស្សជាបីក្រុមពិភាក្សាលើសំណួរខាងក្រោម ក្នុងរយៈពេល៥ទៅ១០នាទី

  ក្រុមទី១ : តើកាកសំណល់រឹងមានអ្វីខ្លះ?

  ក្រុមទី២ : តើកាកសំណល់រាវមានអ្វីខ្លះ?

  ក្រុមទី៣ : តើកាកសំណល់មានផលប៉ះពាល់អ្វីខ្លះដល់សុខភាព?

- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

  **ចម្លើយ**

- **កាកសំណល់រឹង** គឺជារូបធាតុនានាដែលគ្មានសារប្រយោជន៍ទៀត នៅក្នុងទម្រង់ឬលក្ខខណ្ឌបច្ចុប្បន្នរបស់វា។ សំណល់រឹងចែកជាបីក្រុម : សំណល់រឹងគ្មានគ្រោះថ្នាក់ សំណល់រឹងប្រកបដោយគ្រោះថ្នាក់ និងសំណល់វិទ្យុសកម្ម។
- **កាកសំណល់រាវ** គឺជាសំណល់រាវ រួមមានប្រភពសំណល់រាវចេញពីខ្លាញ់ ប្រេង ឬទឹក ដែលប្រើប្រាស់ហើយមានប្រភពមកពីលំនៅឋាន កសិដ្ឋាន និងឧស្សាហកម្ម។
- **ផលប៉ះពាល់នៃកាកសំណល់ចំពោះសុខភាពមាន**: ការបំពុលខ្យល់ ការបំពុលទឹក ការចម្លងជំងឺដល់មនុស្ស ធ្វើឱ្យកខ្វក់ដល់បរិស្ថាន ប៉ះពាល់ដល់សុខភាពទាំងផ្លូវចិត្ត និងផ្លូវកាយរបស់មនុស្ស។ ធ្វើឱ្យប៉ះពាល់ដល់ជីវិតសត្វ រុក្ខជាតិ និងមានឥទ្ធិពលអាក្រក់ដល់ទេសចរណ៍ និងសេដ្ឋកិច្ច។

❖ គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប។



**មេរៀនសង្ខេប**

សំណល់ គឺជាសារធាតុ រឹង រាវ និងឧស្ម័នទាំងឡាយ ដែលពុំមានតម្លៃតទៅទៀតសម្រាប់អ្នកប្រើប្រាស់ ហើយត្រូវគេបោះចោលទៅក្នុងបរិស្ថាន។ សំណល់រឹងចែកជាបីក្រុមដូចជា  សំណល់រឹងគ្មានគ្រោះថ្នាក់ សំណល់រឹងប្រកបដោយគ្រោះថ្នាក់ និងសំណល់វិទ្យុសកម្ម។ សំណល់រាវ មានប្រភពពីខ្លាញ់ ប្រេងនិងទឹកដែលប្រើប្រាស់មកពីលំនៅដ្ឋាន កសិដ្ឋាន និងឧស្សាហកម្ម។ កាកសំណល់មានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសុខភាពសាធារណៈនិងបរិស្ថាន ប្រសិនណា បើគេស្តុក ប្រមូល និងចាក់ចោលមិនត្រឹមត្រូវដូចជា ការបំពុលខ្យល់និងទឹក នាំឱ្យមានការចម្លង ជំងឺគ្រុនពោះវៀន រាកមួល រលាកពោះវៀន និងជំងឺថ្លើម ...។

**៧- វាយតម្លៃ** ( ជំហានទី៤ )

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើកាកសំណល់រឹងមានអ្វីខ្លះ ?

២- តើកាកសំណល់រាវមានអ្វីខ្លះ ?

៣- តើកាកសំណល់មានផលប៉ះពាល់អ្វីខ្លះដល់សុខភាព ?

**៨- លំហាត់** ( ជំហានទី៥ )

**បណ្តាំផ្ញើ** : ចូរអ្នកទុកដាក់កាកសំណល់រឹងនិងរាវនៅផ្ទះ និងសាលាឱ្យបានត្រឹមត្រូវ ដើម្បីកុំឱ្យមានផលប៉ះពាល់ដល់សុខភាព។

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវ ពីវិធីកាត់បន្ថយកាកសំណល់នៅផ្ទះ សាលា និងក្នុងសហគមន៍របស់ប្អូន ? គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ភាគសំណល់និងផលប៉ះពាល់សុខភាព (តចប់)

## ខ្លឹមសារម៉ោងទី២ : ការកាត់បន្ថយសំរាម

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ពណ៌នាពីវិធីកាត់បន្ថយសំរាម តាមយុទ្ធសាស្ត្រ "ប" បី | • បង្ហាញពីការកាត់បន្ថយសំរាម តាមយុទ្ធសាស្ត្រ "ប" បី | • ចូលរួមអនុវត្តយុទ្ធសាស្ត្រ"ប" បី ដើម្បីជួយកាត់ បន្ថយសំរាម ប្រចាំថ្ងៃ ។ |

**៣- សម្ភារៈ**

សៀវភៅសិស្ស រូបភាពក្នុងសៀវភៅ និងក្រដាសផ្ទាំងធំ ហ្វឺត ស្កុត។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

មានយុទ្ធសាស្ត្រដើម្បីកាត់បន្ថយសំរាម : **ប១** បន្ថយការប្រើប្រាស់ គឺជាការប្រើប្រាស់សម្ភារៈតិចជាងមុន ដូចជាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិច តាមរយៈការប្រើប្រាស់ថង់កំណាត់ ឬកន្ត្រកត្បាញ ចានស្រាក់ ។ល។ **ប២** ប្រើប្រាស់ឡើងវិញ មានសម្ភារៈជាច្រើនដែលយើងអាចប្រើប្រាស់ឡើងវិញបាន ។ **ប៣** បំប្លែង គឺជាការយកសំណល់ដែលបោះចោលមកកែច្នៃឡើងវិញ ឬមកបំប្លែងទៅជាផលិតផលថ្មី។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់ ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន
  - ៣- តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីកាត់បន្ថយកាកសំណល់នៅផ្ទះ សាលារៀន និងក្នុងសហគមន៍?
- គ្រូហៅសិស្ស២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)

**ខ្លឹមសារ : ការកាត់បន្ថយសំរាម (ការអនុវត្តយុទ្ធសាស្ត្រ”ប”បី)**

- គ្រូពន្យល់ពីយុទ្ធសាស្ត្រ “ប” បី ដើម្បីកាត់បន្ថយសំរាម
- គ្រូបែងចែកសិស្សជាបីក្រុមពិភាក្សាលើសំណួរខាងក្រោម ក្នុងរយៈពេល៥ទៅ១០នាទី
  ក្រុមទី១ : តើយុទ្ធសាស្ត្រ ប១ ធ្វើដូចម្តេចខ្លះ ? ចូរពន្យល់និងបកស្រាយ
  ក្រុមទី២ : តើយុទ្ធសាស្ត្រ ប២ ធ្វើដូចម្តេចខ្លះ ? ចូរពន្យល់និងបកស្រាយ
  ក្រុមទី៣ : តើយុទ្ធសាស្ត្រ ប៣ ធ្វើដូចម្តេចខ្លះ ? ចូរពន្យល់និងបកស្រាយ
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយតាមខ្លឹមសារមេរៀន។



**ចម្លើយ**

**ប១ : បន្ថយការប្រើប្រាស់** : គឺជាការប្រើប្រាស់សម្ភារតិចជាងមុន ដូចជាការប្រើប្រាស់ថង់កំណាត់ ឬ កន្ត្រកត្បាញ ចានស្រាក់... ជំនួសការប្រើប្រាស់ប្លាស្ទិច។ ការប្រសើរយើងត្រូវទិញទំនិញពីហាងដែលមានការវេចខ្ចប់ពីសម្ភារៈដែលងាយរលួយដូចជា ក្រដាស ស្លឹកចេក ស្លឹកឈូក...។ ចៀសវាងប្រើប្រាស់ផលិតផលដែលបង្កើតសំរាមច្រើនដូចជា កែវជ័រ ចានជ័រ ប្រអប់ស្នោ ជាពិសេសថង់ប្លាស្ទិច ជាប្រភពនៃសំរាមដ៏ចម្បង។

**ប២ : ប្រើប្រាស់ឡើងវិញ** : មានសម្ភារជាច្រើនដែលយើងអាចប្រើប្រាស់ឡើងវិញបាន ដូចជាប្រអប់ដាក់អាហារ ដបកែវ ឬប្លាស្ទិច។ ការប្រើប្រាស់ឡើងវិញ ក៏អាចកាត់បន្ថយនូវបរិមាណសំណល់ ដែលបញ្ចេញចោលបានដែរ។ ប្រទេសមួយចំនួនបានលើកទឹកចិត្តការផលិតទំនិញដែលងាយនឹងយកទៅប្រើប្រាស់ជាថ្មី ឬរបស់ដែលអាចប្រើបានយូរ។ ទឹកដែលប្រើរួចអាចយកមកប្រើឡើងវិញបានដោយទុកវាឱ្យរង បន្សាបជាតិពុល ឆ្លងប្រព័ន្ធបន្សុទ្ធ ឬសម្លាប់មេរោគជាមុន ។



ចានស្រាក់អនាម័យល្អនិងប្រើប្រាស់យូរអង្វែង

**ប៣ : បំប្លែង** : បំប្លែងឬការកែច្នៃឡើងវិញ គឺជាការយកសំណល់ដែលបោះចោលមកកែច្នៃឡើងវិញ ឬមកបំប្លែងទៅជាផលិតផលថ្មីដូចជា ក្រដាស ប្លាស្ទិច កែវ លោហធាតុ អាលុយមីញ៉ូម ដែកថែប សំណល់អាហារ ។ល។ ឧទាហរណ៍មួយចំនួនពីការបំប្លែង៖

- **ការបំប្លែងពីសំណល់សរីរាង្គទៅធ្វើជាជីកំប៉ុស** ដោយទុកឱ្យសំណល់សរីរាង្គ (សំណល់ពីបន្លែ ផ្លែឈើ សំបកដូងទុំ សំបកពងមាន់...) ទាំងនោះបំបែកជាតុទៅជាផលិតផលសរីរាង្គសម្រេច ដែលអាចយកទៅប្រើប្រាស់ជាជីសម្រាប់កសិកម្ម ឬសម្រាប់កែលម្អគុណភាពដី។



សំណល់ចំណីអាហារបំប្លែងផលិតជាជីកំប៉ុស្ត

- **ការបំប្លែងពីសំណល់កង់ឡានទៅជាប្រដាប់ប្រើប្រាស់** ដូចជាយកកង់ឡានលែងប្រើបានទៅច្នៃនិងបំប្លែងទៅជា ថ្នាលសម្រាប់ដំណាំកសិកម្ម ធុងសំរាម ឧបករណ៍សម្រាប់ក្មេងលេងដូចជា ទោងលូន លោត ធ្វើជារបង។ល។
  - ការបំប្លែងពីកំណាត់សេសសល់ទៅជារបស់ប្រើបាស់ដូចជាកំណាត់ជូតជើង អង្រឹង។ល។
  - ការបំប្លែងពីកាកសំណល់រាវ ( ទឹកនោម លាមក ... ) ទៅធ្វើជា ជីវឧស្ម័ន។



សំបក ឬកេសក្រដាស
ច្នៃប្រើប្រាស់ឡើងវិញ



ការច្នៃសំណល់ដប ប្លាស្ទិច
សម្រាប់ប្រើប្រាស់ផ្សេងៗ

❖ គ្រូបិទមេរៀនសង្ខេប និងហៅសិស្សឡើងអាន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅកិច្ចការ។



**មេរៀនសង្ខេប**

យុទ្ធសាស្ត្រ"ប៣" ដើម្បីកាត់បន្ថយសំរាមមានដូចជា ប១: បន្ថយការប្រើប្រាស់គឺជា ការប្រើប្រាស់សម្ភារៈតិចជាងមុន ដូចជាការប្រើប្រាស់ថង់កំណាត់ ឬកន្ត្រកត្បាញ ចានស្រាក់ ជំនួសការប្រើប្រាស់ប្លាស្ទិច។ ប២: ការប្រើប្រាស់ឡើងវិញគឺ សម្ភារៈជាច្រើនដែលយើងអាចប្រើប្រាស់ឡើងវិញបាន ដូចជាប្រអប់ដាក់អាហារ  ដបកែវ ឬប្លាស្ទិច។ ប៣: បំប្លែងឬការកែច្នៃឡើងវិញ គឺជាការយកសំណល់ដែលបោះចោលមកកែច្នៃឡើងវិញ ឬមកបំប្លែងទៅជាផលិតផលថ្មីដូចជា ក្រដាស ប្លាស្ទិច កែវ លោហធាតុ អាលុយមីញ៉ូម ដែកថែប សំណល់អាហារ៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីយុទ្ធសាស្ត្រ"ប" បី ក្នុងការកាត់បន្ថយសំរាម

**៨- លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកចូលរួមអនុវត្តយុទ្ធសាស្ត្រ"ប"បី ដើម្បីជួយកាត់បន្ថយសំរាមប្រចាំថ្ងៃ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការបំពុលទឹកនិងផលប៉ះពាល់សុខភាព សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការបំពុលទឹកនិងផលប៉ះពាល់សុខភាព

## ខ្លឹមសារម៉ោងទី១ : ប្រភពទឹកប្រើប្រាស់និងការបំពុលប្រភពទឹក

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹង៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់ពីប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ<br>• រៀបរាប់ពីការបំពុលទឹក។ | • បង្ហាញពីមូលហេតុនៃការបំពុលទឹក<br>• សង្កេតមើលប្រភពទឹកក្នុងសហគមន៍ដែលអ្នកប្រើប្រាស់តើមានការបំពុលទឹកដែរឬទេ? | • បណ្តុះស្មារតីយកចិត្តទុកដាក់ចូលរួមថែរក្សាការពារប្រភពទឹកមិនឱ្យមានការបំពុល។ |

**៣- សម្ភារ:**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- **ប្រភពទឹកប្រើប្រាស់** មាននៅគ្រប់ទីកន្លែងដូចជា នៅលើដី ក្រោមដី ទឹកកក និងទឹកភ្លៀង។ លើដីមានទឹក ស្ទឹង បឹង ត្រពាំង ទន្លេ អូរ អាងស្តុកទឹក ប្រឡាយ ក្រោមដីមាន និងទឹកអណ្តូង។
- **ការបំពុលប្រភពទឹក** គឺបង្កឡើងដោយសារ កត្តាមនុស្ស ការរីកចំរើនផ្នែកបច្ចេកវិទ្យា និងកត្តា ធម្មជាតិដែលនាំឱ្យប៉ះពាល់ដល់សុខភាពបង្កឡើងដោយបាក់តេរី វីរុស និងប៉ារ៉ាស៊ីតដែលបង្កឱ្យមានជំងឺ ដូចជា គ្រុនពោះវៀន រាក សើស្បែក ដង្កូវព្រូន រលាកថ្លើម។ល។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន? ចម្លើយសិស្ស : ......

៣- តើទឹកដែលយើងប្រើប្រាស់ប្រចាំថ្ងៃមានប្រភពមកពីណាខ្លះ?

៤- តើការបំពុលទឹកបណ្តាលមកពីអ្វី?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារ : ប្រភពទឹកប្រើប្រាស់ ការបំពុលប្រភពទឹក**

- គ្រូបង្ហាញរូបភាពនិងពន្យល់ពីប្រភពទឹកនិងប្រភពនៃការបំពុលទឹក



ប្រភពទឹក



ការបន្ទោបង់និងសង់បង្គន់លើប្រភពទឹកប្រើប្រាស់



លាងសត្វពាហនៈក្នុងប្រភពទឹកប្រើប្រាស់




ការបង្ហូរកាកសំណល់ពីរោងចក្រ



សំណល់ថ្នាំពុលកសិកម្មពីថ្នាំសម្លាប់សត្វល្អិត



កាកសំណល់ហូរតាមទឹកក្នុងទន្លេ

- គ្រូបែងចែកសិស្សជាបួនក្រុមពិភាក្សាលើសំណួរខាងក្រោម ក្នុងរយៈពេល៥ទៅ១០នាទី

  ក្រុមទី១ : តើទឹកដែលយើងប្រើប្រាស់មានប្រភពមកពីណាខ្លះ ?

ក្រុមទី២ : តើការបំពុលទឹកដោយកត្តាមនុស្សមានអ្វីខ្លះ ?

ក្រុមទី៣ : តើការបំពុលទឹកដោយការរីកចម្រើនផ្នែកបច្ចេកវិទ្យាមានអ្វីខ្លះ ?

ក្រុមទី៤ : តើការបំពុលទឹកដោយកត្តាធម្មជាតិមានអ្វីខ្លះ ?

- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសង្ខេបនិងសំយោគចម្លើយ៖
  - ប្រភពទឹកប្រើប្រាស់មាននៅគ្រប់ទីកន្លែងដូចជា ទឹកនៅលើដី ទឹកក្រោមដី ទឹកកក និងទឹកភ្លៀង
  - ការបំពុលប្រភពទឹកបណ្ដាលមកពី កត្តាមនុស្សដូចជា : ការបង្ហូរទឹកសម្អុយ កាកសំណល់ចូលក្នុងប្រភពទឹក ការបន្ទោបង់ចូលក្នុងប្រភពទឹក ការបោកគក់ លាងសត្វពាហនៈក្នុងប្រភពទឹក ចោលសំរាមក្នុងប្រភពទឹក ការសង់លំនៅដ្ឋានលើប្រភពទឹក...។
  - ការបំពុលទឹកដោយការរីកចម្រើនផ្នែកបច្ចេកវិទ្យាមានដូចជា : ទឹកចេញពីរោងចក្រ ថ្នាំគីមីសម្លាប់សត្វល្អិត ការប្រើប្រាស់ម៉ាស៊ីនត្រជាក់និងយានយន្តច្រើន និងកត្តាធម្មជាតិ។
  - ការបំពុលទឹកដោយកត្តាធម្មជាតិមានដូចជា : ធ្វើឱ្យប៉ះពាល់ប្រភពទឹកផងដែរ ព្រោះនៅរដូវវស្សាទឹកជំនន់បាននាំកាកសំណល់ផ្សេងៗចូលក្នុងប្រភពទឹក។ នៅរដូវប្រាំង អាកាសធាតុក្ដៅខ្លាំងប្រភពទឹករាំងស្ងួត ហួត នាំឱ្យបាត់បង់ប្រភពទឹកប្រើប្រាស់។

❖ គ្រូបិទមេរៀនសង្ខេប និងហៅសិស្សឡើងអាន រួចឱ្យសិស្សចម្លងចូលក្នុងសៀវភៅកិច្ចការ។



**មេរៀនសង្ខេប**

ប្រភពទឹកមាននៅគ្រប់ទីកន្លែងដូចជា នៅលើដី ក្រោមដី ទឹកកក និងទឹកភ្លៀង។ លើដីមានទឹក ស្ទឹង បឹង ត្រពាំង ទន្លេ អូរ អាងស្តុកទឹក ប្រឡាយ ក្រោមដីមាន ទឹកអណ្ដូង។ ការបំពុលប្រភពទឹក គឺបង្កឡើងដោយសារ កត្តាមនុស្ស ការរីកចំរើនផ្នែកបច្ចេកវិទ្យា និងកត្តាធម្មជាតិ។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើទឹកដែលយើងប្រើប្រាស់មានប្រភពមកពីណាខ្លះ ?

២- តើការបំពុលទឹកដោយកត្តាមនុស្សមានអ្វីខ្លះ ? ការរីកចម្រើនផ្នែកបច្ចេកវិទ្យាមានអ្វីខ្លះ ? កត្តាធម្មជាតិមានអ្វីខ្លះ ?

**៨- លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកថែរក្សាប្រភពទឹកដែលយើងប្រើប្រាស់ឱ្យបានស្អាត ដើម្បីសុខភាពយើងទាំងអស់គ្នា។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការបំពុលទឹកនិងផលប៉ះពាល់សុខភាព ត្រង់ចំណងជើងផលប៉ះពាល់សុខភាព និងវិធានការបង្ការ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការបំពុលទឹកនិងផលប៉ះពាល់សុខភាព ( តចប់ )

## ខ្លឹមសារម៉ោងទី២ : ផលប៉ះពាល់សុខភាព និងវិធានការបង្ការ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
| --- | --- | --- |
| • រៀបរាប់ពីការបំពុលទឹកនាំឱ្យមានផលប៉ះពាល់សុខភាព និងវិធានការបង្ការ។ | • បង្ហាញពីមូលហេតុនៃការបំពុលទឹកនាំឱ្យមានផលប៉ះពាល់សុខភាព និងវិធានការបង្ការ។ | • បណ្ដុះស្មារតីយកចិត្តទុកដាក់ចូលរួមថែរក្សាការពារប្រភពទឹកមិនឱ្យមានការបំពុល។ |

**៣- សម្ភារៈ**

- សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

- ការបំពុលទឹកនាំឱ្យប៉ះពាល់ដល់សុខភាពដែលបង្កឡើងដោយបាក់តេរី វីរុស និងប៉ារ៉ាស៊ីតដែលបង្កឱ្យមានជំងឺដូចជា គ្រុនពោះវៀន រាក សើស្បែក ដង្កូវព្រូន រលាកថ្លើម ។ល។
- វិធានការបង្ការ : យើងមិនត្រូវចោល ចាក់ គរទុក ឬបង្ហូរកាកសំណល់ផ្សេងៗ ដូចជា សំណល់ រឹង រាវ ទៅក្នុងឬក្បែរប្រភពទឹក មិនត្រូវចិញ្ចឹមសត្វលើឬក្បែរប្រភពទឹកប្រើប្រាស់ និងត្រូវមានវិធានការ និងផែនការគ្រប់គ្រងកាកសំណល់។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់ ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្ដាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្ដាហ៍មុន ? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន រួចសួរ តើការបំពុលទឹកនាំឱ្យមានផលប៉ះពាល់ដល់សុខភាពអ្វីខ្លះ ? ចូរអ្នករៀបរាប់ពីវិធានការបង្ការពីការបំពុលទឹក ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ផលប៉ះពាល់សុខភាព វិធានការបង្ការ**

គ្រូពន្យល់ពីការបំពុលទឹកនាំឱ្យមានផលប៉ះពាល់សុខភាព និងវិធានការបង្ការ

គ្រូបែងចែកសិស្សជាបួនក្រុមពិភាក្សារយៈពេល៥ទៅ១០នាទី លើសំណួរខាងក្រោម៖

ក្រុមទី១ និងក្រុមទី២ : តើការបំពុលទឹកនាំឱ្យមានផលប៉ះពាល់អ្វីខ្លះដល់សុខភាព?

ក្រុមទី៣ និងក្រុមទី៤ : ដើម្បីបង្ការការបំពុលទឹក តើយើងត្រូវមានវិធានការអ្វីខ្លះ?

- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សំយោគចម្លើយ តាមខ្លឹមសារមេរៀន

ចម្លើយ

- ការបំពុលទឹកនាំឱ្យប៉ះពាល់ដល់សុខភាពដែលបង្កឡើងដោយបាក់តេរី វីរុស និងប៉ារ៉ាស៊ីតដែលបង្កឱ្យមានជំងឺដូចជា គ្រុនពោះវៀន រាក សើស្បែក ដង្កូវព្រូន រលាកថ្លើម ។ល។
- ដើម្បីបង្ការការបំពុលទឹកយើងត្រូវអនុវត្តតាមវិធានការដូចខាងក្រោម ៖
  - មិនត្រូវ ចោល ចាក់ ឬគរទុកសំណល់ផ្សេងៗនៅក្បែរប្រភពទឹក ដូចជា ស្រះ ត្រពាំង ទន្លេ ឬក៏ចាក់សំណល់រឹង រាវទៅក្នុងប្រភពទឹកជាដាច់ខាត
  - មិនត្រូវចិញ្ចឹមសត្វពាហនៈលើឬក្បែរប្រភពទឹកប្រើប្រាស់
  - មិនត្រូវបង្ហូរសំណល់ពីជីគីមីផ្សេងៗ ពីរោងចក្រ សិប្បកម្ម អាជីវកម្មចូលទៅក្នុងប្រភពទឹក
  - មិនត្រូវទុកដាក់ ជីគីមី និងថ្នាំសម្លាប់សត្វល្អិតផ្ទាល់ដី ព្រោះវាអាចជ្រាបចូលទៅក្នុងដី និងប្រភពទឹក
  - មិនត្រូវប្រើជីកសិកម្មគីមីដែលអាចបង្កផលប៉ះពាល់ដល់ទឹកលើដី និងទឹកក្រោមដី
  - មិនត្រូវឱ្យមានទឹកកខ្វក់នៅក្បែរប្រភពទឹកស្អាត ដែលអាចបង្កឱ្យមានជាតិពុល
  - មិនត្រូវបន្ទោបង់ក្នុងឬក្បែរប្រភពទឹក។



❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការបំពុលទឹកនាំឱ្យប៉ះពាល់ដល់សុខភាពដែលបង្កឡើងដោយបាក់តេរី វីរុស និងប៉ារ៉ាស៊ីត ដែលបង្កឱ្យមានជំងឺដូចជា គ្រុនពោះវៀន រាក សើស្បែក ដង្កូវព្រូន រលាកថ្លើម។ល។ វិធានការបង្ការការបំពុលប្រភពទឹក គឺមិនត្រូវចោលកាកសំណល់ចូលទៅក្នុងប្រភពទឹកប្រើប្រាស់ និងត្រូវមានវិធានការ និងផែនការគ្រប់គ្រងកាកសំណល់។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើការបំពុលទឹកនាំឱ្យមានផលប៉ះពាល់អ្វីខ្លះដល់សុខភាព?

២- ចូរអ្នករៀបរាប់ពីវិធានការបង្ការពីការបំពុលទឹក?

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរអ្នកថែរក្សាការពារប្រភពទឹកមិនត្រូវឱ្យមានការបំពុល ទឹកស្អាតនាំមកនូវសុខភាពល្អ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនគ្រោះថ្នាក់នៃសារធាតុញៀន សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : គ្រោះថ្នាក់នៃសារធាតុញៀន

## ខ្លឹមសារម៉ោងទី១ : និយមន័យសារធាតុញៀន និងគ្រោះថ្នាក់នៃសារធាតុញៀន

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ"សារធាតុញៀន" និងរៀបរាប់ពីគ្រោះថ្នាក់នៃសារធាតុញៀន។ | • បកស្រាយពីគ្រោះថ្នាក់នៃសារធាតុញៀន។ | • យកចិត្តទុកដាក់បង្ការខ្លួនពីការសាកល្បងសារធាតុញៀន |

**៣- សម្ភារៈ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**និយមន័យសារធាតុញៀន** : គឺជាសារធាតុដែលចម្រាញ់ចេញពីរុក្ខជាតិ ឬសារធាតុគីមីដែលមានសមត្ថភាពធ្វើឱ្យមានការផ្លាស់ប្តូរនូវមុខងារផ្សេងៗនៃសរពាង្គកាយរបស់មនុស្ស ឬសត្វ និងជាពិសេសប្រព័ន្ធសរសៃប្រសាទខួរក្បាល។ សារធាតុញៀនមានពីរប្រភេទ សារធាតុញៀនបានពីធម្មជាតិ មានដូចជា កញ្ឆា អាភៀន ប្រេងម្រះព្រៅ...និងសារធាតុញៀនបានពីការសំយោគ។

**គ្រោះថ្នាក់នៃសារធាតុញៀន** : ធ្វើឱ្យខូចសរីរាង្គថ្លើម បេះដូង តម្រងនោម និងសួត រាងកាយស្គមស្គាំង ស្លេកស្លាំង មិនងងុយដេក មិនឃ្លានអាហារ និងកំលាំងចុះថយដល់បុគ្គលដែលប្រើប្រាស់គ្រឿងញៀន។ ចំពោះគ្រួសារ : ធ្វើឱ្យបាត់បង់កិត្តិយស ខាតបង់ថវិកា បំផ្លាញទ្រព្យសម្បត្តិ បង្កការភ័យខ្លាច អំពើហិង្សា និងបង្កគ្រោះថ្នាក់ដល់ជីវិតគ្រួសារជាដើម ។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : ............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន ? ចម្លើយសិស្ស : ......

៣- តើអ្នកធ្លាប់ឃើញនិងជួបប្រទះអ្នកញៀនថ្នាំដែរឬទេ? តើអ្នកញៀនថ្នាំមានសភាព និងអាការៈដូចម្តេចខ្លះ?

- គ្រូហៅសិស្ស២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យសារធាតុញៀន និងគ្រោះថ្នាក់នៃសារធាតុញៀន**

- គ្រូបង្ហាញរូបភាពខាងក្រោម បន្ទាប់មកសួរសំណួរខាងក្រោម
  - តើរូបភាពនេះជារូបអ្វី?
  - ដូចម្តេចដែលហៅថាសារធាតុញៀន?
  - តើសារធាតុញៀនមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
  - គ្រូហៅសិស្ស២ ឬ៣ នាក់ឆ្លើយ។ ចម្លើយសិស្ស...


ដើមនិងផ្កាកញ្ឆា


ដើមនិងផ្លែអាភៀន


ដើមនិងស្លឹកកូកា


គ្រឿងញៀនជាប្រភេទគ្រាប់

**ចម្លើយ៖**

សារធាតុញៀន គឺជាសារធាតុដែលចម្រាញ់ចេញពីរុក្ខជាតិ ឬសារធាតុគីមីដែលមានសមត្ថភាពធ្វើឱ្យមានការផ្លាស់ប្តូរនូវមុខងារផ្សេងៗនៃសារពាង្គកាយរបស់មនុស្ស ឬសត្វ និងជាពិសេសប្រព័ន្ធសរសៃប្រសាទខួរក្បាល។ សារធាតុញៀនមានពីរប្រភេទ៖ **១- សារធាតុញៀនបានពីធម្មជាតិ** មានដូចជា កញ្ឆា អាភៀន ប្រេងម្រះព្រៅ **២- សារធាតុញៀនបានពីការសំយោគ** សំដៅដល់ប្រភេទគ្រឿងញៀនដែលត្រូវបានផលិតឬផ្សំឡើងពីសារធាតុគីមីទាំងឡាយ មានដូចជា  យ៉ាបា យ៉ាម៉ា ជាម្សៅ ជ័រ ឬការ គេប្រើដោយលេបចាក់ ជក់ និងខ្លះទៀតគេប្រើដោយហិត។

- គ្រូបែងចែកសិស្សជាក្រុមពិភាក្សាលើសំណួរខាងក្រោម ក្នុងរយៈពេល៥ទៅ១០នាទី
  - ១- តើសារធាតុញៀនបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នក (បុគ្គល) អ្វីខ្លះ?
  - ២- តើសារធាតុញៀនបណ្តាលឱ្យមានគ្រោះថ្នាក់ដល់គ្រួសារអ្វីខ្លះ?
  - ៣- តើសារធាតុញៀនបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សង្គមអ្វីខ្លះ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផល

- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេបតាមខ្លឹមសារនៃមេរៀន។





អំពើហឹង្សាក្នុងគ្រួសារ



ចោរលួច



ចោរឆក់

*ការញៀននិងផលប៉ះពាល់នៃសារធាតុញៀន*

## ចម្លើយ

**គ្រោះថ្នាក់នៃសារធាតុញៀនចំពោះបុគ្គលមាន ៖** សារធាតុញៀនបានជ្រាបចូលក្នុងសរីរាង្គថ្លើម បេះដូង តម្រងនោម និងសួត ដែលអាចបណ្ដាលឱ្យរាងកាយស្គមស្គាំង ស្លេកស្លាំង មិនងងុយដេក មិនឃ្លានអាហារ និងកំលាំងចុះថយ។ ករណីស្ត្រីមានផ្ទៃពោះ អាចមានឥទ្ធិពលផ្ទាល់ទៅលើទារកក្នុងផ្ទៃ ទាំងរាងកាយ និងខួរក្បាល ។ ចំពោះអ្នកប្រើម្ជុលសឺរ៉ាំងរួមគ្នា អាចឆ្លងមេរោគអេដស៍ រលាកថ្លើមប្រភេទ បេ សេ និងបូសថ្លើម ជាដើម។ សារធាតុញៀនធ្វើឱ្យប៉ះពាល់សុខភាពផ្លូវចិត្ត ដូចជា សតិស្មារតីមិនប្រក្រតី បាត់បង់ភាពម្ចាស់ការលើខ្លួនឯង ការចងចាំថយចុះ ឬបាត់បង់តែម្ដង កាចសាហាវ ឡប់សតិ ឬឆ្កួត។

**ចំពោះគ្រួសារ ៖** ធ្វើឱ្យបាត់បង់កិត្តិយស ខាតបង់ថវិកា បំផ្លាញទ្រព្យសម្បត្តិ បង្កការភ័យខ្លាច អំពើហិង្សា និងបង្កគ្រោះថ្នាក់ដល់ជីវិតគ្រួសារជាដើម។

**ចំពោះសង្គម ៖** បង្កអំពើហិង្សាទូទៅនិងផ្លូវភេទ គ្រោះថ្នាក់ចរាចរណ៍ ប្រព្រឹត្តអំពើឆក់ប្លន់ ឬបទឧក្រិដ្ឋផ្សេងៗ រួមទាំងបាត់បង់ធនធានមនុស្ស ធ្វើឱ្យសង្គមមិនរីកចម្រើន។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



## មេរៀនសង្ខេប

សារធាតុញៀន គឺជាសារធាតុដែលចម្រាញ់ចេញពីរុក្ខជាតិ ឬសារធាតុគីមីហើយមានសមត្ថភាពធ្វើឱ្យមានការផ្លាស់ប្ដូរនូវមុខងារផ្សេងៗនៃរូបរាងកាយ មនុស្ស ឬ សត្វ និងជាពិសេសប្រព័ន្ធសរសៃប្រសាទខួរក្បាល។ សារធាតុញៀនមានពីរប្រភេទ គឺសារធាតុញៀនបានពីធម្មជាតិនិងសំយោគ។ គ្រោះថ្នាក់នៃសារធាតុញៀនមានចំពោះ បុគ្គលធ្វើឱ្យប៉ះពាល់សុខភាព ចំពោះគ្រួសារ បំផ្លាញទ្រព្យសម្បត្តិ និងធ្វើឱ្យអសន្តិសុខសង្គម។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ដូចម្ដេចដែលហៅថាសារធាតុញៀន?

២- តើសារធាតុញៀនបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់អ្នកនិងគ្រួសារអ្វីខ្លះ?

**៨- លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកកុំព្យាយាមសាកល្បងឬប្រើប្រាស់សារធាតុញៀនឱ្យសោះ ព្រោះវានឹងបំផ្លាញអនាគតរបស់អ្នក។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនគ្រោះថ្នាក់នៃសារធាតុញៀន ត្រង់ចំណងជើងវិធីបង្ការការសាកល្បងសារធាតុញៀន សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : គ្រោះថ្នាក់នៃសារធាតុញៀន ( តចប់ )

## ខ្លឹមសារម៉ោងទី២ : វិធីបង្ការការសាកល្បងសារធាតុញៀន

**១- រយៈពេល :** ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីវិធីបង្ការការសាកល្បងសារធាតុញៀន។ | • បង្ហាញវិធីបង្ការការសាកល្បងសារធាតុញៀន។ | • យកចិត្តទុកដាក់បង្ការខ្លួនពីការសាកល្បងសារធាតុញៀន។ |

**៣- សម្ភារៈ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

វិធីបង្ការការសាកល្បងសារធាតុញៀន : ចូរកុំសាកល្បងប្រើប្រាស់សារធាតុញៀនសូម្បីតែម្តង ព្រោះវាជាសន្ទួចស្ទួចអ្នកឱ្យញៀន កុំសេពគប់មិត្តភក្តិដែលប្រើប្រាស់គ្រឿងញៀន ចេះជំនាញចរចា បដិសេធនៅពេលមានមិត្តភក្តិអូសទាញឱ្យប្រើប្រាស់គ្រឿងញៀន ចៀសវាងឱ្យឆ្ងាយពីអ្នកប្រើប្រាស់គ្រឿងញៀន និងផ្តល់ព័ត៌មានអ្នកសង្ស័យប្រើប្រាស់សារធាតុញៀនដល់លោកគ្រូ អ្នកគ្រូ និងអ្នកដែលទុកចិត្ត ក្នុងការណែនាំបន្ត ឱ្យទៅរកសេវាផ្តាច់សារធាតុញៀន កុំញុំាភេសជ្ជៈ ឬអាហារដែលមិនមែនជារបស់ខ្លួន។

**៥- វិធីសាស្ត្រ**

សំណួរបំផុស សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅសប្តាហ៍មុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅសប្តាហ៍មុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន រួចសួរ៖
  - ៣- តើផលប៉ះពាល់នៃសារធាតុញៀនដល់សហគមន៍ និងវិធីបង្ការការសាកល្បងសារធាតុញៀនមានអ្វីខ្លះ?
- គ្រូហៅសិស្ស២ ទៅ ៣នាក់ឱ្យឆ្លើយ

- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : វិធីបង្ការការសាកល្បងសារធាតុញៀន**

- គ្រូលើកយករូបភាពវិធីបង្ការការសាកល្បងសារធាតុញៀន មកបង្ហាញ។ បន្ទាប់មកសួរ តើរូបភាពនេះបង្ហាញពីអ្វីខ្លះ?។ ចម្លើយសិស្ស...



- គ្រូបែងចែកសិស្សជាក្រុមពិភាក្សា រយៈពេល ៥ទៅ១០នាទី នូវសំណួរ តើវិធីបង្ការការសាកល្បងសារធាតុញៀនមានអ្វីខ្លះ?
- តំណាងក្រុមឡើងបកស្រាយ
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេប តាមខ្លឹមសារនៃមេរៀន។

**ចម្លើយ**

- **វិធីការពារខ្លួនពីសារធាតុញៀន** ចូរកុំសាកល្បងប្រើប្រាស់សារធាតុញៀនសូម្បីតែម្តង ព្រោះវាជាសន្ទុចស្ទួចអ្នកឱ្យញៀន កុំសេពគប់មិត្តភក្តិដែលប្រើប្រាស់គ្រឿងញៀន ចេះជំនាញចរចា បដិសេធនៅពេលមានមិត្តភក្តិអូសទាញឱ្យប្រើប្រាស់គ្រឿងញៀន ចៀសវាងឱ្យឆ្ងាយពីអ្នកប្រើប្រាស់គ្រឿងញៀន និងផ្តល់ព័ត៌មានអ្នកសង្ស័យប្រើប្រាស់សារធាតុញៀនដល់លោកគ្រូ អ្នកគ្រូ និងអ្នកដែលទុកចិត្តក្នុងការណែនាំបន្តឱ្យទៅរកសេវាផ្តាច់សារធាតុញៀន។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

វិធីការពារខ្លួនពីសារធាតុញៀន ចូរកុំសាកល្បងប្រើប្រាស់សារធាតុញៀន កុំសេពគប់មិត្តភក្តិដែលប្រើប្រាស់គ្រឿងញៀន បដិសេធនៅពេលមានមិត្តភក្តិអូសទាញឱ្យប្រើប្រាស់ និងចៀសវាងឱ្យឆ្ងាយពីអ្នកប្រើប្រាស់គ្រឿងញៀន កុំញ៉ាំឱសថ ឬអាហារដែលមិនមែនជារបស់ខ្លួន៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើវិធីបង្ការការសាកល្បងសារធាតុញៀនមានអ្វីខ្លះ ?

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរអ្នកជៀសឆ្ងាយពីសារធាតុញៀនគ្រប់ប្រភេទ ដើម្បីអនាគតល្អរបស់អ្នក។